សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច

Université Royale de Droit et des Sciences Economiques

Royal University of Law and Economics


## សារណាបញ្ចប់ការសិក្សា

# មូលហេតុនៃការមិនទទួលខុសត្រូវ
# ឬការសម្រាលទោសនូវការទទួលខុសត្រូវព្រហ្មទណ្ឌ

ស្រាវជ្រាវចាប់ពីថ្ងៃទី ២៧ ខែ មេសា ឆ្នាំ ២០២១ ដល់ថ្ងៃទី ២៥ ខែ មិថុនា ឆ្នាំ ២០២១


រៀបរៀងដោយនិស្សិត

**១. កែវ សៃហ្វុង**

**២. ស្លេះ ម៉ារ៉ាអ៊ី**

ណែនាំដោយសាស្ត្រាចារ្យ៖

លោក **ជ្រ សុការ៉ា**


ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**

ជំនាន់ទី ២១

ឆ្នាំចូលសិក្សា ២០១៧

ឆ្នាំសរសេរសារណា ២០២១

# លិខិតថ្លែងអំណរគុណ

នាងខ្ញុំឈ្មោះ **កែវ សៃហ្វុង** និងមិត្តរួមក្រុមឈ្មោះ **ស្លេះ ម៉ារ៉ាអ៊ី** ជានិស្សិតថ្នាក់បរិញ្ញាបត្រនីតិសាស្ត្រ ជំនាន់ទី ២១ នៃ**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច** ក្នុងឆ្នាំសិក្សា ២០១៧-២០២១។

**យើងខ្ញុំសូមលំឱនកាយ ដឹងគុណកតញ្ញូតាធម៌ដល់អ្នកមានគុណយ៉ាងជ្រាលជ្រៅជាទីបំផុតជូនចំពោះអ្នកមានគុណរួមមាន៖**

**លោកឪពុក គង់ គឿន** **អ្នកម្តាយ ម៉ាក សារ៉ែម**

**លោកឪពុក ទូល័ស យូសុះ** **អ្នកម្តាយ ស្លេះ អាស៊ីហ្សះ**

អ្នកមានគុណទាំងពីរគឺ លោក ឪពុក និង អ្នកម្តាយ ដែលបានផ្តល់កំណើតដល់រូបកូន និងខិតខំចិញ្ចឹមបីបាច់ថែរក្សាអប់រំរូបកូន ដោយបានជួយទំនុកបម្រុងរូបកូនឲ្យទទួលបានការអប់រំដ៏ខ្ពង់ខ្ពស់រហូតដល់បានបញ្ចប់ថ្នាក់បរិញ្ញាបត្រប្រកបដោយជោគជ័យ។

អ៊ំប្រុស អ៊ំស្រី លោកពូ អ្នកមីង បងប្រុស បងស្រី ដែលជួយទំនុកបម្រុងទាំងផ្នែកសម្ភារៈ និងផ្នែកស្មារតីដោយបានផ្តល់នូវការលើកទឹកចិត្តយ៉ាងខ្លាំងក្លាដល់យើងខ្ញុំឲ្យខិតខំប្រឹងប្រែងរៀនសូត្ររហូតបានបញ្ចប់ថ្នាក់បរិញ្ញាបត្រនេះ។

ថ្នាក់ដឹកនាំ លោក លោកស្រីសាស្ត្រាចារ្យទាំងអស់ នៃ**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច** ដែលបានខិតខំបង្ហាត់បង្រៀនយើងខ្ញុំយ៉ាងយកចិត្តទុកដាក់នូវគ្រប់មុខវិជ្ជាដ៏មានតម្លៃទើបធ្វើឲ្យយើងខ្ញុំទទួលបាននូវចំណេះដឹងដ៏ឧត្តុងឧត្តម្ភ ដើម្បីទុកជាស្ពានសម្រាប់ចម្លងជីវិតទៅមុខជានិច្ច។

ជាពិសេសលោកសាស្ត្រាចារ្យមេធាវី **រួង សុនារ៉ា** ដែលលោកបានខិតខំអស់ពីកម្លាំងកាយចិត្តក្នុងការដឹកនាំបង្ហាត់បង្រៀននូវរាល់ចំណុចខ្វះខាតរបស់ពួកយើង ដោយលោកបានចំណាយពេលវេលាដ៏មានតម្លៃក្នុងការកែលម្អនូវចំណុចខ្វះខាតដែលបានកើតឡើងចាប់តាំងពីពេលចាប់ផ្តើមរហូតដល់ចុងបញ្ចប់។

ឆ្លៀតក្នុងឱកាសនេះផងដែរ យើងខ្ញុំសូមសម្តែងនូវការដឹងគុណដ៏ជ្រាលជ្រៅដល់អ្នកមានគុណទាំងអស់ដូចដែលយើងខ្ញុំបានរៀបរាប់ខាងលើដោយក្តីគោរពបំផុត សូមគោរពជូនពរឲ្យជួបប្រទះតែពុទ្ធពរទាំង ៥ ប្រការគឺ៖ អាយុ វណ្ណៈ សុខៈ ពលៈ បដិភាណៈ កុំបីឃ្លៀងឃ្លាតឡើយ ព្រមទាំងទទួលបានជោគជ័យគ្រប់ភារកិច្ច។

# អារម្ភកថា

សៀវភៅមួយក្បាលនេះគឺជាជំនួយដល់បណ្ដាអ្នកច្បាប់ដូចជា ចៅក្រម ព្រះរាជអាជ្ញា មេធាវី ក្រឡាបញ្ជី សារការី អាជ្ញាសាលា មន្ត្រីនគរបាលយុត្តិធម៌ ភ្នាក់ងារនគរបាលយុត្តិធម៌ ឬមន្ត្រីអនុវត្តច្បាប់ និងនិស្សិតច្បាប់។

ស្នាដៃក្នុងការបង្កើតសៀវភៅមួយក្បាលនេះ ក្នុងគោលបំណងចូលរួមចំណែកក្នុងការពង្រឹងនីតិរដ្ឋ ក៏ដូចជា លើកស្ទួយវិស័យយុត្តិធម៌តាមរយៈខ្លឹមសារនៃប្រធានបទដែលបង្ហាញជូនជនរួមជាតិ និងសាធារណៈមតិទូទៅអំពីគោលបំណង ឧត្តមគតិ និងការប្ដេជ្ញាចិត្តរបស់អ្នករៀបចំក្នុងការពុះពារ បម្រើជាតិ និងប្រជាជនគ្រប់កាលៈទេសៈ ព្រមទាំងបង្ហាញអំពីចក្ខុវិស័យពាក់ព័ន្ធនឹងយុត្តិធម៌ ដើម្បីបន្តកសាង និងការពារមាតុភូមិអង្គរដ៏បវររុងរឿងនៃយើងឲ្យឆ្ពោះទៅរកអនាគតមួយយ៉ាងត្រចះត្រចង់ស្របតាមឆន្ទៈ និងបំណងប្រាថ្នារបស់ប្រជាពលរដ្ឋខ្មែរព្រោះតែចង់បានយុត្តិធម៌។

ក្នុងស្មារតីនេះ អ្នករៀបរៀងនឹងព្យាយាមធ្វើឲ្យប្រធានបទមួយនេះផ្ដល់ជាអត្ថប្រយោជន៍ ក្នុងការសិក្សាស្រាវជ្រាវរបស់ប្រជាពលរដ្ឋខ្មែរគ្រប់រូប ជាពិសេស មេធាវី និងបណ្ដាអ្នកច្បាប់ទាំងអស់ ក្នុងការពិនិត្យ និងរកដំណោះស្រាយទៅលើបញ្ហាដែលពាក់ព័ន្ធនឹងច្បាប់។

យើងខ្ញុំសំណូមពរឲ្យជនរួមជាតិទាំងអស់ ពិសេសស្ថាប័នតុលាការ និងស្ថាប័នអនុវត្តច្បាប់នានា ជួយផ្ដល់ជាការគាំទ្រ ដោយចូលរួមអនុវត្តយ៉ាងសកម្មនូវតួនាទី និងភារកិច្ចរបស់ខ្លួនដើម្បីឲ្យក្លាយទៅជាចលនារួបរួមដ៏ខ្លាំងក្លាប្រកបដោយចីរភាពសំដៅសម្រេចឲ្យបាននូវភាពជោគជ័យជាផ្លែផ្កា សម្រាប់ឧត្ដមប្រយោជន៍ដ៏មានតម្លៃរបស់ប្រទេសកម្ពុជាលើវិស័យយុត្តិធម៌។

យើងខ្ញុំសូមសម្ដែងនូវសេចក្ដីគោរព និង ដឹងគុណដ៏ជ្រាលជ្រៅបំផុត ជូនចំពោះជនរួមជាតិនៅគ្រប់ទិសទីដែលបានផ្ដល់នូវជំនឿ និងការគាំទ្រយ៉ាងធំធេងដល់ស្នាដៃនេះ។ ការគាំទ្រនេះហើយ ធ្វើឲ្យអ្នករៀបរៀងបានប្ដេជ្ញាចិត្តប្រមូលផ្ដុំនូវ កម្លាំងកាយ កម្លាំងចិត្ត និងប្រាជ្ញា ព្រមទាំងចំណេះដឹងដែលទទួលបានពីការសិក្សាស្រាវជ្រាវ មកធ្វើការរៀបរៀង ចងក្រង ដើម្បីពន្យល់ឲ្យបានយ៉ាងលម្អិតលើប្រធានបទស្ដីពី **មូលហេតុនៃការមិនទទួលទទួលខុសត្រូវ ឬការសម្រាលទោសនូវការទទួលខុសត្រូវព្រហ្មទណ្ឌ។**

# មាតិកា

ទំព័រ

## សេចក្តីផ្តើម


**១. បុព្វហេតុនៃការស្រាវជ្រាវ** ....................................................................................១

**២. ចំណោទបញ្ហានៃការស្រាវជ្រាវ**.................................................................................២

**៣. គោលបំណងនៃការស្រាវជ្រាវ** ..................................................................................២

**៤. ដែនកំណត់នៃការស្រាវជ្រាវ**......................................................................................៣

**៥. វិធីសាស្ត្រនៃការស្រាវជ្រាវ**........................................................................................៣

**៦. សារៈសំខាន់នៃការស្រាវជ្រាវ**....................................................................................៣

**៧. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ**.....................................................................................៣


## ជំពូកទី១

## មូលហេតុអត្តនោម័តនៃការមិនទទួលខុសត្រូវ ឬការសម្រាលទោសនូវការទទួលខុសត្រូវព្រហ្មទណ្ឌ


**១.១ វិបល្លាសស្មារតី**.......................................................................................................៤

**១.១.១. និយមន័យ**.............................................................................................................៤

**១.១.២. ជនដែលចាត់ទុកជាវិបល្លាសស្មារតី** .......................................................................៥

**១.១.៣. ករណីពិសេស**.........................................................................................................៥

១.១.៣.១. ករណីវិបល្លាសស្មារតីគ្រាន់តែបន្ថយនូវការយល់ដឹងរបស់ខ្លួន ..................................៦

១.១.៣.២. ករណីប្រើប្រាស់គ្រឿងស្រវឹង គ្រឿងញៀន ឬសារធាតុច្បាប់ហាមឃាត់ ..........................៦

**១.១.៤. ការបង្ហាញភស្តុតាង**................................................................................................៦

**១.២. អានុភាពនៃកម្លាំង ឬការបង្ខំ** .......................................................................................៧

**១.២.១. និយមន័យ**.............................................................................................................៧

**១.២.២. ប្រភេទអានុភាពនៃកម្លាំង ឬការបង្ខំលើរូបរាងកាយ និង ផ្លូវចិត្ត**..................................៨

១.២.២.១. ការបង្ខំលើរូបរាងកាយ ...........................................................................................៨

១.២.២.២. ការបង្ខំលើផ្លូវចិត្ត .................................................................................................៨

**១.២.៣. លក្ខណៈអានុភាពនៃកម្លាំង ឬការបង្ខំ**.......................................................................៩

១.២.៣.១. លក្ខណៈអានុភាពនៃកម្លាំង ឬការបង្ខំដែលមិនអាចមើលឃើញជាមុនបាន.......................៩

១.២.៣.២. លក្ខណៈអានុភាពនៃកម្លាំង ឬការបង្ខំដែលមិនអាចជៀសវាងបាន.............................១០

## ជំពូកទី២

## មូលហេតុសត្យានុម័តនៃការមិនទទួលខុសត្រូវ ឬការសម្រាលទោសនូវការទទួលខុសត្រូវព្រហ្មទណ្ឌ


**២.១. ការអនុញ្ញាតដោយច្បាប់ ឬអាជ្ញាធរ** ..... ១១

**២.១.១. ការអនុញ្ញាតដោយច្បាប់** ..... ១២

២.១.១.១. និយមន័យ ..... ១២

២.១.១.២. ការអនុវត្តជាក់ស្តែង ..... ១២

**២.១.២. ការអនុញ្ញាតដោយអាជ្ញាធរ** ..... ១៣

២.១.២.១. ការអនុញ្ញាតដោយអាជ្ញាធរស្របច្បាប់ ..... ១៣

២.១.២.២. ការបញ្ជាស្របច្បាប់. ..... ១៤

**២.២. ការការពារស្របច្បាប់** ..... ១៤

**២.២.១. លក្ខខណ្ឌនៃការការពារស្របច្បាប់** ..... ១៥

២.២.១.១. ការការពារត្រូវតែចាំបាច់ ..... ១៥

២.២.១.២. បទល្មើស និងការឈ្លានពានត្រូវតែកើតមានក្នុងពេលជាមួយគ្នា ..... ១៦

២.២.១.៣. ភាពគ្មានវិសមាមាត្ររវាងមធ្យោបាយការពារនិងទម្ងន់នៃការឈ្លានពាន ..... ១៧

**២.២.២. លក្ខណៈក្នុងការការពារស្របច្បាប់** ..... ១៨

២.២.២.១. ការការពារខ្លួន ..... ១៨

២.២.២.២. ការការពារអ្នកដទៃ ..... ១៩

២.២.២.៣. ការការពារទ្រព្យសម្បត្តិ ..... ១៩

**២.៣. សច្ចធារណ៍នៃការការពារស្របច្បាប់** ..... ២០

**២.៤. ស្ថានភាពចាំបាច់** ..... ២១

**២.៤.១. គ្រោះថ្នាក់កំពុងមាន ឬដែលនឹងកើតមាន** ..... ២២

**២.៤.២. ការការពារចាំបាច់** ..... ២៣

**២.៤.៣. គ្មានវិសមាមាត្ររវាងមធ្យោបាយការពារជាមួយនឹងទម្ងន់នៃគ្រោះថ្នាក់** ..... ២៣


## ជំពូកទី៣

## មូលហេតុនីត្យានុកូលភាពនៃការមិនទទួលខុសត្រូវ ឬការសម្រាលទោសនូវទទួលខុសត្រូវព្រហ្មទណ្ឌ


**៣.១. ការមិនទទួលខុសត្រូវរបស់អនីតិជន** ..... ២៤

**៣.១.១. និយមន័យ** ..... ២៤

៣.១.២. អនីតិជនដែលមានអាយុក្រោម ១៤ ឆ្នាំ..........................................................................២៤
៣.១.៣. អនីតិជនដែលមានអាយុចាប់ពី ១៤ ឆ្នាំរហូតទៅដល់ក្រោម ១៨ ឆ្នាំ...........................២៥
៣.២. ការមិនទទួលខុសត្រូវរបស់នីតិបុគ្គលសាធារណៈ....................................................២៧
សេចក្តីសន្និដ្ឋាន……..................................................................................៣០
អនុសាសន៍………………………………………………………………...………………..…..៣១
ឯកសារយោង
ឧបសម្ព័ន្ធ

# សេចក្តីផ្តើម

## ១. មូលហេតុនៃការស្រាវជ្រាវ

ក្នុងប្រទេសមួយដើម្បីឲ្យប្រជាជនរបស់ខ្លួនរស់នៅប្រកបដោយសុខសន្តិភាព ប្រទេសមួយចាំបាច់ត្រូវមានច្បាប់ទំលាប់ក្នុងការរស់នៅប្រចាំថ្ងៃ។ ប្រសិនបើប្រទេសមួយគ្មានច្បាប់ទំលាប់គ្រប់គ្រាន់ ឬខ្វះចន្លោះត្រង់ផ្នែកណាមួយនោះ បណ្តាលឲ្យប្រទេសមួយនោះក្លាយទៅជាប្រទេសអាណាធិបតេយ្យយ៉ាងខ្លាំងមិនខាន ដូច្នេះហើយ រដ្ឋបង្កើតឲ្យមានច្បាប់សម្រាប់មនុស្សគ្រប់វណ្ណៈអនុវត្តជាចាំបាច់។ ច្បាប់បង្កើតឡើងក្នុងគោលបំណងការពារផលប្រយោជន៍ទាំងឯកជន និងសាធារណៈដល់ប្រជាជន ក៏ដូចជាប្រទេសជាតិទាំងមូលផងដែរ នៅពេលដែលនរណាម្នាក់ បានប្រព្រឹត្តបទល្មើសទាំងឡាយណាដែលផ្ទុយនឹងច្បាប់ បណ្តាលឲ្យប៉ះពាល់ដល់ប្រយោជន៍ឯកជន ឬសាធារណៈ ជននោះចាំបាច់ត្រូវតែទទួលខុសត្រូវព្រហ្មទណ្ឌចំពោះអំពើរបស់ខ្លួន។

ជាគោលការណ៍ក្នុងក្រមព្រហ្មទណ្ឌ នូវពេលដែលបទល្មើសមួយបានកើតឡើង ចាំបាច់ត្រូវតែមានបុគ្គលណាម្នាក់ទទួលខុសត្រូវចំពោះអំពើនោះ។ អ្នកប្រព្រឹត្តបទល្មើសអាចជា រូបវន្តបុគ្គល ឬនីតិបុគ្គល។ ចំពោះរូបវន្តបុគ្គលចែកជា ២ ប្រភេទគឺ៖ នីតិជន និងអនីតិជន។ **នីតិជន** សំដៅដល់ជនដែលមានអាយុចាប់ពី ១៨ ឆ្នាំ ឡើងទៅ។ រីឯ **អនីតិជន** សំដៅដល់ជនដែលមានអាយុក្រោម ១៨ ឆ្នាំ។

យោងតាមមាត្រា ៣១ ដល់ មាត្រា ៣៧ នៃក្រមព្រហ្មទណ្ឌ ក៏បានចែងអំពីនីតិជនដែលបានប្រព្រឹត្តបទល្មើស ប៉ុន្តែនីតិជននោះនៅតែរួចផុតពីការទទួលខុសត្រូវព្រហ្មទណ្ឌដដែលដោយសារតែនីតិជននោះត្រូវបានច្បាប់ចាត់ទុកថាជាជនវិបល្លាសស្មារតី ឬនីតិជននោះមិនបានកើតវិបល្លាសស្មារតីទេ ប៉ុន្តែគាត់បានប្រព្រឹត្តបទល្មើសដោយសារតែកម្លាំង ឬការបង្ខំណាមួយខាងក្រៅឆន្ទៈរបស់គាត់ និងកាន់តែមិនអាចទទួលខុសត្រូវ ប្រសិនបើអំពើដែលគាត់បានប្រព្រឹត្តស្ថិតក្នុងពេលបំពេញមុខងារដែលទទួលបានការអនុញ្ញាតដោយច្បាប់។ ដូច្នេះហើយ នីតិជនប្រភេទនេះមិនតម្រូវឲ្យទទួលខុសត្រូវព្រហ្មទណ្ឌចំពោះអំពើរបស់ខ្លួនបានឡើយ។

យោងតាមអនុសញ្ញាស្តីពី សិទ្ធិកុមារ ត្រង់បញ្ញត្តិនៃមាត្រា ៤០ បានតម្រូវឲ្យរដ្ឋជាភាគីដែលក្នុងនោះក៏មានព្រះរាជាណាចក្រកម្ពុជាផងដែរ ដែលត្រូវកំណត់កម្រិតអាយុអប្បបរមានៃការទទួលខុសត្រូវព្រហ្មទណ្ឌរបស់កុមារ។ មានន័យថាដែលក្រោមអប្បបរមានេះ កុមារត្រូវសន្មត់ជាមុនថាពុំមានសមត្ថភាពនឹងប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌឡើយ។ សមត្ថភាពទទួលខុសត្រូវព្រហ្មទណ្ឌ គឺជាលទ្ធភាពរបស់មនុស្សនៅពេលប្រព្រឹត្ត អំពើបង្កគ្រោះថ្នាក់ដល់សង្គមហើយជននោះអាចយល់ដឹងអំពីថវិតគ្រោះថ្នាក់នៃអំពើរបស់ខ្លួន និងអាចបញ្ជាក់នូវរាល់អំពើទាំងនោះបាន។ មនុស្សម្នាក់ត្រូវបានចាត់ទុកថា មានសមត្ថភាពទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌ ប្រសិនបើពេលប្រព្រឹត្តអំពើគ្រោះថ្នាក់ ហើយបុគ្គលនោះបានឈានដល់អាយុមួយដែលច្បាប់តម្រូវឲ្យទទួលខុសត្រូវព្រហ្មទណ្ឌចំពោះអំពើរបស់ខ្លួន។ ចំពោះការបង្កើតអំពីការម្រិតអាយុនៃការមិនទទួលខុសត្រូវព្រហ្មទណ្ឌគឺ ដោយសារតែអនីតិជនក៏ត្រូវបានចែកជា ២ ប្រភេទទៀតគឺ៖ អនីតិជនអាយុ ១៤ ឆ្នាំដល់ក្រោម ១៨ ឆ្នាំ និងអនីតិជនក្រោម

១៤ ឆ្នាំ កត្តាដែលជម្រុញឲ្យមានការបែងចែកអនីតិជនជាពីរប្រភេទបែបនេះដោយសារតែ អនីតិជនក៏មានការប្រែប្រួលដោយយោងទៅតាមគោលការណ៍នៃច្បាប់ព្រហ្មទណ្ឌ ការរីកចម្រើនផ្នែករូបរាងកាយ និងប្រាជ្ញាស្មារតីរបស់អនីតិជនផងដែរ។

## ២. ចំណោទបញ្ហានៃការស្រាវជ្រាវ

គោលការណ៍នៃក្រមព្រហ្មទណ្ឌ ចំពោះនីតិជនដែលបានកើតវិបល្លាសស្មារតីនៅពេលប្រព្រឹត្តបទល្មើស ឬនីតិជន ដែលបានប្រព្រឹត្តបទល្មើសដែលកើតចេញពីឆន្ទៈខាងក្រៅរបស់ខ្លួនក្រោមការបង្ខំណាមួយ ឬបានប្រព្រឹត្តបទល្មើសក្រោមការអនុញ្ញាតដោយច្បាប់ នីតិជនប្រភេទនេះមិនតម្រូវឲ្យទទួលខុសត្រូវព្រហ្មទណ្ឌបានឡើយដោយសារតែជនវិបល្លាសស្មារតី គឺជាជនដែលពុំមានបញ្ញាស្មារតីគ្រប់គ្រាន់ដូចទៅនឹងមនុស្សទូទៅ។ ចំពោះនីតិជនដែលមិនបានកើតវិបល្លាសស្មារតី តែបានប្រព្រឹត្តបទល្មើសក្រៅពីឆន្ទៈរបស់ខ្លួនក្រោមរូបភាពបង្ខំពីកម្លាំងណាមួយ ឬការអនុញ្ញាតដោយច្បាប់ ដោយសារតែអំពើទាំងនេះមានផលប្រយោជន៍ដល់សង្គម ឬដើម្បីការពារទ្រព្យសម្បត្តិណាមួយដែលកំពុង ឬនឹងរងនូវការឈ្លានពានដែលមិនត្រឹមត្រូវ។

ដោយសង្កេតឃើញថាសម័យបច្ចុប្បន្ន បញ្ហាគតិយុត្តមួយនេះអាចនិយាយបានថា មានភាគរយកើនឡើងច្រើនគួរឲ្យកត់សម្គាល់ ទើបពួកយើងបានសម្រេចចិត្តជ្រើសប្រធានបទ **មូលហេតុនៃការមិនទទួលខុសត្រូវ ឬការសម្រាលទោសនូវការទទួលខុសត្រូវព្រហ្មទណ្ឌ** យកមកចងក្រងសរសេរជាសារណាបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្ររបស់ពួកយើង។

**មូលហេតុនៃការមិនទទួលខុសត្រូវ ឬការសម្រាលទោសនូវការទទួលខុសត្រូវព្រហ្មទណ្ឌ** សំដៅដល់ជនទាំងឡាយណាដែលបានប្រព្រឹត្តបទល្មើសដែលមានចែងក្នុងច្បាប់ តែជននោះអាចរួចផុតពីការទទួលខុសត្រូវព្រហ្មទណ្ឌបានដោយចៅក្រមបានរកឃើញថា មានមូលហេតុត្រឹមត្រូវគ្រប់គ្រាន់ក្នុងការឲ្យចារីរួចផុតពីការទទួលខុសត្រូវព្រហ្មទណ្ឌបាន។

## ៣. គោលបំណងនៃការស្រាវជ្រាវ

ក្នុងការស្រាវជ្រាវទៅលើប្រធានបទមួយនេះ គោលបំណងក្នុងការស្រាវជ្រាវទៅលើបញ្ហាគតិយុត្តនៃក្រមព្រហ្មទណ្ឌដើម្បីស្វែងយល់ឲ្យបានកាន់តែស៊ីជម្រៅបន្ថែមទៀត ដើម្បីជាប្រយោជន៍ដ៏មានសារៈសំខាន់ក្នុងការក្នុងការស្វែងរកដំណោះស្រាយឲ្យបានត្រឹមត្រូវ ទៅលើបទល្មើសដែលបានកើតមានឡើង និងទុកជាឯកសារមួយដែលមានប្រយោជន៍សម្រាប់អ្នកច្បាប់ទាំងអស់ ក៏ដូចជានិស្សិតច្បាប់ផងដែរ។ ហើយសមិទ្ធផលនៃការស្រាវជ្រាវនេះ ក៏ជាផ្នែកមួយក្នុងការជួយលើកស្ទួយវិស័យច្បាប់នៅក្នុងព្រះរាជាណាចក្រកម្ពុជាឲ្យមានភាពរីកចម្រើនទៅមុខប្រកបដោយប្រសិទ្ធភាពផងដែរ។

## ៤. ដែនកំណត់នៃការស្រាវជ្រាវ

ដើម្បីឆ្លើយតបទៅនឹងចំណោទបញ្ហាខាងលើ ពួកយើងបានធ្វើការសិក្សាស្រាវជ្រាវ និងជ្រើសរើសឯកសារពាក់ព័ន្ធមួយចំនួនមកធ្វើការសិក្សាដើម្បីសរសេរសារណាមួយនេះឡើង។ ឯកសារទាំងនោះរួមមាន៖ ក្រម

ព្រហ្មទណ្ឌឆ្នាំ ២០០៩ ក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ ២០០៧ ច្បាប់ស្តីពីសិទ្ធិកុមារ ច្បាប់ស្តីពីយុត្តិធម៌អនីតិជន និង ឯកសារច្បាប់ពាក់ព័ន្ធមួយចំនួនទៀត។ នៅក្នុងការសរសេរសារណាមួយនេះ គឺបានលើកឡើងអំពីមូលហេតុ ឬ ភស្តុតាងទាំងឡាយណាដែលនាំឲ្យចារីរួចផុតពីការទទួលខុសត្រូវព្រហ្មទណ្ឌបាន។

## ៥. វិធីសាស្ត្រនៃការស្រាវជ្រាវ

ការរៀបរៀងសារណាមួយនេះឡើង គឺកើតចេញពីការស្រាវជ្រាវឯកសារច្បាប់មួយចំនួន ដែលមានប្រភពដើមមកពីសាស្ត្រាចារ្យផ្នែកច្បាប់ និងសារណារបស់សិស្សច្បងមួយចំនួន។ ទទួលបានការពិភាក្សាផ្តល់មតិយោបល់ទៅវិញទៅមកជាមួយមិត្តរួមក្រុម និងសាស្ត្រាចារ្យជំនាញផ្នែកច្បាប់ ព្រមទាំងសៀវភៅច្បាប់មួយចំនួននៃព្រះរាជាណាចក្រកម្ពុជា ដែលមានអត្ថន័យពាក់ព័ន្ធទៅលើប្រធានបទមួយនេះ មកចងក្រងជាសារណាមួយបែបវិធីសាស្ត្រពិពណ៌នា និងវិភាគ។

## ៦. សារៈសំខាន់នៃការស្រាវជ្រាវ

អត្ថប្រយោជន៍នៃសមិទ្ធផលសារណាអំពីប្រធានបទមួយនេះគឺមានសារៈប្រយោជន៍សម្រាប់ពួកយើងដែលជាអ្នកចងក្រងអំពីប្រធានបទមួយនេះឡើងឲ្យមានការយល់ដឹងកាន់តែច្បាស់អំពីមូលហេតុនៃការមិនទទួលខុសត្រូវព្រហ្មទណ្ឌ ឬការសម្រាលទោសនូវការទទួលខុសត្រូវព្រហ្មទណ្ឌ និងទុកសម្រាប់ជាឯកសារមួយដែលពោរពេញទៅដោយអត្ថប្រយោជន៍ សម្រាប់ប្អូនៗនិស្សិតជំនាន់ក្រោយយកទៅសិក្សាបន្ថែមដើម្បីបង្កើននូវចំណេះដឹងឲ្យបានកាន់តែស៊ីជម្រៅ។

## ៧. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

ចំពោះរចនាសម្ព័ន្ធនៃប្រធានបទ **មូលហេតុនៃការមិនទទួលខុសត្រូវ ឬការសម្រាលទោសនូវការទទួលខុសត្រូវព្រហ្មទណ្ឌ** បែងចែកជា ៣ ជំពូកធំៗគឺ៖

**ជំពូកទី ១ ៖ មូលហេតុអត្តនោម័តនៃការមិនទទួលខុសត្រូវ ឬការសម្រាលទោសនូវការទទួលខុសត្រូវព្រហ្មទណ្ឌ**

**ជំពូកទី ២ ៖ មូលហេតុសត្យានុម័តនៃការមិនទទួលខុសត្រូវ ឬការសម្រាលទោសនូវការទួលខុសត្រូវព្រហ្មទណ្ឌ**

**ជំពូកទី ៣ ៖ មូលហេតុនីត្យានុកូលភាពនៃការមិនទទួលខុសត្រូវ ឬការសម្រាលទោសនូវការទួលខុសត្រូវព្រហ្មទណ្ឌ**

# ជំពូកទី១
# មូលហេតុអត្តនោម័តនៃការមិនទទួលខុសត្រូវ ឬការសម្រាលទោសនូវការទទួលខុសត្រូវព្រហ្មទណ្ឌ

មូលហេតុអត្តនោម័តនៃការមិនទទួលខុសត្រូវ ឬការសម្រាលទោសនូវការទទួលខុសត្រូវព្រហ្មទណ្ឌគឺជាមូលហេតុម្យ៉ាង ដែលក្រមព្រហ្មទណ្ឌបានផ្តោតសំខាន់ទៅលើស្ថានភាពរបស់ចារីដោយផ្ទាល់។ មូលហេតុនេះជាឧបសគ្គដ៏ធំមួយដែលពិបាកក្នុងការទម្លាក់កំហុសទៅលើចារី ព្រោះតែចារីពុំមានបញ្ញាស្មារតីធម្មតាដូចមនុស្សទូទៅ ឬពុំមានសេរីភាពគ្រប់គ្រាន់ក្នុងការប្រព្រឹត្តអំពើល្មើសទេ។ នៅក្នុងករណីនេះកាលបើបទល្មើសមួយបានកើតឡើង គឺតែងតែកើតចេញពីបុគ្គលណាម្នាក់ជាអ្នកប្រព្រឹត្តបទល្មើសមួយនោះ ប៉ុន្តែនៅពេលដែលបទល្មើសបានកើតឡើងរួចភ្លាមៗ ចៅក្រមពុំអាចសន្និដ្ឋានបានថាចារីនោះជាបុគ្គលប្រភេទណាបានទេ ដូច្នេះហើយទើបក្រមព្រហ្មទណ្ឌបានធ្វើការផ្តោតសំខាន់ទៅលើបុគ្គលដែលជាចារីនោះយ៉ាងយកចិត្តទុកដាក់បំផុត ទើបបន្តនីតិវិធីទៅលើបទល្មើសដែលបានកើតឡើងជាមួយនឹងចារីដោយផ្ទាល់នោះបន្តទៀត។ ប៉ុន្តែនៅក្នុងន័យនេះ ចំពោះសហចារីពុំអាចលើកយកមូលហេតុខាងលើដើម្បីឲ្យខ្លួនរួចផុតពីការទទួលខុសត្រូវព្រហ្មទណ្ឌបានឡើយ។ ដោយហេតុថាបុគ្គលទាំងនោះមានលក្ខណៈខុសគ្នាជាមួយបុគ្គលដែលជាចារីនៃបទល្មើស។

មូលហេតុអត្តនោម័តនៃការមិនទទួលខុសត្រូវ ឬការសម្រាលទោសនូវការទទួលខុសត្រូវព្រហ្មទណ្ឌដោយយោងតាមក្រមព្រហ្មទណ្ឌរួមមាន៖ **១.១. វិបល្លាសស្មារតី និង ១.២. អានុភាពនៃកម្លាំង ឬការបង្ខំ**

## ១.១. វិបល្លាសស្មារតី

### ១.១.១. និយមន័យ

**វិបល្លាសស្មារតី៖** មានន័យថា បើជាមនុស្ស គឺមនុស្សដែលមានបញ្ហាផ្នែកប្រព័ន្ធប្រសាទ។

យោងតាមមាត្រា ៣១ នៃក្រមព្រហ្មទណ្ឌបានចែងថា៖ កាលបើជនណាម្នាក់បានប្រព្រឹត្តអំពើល្មើសនៅពេលដែលជននោះកើតវិបល្លាសស្មារតី ដែលធ្វើឲ្យបាត់បង់នូវការយល់ដឹងខុសត្រូវរបស់ខ្លួន ជននោះមិនតម្រូវឲ្យទទួលខុសត្រូវព្រហ្មទណ្ឌចំពោះអំពើល្មើសរបស់ខ្លួនបានឡើយ។[1]

កាលបើជនណាម្នាក់បានបានប្រព្រឹត្តបទល្មើសមួយដែលច្បាប់បានបញ្ញត្តទុកជាមុន ថែមទាំងទទួលបានការរួចផុតពីការទទួលខុសត្រូវព្រហ្មទណ្ឌនូវរាល់អំពើល្មើសរបស់ខ្លួនទៅវិញ ក្នុងករណីដែលមានភស្តុតាង ឬសាក្សីគ្រប់គ្រាន់បញ្ជាក់ថា ជននោះបានកើតវិបល្លាសស្មារតី ឬភាសាសាមញ្ញហៅថា មនុស្សឆ្កួតនៅពេលប្រព្រឹត្តបទល្មើស ដូច្នេះចៅក្រមនឹងសម្រេចលើកយកមាត្រា ៣១ នៃក្រមព្រហ្មទណ្ឌមកអនុវត្តទៅលើអង្គហេតុមួយនេះ។[2]

1.ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ ២០០៩, មាត្រា ៣១

2. ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ ២០០៩, មាត្រា ៣១ កថាខណ្ឌទី១

### ១.១.២. ជនដែលចាត់ទុកជាវិបល្លាសស្មារតី

ជនវិបល្លាសស្មារតី សំដៅដល់ជនទាំងឡាយណាដែលមានបញ្ហាផ្នែកប្រព័ន្ធប្រសាទ វិកលចរិត សតិមិនប្រក្រតីដែលមិនអាចយល់ដឹងនូវរាល់ទង្វើរបស់ខ្លួនបានដូចមនុស្សធម្មតាក្នុងរយៈពេលមិនអាចកំណត់ ឬក្នុងរយៈពេលខ្លី ហើយបញ្ហាជំងឺវិបល្លាសស្មារតីនោះ បានបង្កភាពលំបាកខ្លាំងដល់អ្នកជំងឺផ្នែកវិបល្លាសស្មារតី និងមនុស្សជុំវិញខ្លួនថែមទៀតផង។ ជនដែលកើតវិបល្លាសស្មារតីពុំអាចធ្វើកិច្ចការងាររកប្រាក់សម្រាប់ចិញ្ចឹមជីវិត ឬមើលថែខ្លួនបានដូចមនុស្សទូទៅបានឡើយ ថែមទាំងធ្វើឲ្យអ្នកនៅជុំវិញខ្លួនមានការលំបាកក្នុងការចិញ្ចឹម មើលថែ និងគ្រប់គ្រងថែមទៀតផង ដូច្នេះកាលបើជនណាម្នាក់បានប្រព្រឹត្តបទល្មើសនៅពេលដែលជននោះបានកើតវិបល្លាសស្មារតី ជននោះមិនតម្រូវឲ្យទទួលខុសត្រូវព្រហ្មទណ្ឌឡើយ។

បញ្ហាវិបល្លាសស្មារតីទាំងនេះបណ្តាលមកពីកត្តាមួយចំនួនដូចជា៖ ជរាភាព គ្រោះថ្នាក់ចារាចរណ៍ ឬអាចបណ្តាលមកពីកត្តាមួយចំនួនជាច្រើនទៀតដែលរៀបរាប់មិនអស់។ ដោយសារតែប្រព័ន្ធប្រសាទមានបញ្ហាមិនប្រក្រតី បណ្តាលឲ្យចារីបានបាត់បង់នូវលទ្ធភាពផ្នែកការយល់ដឹងអំពីតថភាពរបស់សង្គមជុំវិញខ្លួនបាន និងកាន់តែពុំអាចគ្រប់គ្រង ត្រួតពិនិត្យរាល់សកម្មភាពរបស់ខ្លួនបានថែមទៀតផង ជាហេតុនាំឲ្យបុគ្គលប្រភេទនេះបានប្រព្រឹត្តបទល្មើសណាមួយដោយពុំបានគិតវែងឆ្ងាយពីព្យសនកម្មទៅដល់សង្គម អ្នកដ៏ទៃ ក៏ដូចជាខ្លួនឯង និងក្រុមគ្រួសារបាន។

ឧទាហរណ៍៖ បុរសម្នាក់ធ្លាប់ជួបគ្រោះថ្នាក់ចរាចរណ៍បណ្តាលឲ្យប៉ះពាល់ដល់ផ្នែកប្រព័ន្ធប្រសាទរបស់គាត់យ៉ាងធ្ងន់ធ្ងរ រហូតត្រូវបានចាត់ទុកថា ជាជនវិបល្លាសស្មារតី។ ថ្ងៃមួយបុរសនោះបានដើរតាមដងផ្លូវ ស្រាប់តែបុរសនោះរើសយកដុំថ្មមួយដុំធំគប់ទៅលើនារីម្នាក់ដែលកំពុងជិះម៉ូតូក្បែរនោះ។ ក្នុងករណីនេះមិនតម្រូវឲ្យគាត់ទទួលខុសត្រូវព្រហ្មទណ្ឌឡើយ បើទោះបីជាគាត់បានប្រព្រឹត្តបទល្មើសក៏ពិតមែន ប៉ុន្តែបុរសនោះត្រូវបានចាត់ទុកថាជាជនវិបល្លាសស្មារតី។

### ១.១.៣. ករណីពិសេស

នៅក្នុងករណីនេះ ជនដែលកើតវិបល្លាសស្មារតី ដែលជាមូលហេតុនៃការមិនទទួលខុសត្រូវ ឬសម្រាលទោសនូវការទទួលខុសត្រូវព្រហ្មទណ្ឌ ចាំបាច់ត្រូវតែជាវិបល្លាសស្មារតីដែលបំផ្លាញនូវការយល់ដឹងរបស់ខ្លួនទាំងស្រុង ឬជនទាំងឡាយណាដែលបំផ្លាញចោលទាំងស្រុងនូវរាល់សកម្មភាពរបស់ខ្លួន។[3]

បុគ្គលទាំងឡាយណាដែលបាត់បង់ការយល់ដឹងគ្រប់បែបយ៉ាង ហើយកាន់តែពុំអាចដឹង ឬចងចាំអ្វីទាំងអស់ដែលខ្លួនបានប្រព្រឹត្តដោយផ្ទាល់ហើយអំពើទាំងឡាយដែលបានកើតឡើងដោយចារីនោះ គឺដោយសារតែចារីនោះបានកើតជំងឺវិបល្លាសស្មារតី ឬហៅថាជំងឺឆ្កួត។ ដូច្នេះក្នុងករណីមួយនេះត្រូវបានចាត់ចូលជាករណីពិសេសក្នុងការឲ្យចារីដែលបានកើតវិបល្លាសស្មារតីទទួលបាននូវការរួចផុតពីការទទួលខុសត្រូវទាំងស្រុង។

3.ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ ២០០៩ មាត្រា ៣១

ឧទាហរណ៍៖ នារីម្នាក់មានបញ្ហាផ្នែកប្រព័ន្ធប្រសាទធ្ងន់ធ្ងរ មិនអាចគ្រប់គ្រងខ្លួនឯងបាន។ ថ្ងៃមួយគាត់បានប្រព្រឹត្តបទល្មើសហិង្សាទៅលើម្តាយរបស់គាត់ ដោយការវាយបោចសក់ម្តាយរបស់គាត់យ៉ាងចាស់ដៃបណ្តាលឲ្យម្តាយរបស់គាត់រងរបួសយ៉ាងធ្ងន់ធ្ងរ។ ក្នុងករណីនេះជនល្មើសមិនតម្រូវឲ្យទទួលខុសត្រូវព្រហ្មទណ្ឌទេដោយសារតែនារីម្នាក់នោះបានកើតវិបល្លាសស្មារតីទាំងស្រុង ដែលជាហេតុនាំឲ្យគាត់ទទួលបាននូវការរួចផុតពីការទទួលខុសត្រូវព្រហ្មទណ្ឌដោយយោងទៅតាមមាត្រា ៣១ កថាខណ្ឌទី ១ នៃក្រមព្រហ្មទណ្ឌឆ្នាំ ២០០៩។

**១.១.៣.១. ករណីវិបល្លាសស្មារតីគ្រាន់តែបន្ថយនូវការយល់ដឹងរបស់ខ្លួន**

ក្នុងករណីនេះប្រសិនបើចារីមានវិបល្លាសស្មារតី គ្រាន់តែបន្ថយនូវការយល់ដឹងរបស់ខ្លួនចារីនោះនៅតែទទួលខុសត្រូវព្រហ្មទណ្ឌដដែល។ មានន័យថាចារីគ្រាន់តែខ្សោយបញ្ញាស្មារតីរបស់ខ្លួន ប៉ុន្តែគាត់អាចត្រួតពិនិត្យនូវរាល់សកម្មភាព ឬអំពើដែលគាត់បានប្រព្រឹត្ត នោះគាត់នូវតែទទួលខុសត្រូវព្រហ្មទណ្ឌដដែល គ្រាន់តែថាអាចបន្ថយទោសសម្រាប់ចារីបានទៅតាមកម្រិតផ្នែកប្រព័ន្ធប្រសាទរបស់ចារីនោះ។[4] វិបល្លាសស្មារតីអាចមានច្រើនករណីដូចជា វិបល្លាសស្មារតីដែលបណ្តាលឲ្យបាត់បង់ទាំងស្រុងនូវការយល់ដឹង ឬពុំអាចត្រួតពិនិត្យរាល់សកម្មភាពរបស់ខ្លួនបានទាំងស្រុង។ ក្រៅពីករណីវិបល្លាសស្មារតីទាំងស្រុង ក៏មានវិបល្លាសស្មារតីគ្រាន់តែបន្ថយនូវការយល់ដឹងរបស់ខ្លួនដែរ។

វិបល្លាសស្មារតីគ្រាន់តែបន្ថយនូវការយល់ដឹងផ្នែកប្រព័ន្ធប្រសាទ ច្រើនបណ្តាលមកពីប្រភពមួយចំនួនដូចជា៖ ការប្រើប្រាស់គ្រឿងស្រវឹង គ្រឿងញៀន ឬសារធាតុដែលច្បាប់ហាមឃាត់។

ឧទាហរណ៍៖ ជនម្នាក់មានបញ្ហាផ្នែកប្រព័ន្ធប្រសាទ ម្តងអាចគ្រប់គ្រងខ្លួនបាន ម្តងមិនអាចគ្រប់គ្រងខ្លួនបាន ថ្ងៃមួយជននោះបានប្រព្រឹត្តបទល្មើស ដោយយកកាំបិតមុតស្រួចទៅចាក់ឆ្វេតឡានអ្នកជិតខាងបណ្តាលឲ្យរងការខូចខាតជាច្រើន។ ក្នុងករណីនេះជននោះនូវតែទទួលខុសត្រូវដដែលគ្រាន់តែគាត់ទទួលបាននូវការសម្រាលទោសដោយសារតែគាត់កើតវិបល្លាសស្មារតី ដោយគ្រាន់តែបន្ថយនូវការយល់ដឹងតែប៉ុណ្ណោះ។

**១.១.៣.២. ករណីប្រើប្រាស់គ្រឿងស្រវឹង គ្រឿងញៀន ឬសារធាតុច្បាប់ហាមឃាត់**

ចំពោះបញ្ហាចោទឡើងអំពីការប្រើប្រាស់នូវគ្រឿងស្រវឹង គ្រឿងញៀន ឬសារធាតុដែលច្បាប់បានហាមឃាត់ ដោយសារតែសារធាតុទាំងនេះ បានបណ្តាលឲ្យមានឥទ្ធិពលប៉ះពាល់យ៉ាងខ្លាំងទៅដល់ប្រព័ន្ធសាទរបស់មនុស្ស រួមមានដូចជា៖ គ្រឿងញៀនគ្រប់ប្រភេទ សុរា ឬប្រភេទសារធាតុផ្សេងៗ មួយចំនួនទៀតដែលច្បាប់ហាមឃាត់។ ការប្រើប្រាស់នូវគ្រឿងស្រវឹង គ្រឿងញៀន ឬសារធាតុដែលច្បាប់ហាមឃាត់ច្រើនលើសកម្រិតបណ្តាលឲ្យប្រព័ន្ធប្រសាទដំណើរការមិនប្រក្រតី (ម្តងអាចគ្រប់គ្រងខ្លួនឯងបាន ម្តងមិនអាចគ្រប់គ្រងខ្លួនឯងបាន) ប៉ុន្តែការកំណត់ថាការប្រើប្រាស់សារធាតុទាំងនេះស្តែងចេញពីឆន្ទៈខាងក្នុងរបស់បុគ្គលផ្ទាល់តែម្តង។ ដូច្នេះហើយទើបក្រមព្រហ្មទណ្ឌត្រង់មាត្រា ៣១ កថាខណ្ឌទី ៣ មិនត្រូវចាត់ទុកថាវិបល្លាសស្មារតីដែលកើត

4.ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ ២០០៩, មាត្រា ៣១ កថាខណ្ឌទី២

ចេញពីការប្រើប្រាស់ គ្រឿងញៀន គ្រឿងស្រវឹង ឬសារធាតុទាំងឡាយណាច្បាប់បានហាមឃាត់មិនអាចរួចផុតពីការទទួលខុសត្រូវព្រហ្មទណ្ឌបានឡើយ។[5]

ឧទាហរណ៍ៈ បុរសម្នាក់បានទៅចូលរួមកម្មវិធីជប់លៀងមួយកន្លែងដោយមានការពិសារនូវគ្រឿងស្រវឹង ដោយបុរសនោះបានពិសារគ្រឿងស្រវឹងក្នុងបរិមាណច្រើនបណ្តាលឲ្យស្រវឹងនៅពេលចប់កម្មវិធី។ បន្ទាប់មកគាត់ក៏បានបើករថយន្តត្រឡប់ទៅផ្ទះវិញ ពេលកំពុងធ្វើដំណើរលើដងផ្លូវគាត់បានជ្រុលចង្កូតទៅបុកអ្នកជិះម៉ូតូលើផ្លូវជាមួយស្របទិសដៅគ្នា បណ្តាលឲ្យអ្នកជិះម៉ូតូរួមផ្លូវនោះរងរបួសយ៉ាងធ្ងន់ធ្ងរ។ ក្នុងករណីនេះ បុរសដែលជាអ្នកបើករថយន្តមិនអាចរួចផុតពីការទទួលខុសត្រូវបានទេ ដោយគាត់មានបញ្ហាផ្នែកស្មារតីតែមួយពេល ដែលគាត់បានពិសារគ្រឿងស្រវឹងតែប៉ុណ្ណោះ។

បន្ថែមពីនេះទៅទៀត ក្រមព្រហ្មទណ្ឌកាន់តែមិនអាចចាត់ទុកថាជាវិបល្លាសស្មារតីនូវប្រភេទជាហេតុនូវការមិនទទួលខុសត្រូវ ឬការសម្រាលនូវការទទួលខុសត្រូវព្រហ្មទណ្ឌបានឡើយដោយហេតុថា ចារីវិបល្លាសស្មារតីប្រភេទនេះ គឺជាបុគ្គលមានបញ្ញាស្មារតីធម្មតាដូចបុគ្គលទូទៅដែរ ហើយបុគ្គលប្រភេទនេះកើតវិបល្លាសស្មារតីនៅពេលដែលបានប្រើប្រាស់នូវ គ្រឿងស្រវឹង គ្រឿងញៀន ឬសារធាតុដែលច្បាប់បានហាមឃាត់តែប៉ុណ្ណោះ ហើយការប្រើប្រាស់នោះគឺបានកើតចេញពីឆន្ទៈខាងក្នុងរបស់គាត់។ ដូចការលើកឡើងខាងលើនេះ បន្ទាប់ពីសារធាតុទាំងនោះសាបទៅវិញ គាត់ក៏មានសតិធម្មតាវិញដែរ ដូច្នេះហើយទើបក្រមព្រហ្មទណ្ឌចាំបាច់ត្រូវមានការបែងចែកអំពីបញ្ហាវិបល្លាសស្មារតីទាំងស្រុង និងវិបល្លាសស្មារតីគ្រាន់តែបន្ថយនូវការយល់ដឹងរបស់ខ្លួនជាពីរផ្នែកផ្សេងគ្នាបែបនេះ ក្នុងគោលបំណងដើម្បីរកភាពយុត្តិធម៌យ៉ាងសុក្រឹតជូនជនរងគ្រោះ និងធ្វើការដាក់ទណ្ឌកម្មយ៉ាងត្រឹមត្រូវទៅលើជនដែលប្រព្រឹត្តបទល្មើស។

### ១.១.៤. ការបង្ហាញភស្តុតាង

ដើម្បីទទួលបានការរួចផុតពីការទទួលខុសត្រូវ ឬការសម្រាលនូវការទទួលខុសត្រូវព្រហ្មទណ្ឌ ចាំបាច់ត្រូវតែមានការបង្ហាញភស្តុតាងមកបញ្ជាក់ពីអត្ថិភាពនៃវិបល្លាសស្មារតីដែលចារីមាននៅពេលប្រព្រឹត្តបទល្មើស។ ភស្តុតាងនេះត្រូវរកឲ្យបានគ្រប់គ្រាន់ ព្រមទាំងពិតប្រាកដដោយគ្មានការប្រឌិតឡើង ឬប្រើមធ្យោបាយណាមួយដើម្បីបន្លំឲ្យខ្លួនទទួលបានការរួចផុតពីការទទួលខុសត្រូវព្រហ្មទណ្ឌបានឡើយ ពោលគឺមិនមានការសន្មត់ថាជនណាម្នាក់បានកើតវិបល្លាសស្មារតីពិតប្រាកដនៅពេលប្រព្រឹត្តបទល្មើសទេ ទោះបីជាជននោះស្ថិតក្រោមអាណាព្យាបាលទូទៅក៏ដោយ។

ជាទូទៅភស្តុតាងនៃវិបល្លាសស្មារតីត្រូវមានការបញ្ជាក់ដោយវេជ្ជបណ្ឌិតជំនាញ ក៏ប៉ុន្តែយោបល់ទាំងនោះពុំមានអានុភាពចងជាកាតព្វកិច្ចឲ្យចៅក្រមត្រូវតែជឿតាមទេ ពោលគឺចៅក្រមអាចជឿក៏បាន ឬមិនជឿក៏បាន។

ឧទាហរណ៍ៈ បទល្មើសមួយបានកើតឡើង ព្រមទាំងមានការបញ្ជាក់ពីវេជ្ជបណ្ឌិតជំនាញផ្នែកប្រព័ន្ធប្រសាទថា ជននោះជាជនវិបល្លាសស្មារតី ក្នុងករណីចៅក្រមរកឃើញថា ការបញ្ជាក់របស់វេជ្ជបណ្ឌិតជាការពិត

5.ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ ២០០៩, មាត្រា ៣១ កថាខណ្ឌទី៣

នោះចៅក្រមនឹងសម្រេចឲ្យចារីនោះរួចផុតពីការទទួលខុសត្រូវព្រហ្មទណ្ឌបាន ប៉ុន្តែក្នុងករណីចៅក្រមរកឃើញថា ការបញ្ជាក់ពីវេជ្ជបណ្ឌិតនោះជាការប្រឌិតឡើង នោះចៅក្រមនឹងសម្រេចឲ្យចារីនៅតែទទួលខុសត្រូវព្រហ្មទណ្ឌដដែល។

## ១.២. អានុភាពនៃកម្លាំង ឬការបង្ខំ

### ១.២.១. និយមន័យ

**អានុភាព៖** ថាមពលនៃកម្លាំងអ្វីមួយ។

យោងតាមមាត្រា ៣៦ នៃក្រមព្រហ្មទណ្ឌបានចែងថា៖ បុគ្គលដែលប្រព្រឹត្តបទល្មើសក្រោមអានុភាពនៃកម្លាំង ឬការបង្ខំ ដែលបុគ្គលនោះមិនអាចទប់ស្កាត់បាន មិនតម្រូវឲ្យទទួលខុសត្រូវព្រហ្មទណ្ឌនោះឡើយ។[6]

កម្លាំង និងការបង្ខំអាចចេញមកពីព្រឹត្តិការណ៍ក្រៅឆន្ទៈរបស់មនុស្សតែប៉ុណ្ណោះ។ កម្លាំង និងការបង្ខំនេះត្រូវតែមិនអាចមើលឃើញជាមុនបាន និងមិនអាចជៀសវាងបាន។[7] ក្នុងករណីដែលបទល្មើសមួយបានកើតឡើង ហើយបុគ្គលនោះពុំអាចដឹងជាមុន ឬពុំអាចត្រៀមខ្លួនក្នុងការទប់ទល់នឹងបទល្មើសមួយនោះបានក៏បង្ខំចិត្តប្រព្រឹត្តបទល្មើសនោះទៅ ដូច្នេះបុគ្គលនោះមិនតម្រូវឲ្យទទួលខុសត្រូវព្រហ្មទណ្ឌបានទេ។

ក្រមព្រហ្មទណ្ឌថ្មីមិនបានឲ្យនិយមន័យលើពាក្យ អានុភាពនៃកម្លាំង ឬការបង្ខំឡើយ។ ចំណែកឯក្រមព្រហ្មទណ្ឌចាស់មិនបានប្រើពាក្យ អានុភាពនៃកម្លាំង ឬការបង្ខំឡើយ ប៉ុន្តែចែងអំពីកម្លាំងបង្ខំនៅមាត្រា ៩៦ ថា៖ កាលបើមានភស្តុតាងមានកម្លាំងអ្វីមួយមកបង្ខំនរណាម្នាក់ឲ្យប្រព្រឹត្តបទល្មើសអ្វីមួយ ហើយបុគ្គលនោះពុំអាចទប់ស្កាត់នឹងកម្លាំងនោះបានក៏ប្រព្រឹត្តបទល្មើសនោះទៅ។ ជនដែលប្រព្រឹត្តបទល្មើសនោះមិនតម្រូវឲ្យទទួលខុសត្រូវព្រហ្មទណ្ឌចំពោះអំពើដែលខ្លួនបានប្រព្រឹត្តឡើយ។[8] មាត្រា ៩៧ នៃក្រមព្រហ្មទណ្ឌចាស់បានឲ្យនិយមន័យនៃពាក្យកម្លាំងបង្ខំថា ជាគ្រោះថ្នាក់ណាមួយដែលបណ្តាលឲ្យមានអាសន្នយ៉ាងធំបំផុត ។ ពាក្យថា **អាសន្នយ៉ាងធំបំផុត** មានន័យថាគ្រោះយ៉ាងធំបំផុតដែលនឹងត្រូវធ្លាក់មកលើខ្លួនក្នុងពេលមិនអាចជៀសផុតពីគ្រោះថ្នាក់នោះបាន ដោយមិនបានប្រព្រឹត្តបទល្មើសមួយនោះទេ ម្យ៉ាងទៀតគ្រោះថ្នាក់នោះកាលបើមានកើតឡើងក៏មិនមែនកើតឡើងមកពីឆន្ទៈផ្ទាល់របស់ចារីនៃបទល្មើសនោះដែរ និងមិនមែនខ្លួនចារីនោះជាអ្នកបង្កើត ឬជាអ្នកបណ្តាលឲ្យមានគ្រោះថ្នាក់នោះដែរ។[9]

ថ្វីត្បិតតែក្រមព្រហ្មទណ្ឌថ្មីពុំបានឲ្យនិយមន័យជាក់លាក់លើពាក្យ អានុភាពនៃកម្លាំង ឬការបង្ខំក៏ដោយ ក៏ខ្លឹមសារនៃមាត្រា ៣៦ នៃក្រមព្រហ្មទណ្ឌថ្មីពុំមានអ្វីខុសប្លែកពីមាត្រា ៩៦ នៃក្រមព្រហ្មទណ្ឌចាស់ដែរវាអាចជាប្រទីបមួយសម្រាប់ស្វែងយល់ពីមាត្រា ៣៦ នៃក្រមព្រហ្មទណ្ឌថ្មីបាន។

6.ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ ២០០៩, មាត្រា ៣៦ កថាខណ្ឌទី១

7.ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ ២០០៩, មាត្រា ៣៦ កថាខណ្ឌទី២

8.ក្រមព្រហ្មទណ្ឌចាស់នៃព្រះរាជាណាចក្រកម្ពុជា, មាត្រា ៩៦

9.ក្រមព្រហ្មទណ្ឌចាស់នៃព្រះរាជាណាចក្រកម្ពុជា, មាត្រា ៩៧

តាមរយៈមាត្រា ៣៦ នៃក្រមព្រហ្មទណ្ឌថ្មីស្តីពីអានុភាពនៃកម្លាំង ឬការបង្ខំ និងមាត្រា ៣៥ នៃក្រមនេះដដែលស្តីពីស្ថានភាពចាំបាច់ អាចបណ្តាលឲ្យមានការយល់ច្រឡំរវាងស្ថានភាពទាំងពីរនេះ។ អានុភាពនៃកម្លាំង ឬការបង្ខំគឺជាមូលហេតុអត្តនោម័តនៃការមិនទទួលខុសត្រូវព្រហ្មទណ្ឌ ចំណែកឯស្ថានភាពចាំបាច់គឺស្ថិតក្នុងមូលហេតុសត្យានុម័តនៃការមិនទទួលខុសត្រូវព្រហ្មទណ្ឌ ឬហៅម្យ៉ាងទៀតថាយុត្តកម្មនៃបទល្មើស វវាងមាត្រា ៣៥ និង មាត្រា ៣៦ ខុសគ្នាត្រង់ថា សម្រាប់ស្ថានភាពចាំបាច់ ចារីមានជម្រើសពីរយ៉ាងគឺ ការប្រព្រឹត្តបទល្មើស ឬទុកឲ្យគ្រោះថ្នាក់ឲ្យកើតមាន ចំណែកឯអានុភាពនៃកម្លាំង ឬការបង្ខំវិញចារីពុំមានជម្រើសទេដោយទទួលរងនូវកម្លាំងមិនអាចទប់ទល់បាន ក៏នាំឲ្យចារីប្រព្រឹត្តបទល្មើសតែម្តង។[10]

ឧទាហរណ៍៖ បុរសជាអ្នករត់តាក់ស៊ីម្នាក់ បានបើកបរគោរពតាមច្បាប់ចរាចរណ៍ដែលបានកំណត់ នៅពេលកំពុងបើកបរ ស្រាប់តែមានខ្យល់ព្យុះយ៉ាងធំមួយបានគួចបោកឡានបុរសនោះបណ្តាលឲ្យធ្លាក់ផ្លូវ និងក្រឡាប់ បណ្តាលឲ្យអ្នកធ្វើដំណើរក្នុងឡាននោះរងរបួសជាច្រើននាក់។ ក្នុងករណីនេះបុរសរត់តាក់ស៊ីនោះមិនតម្រូវឲ្យទទួលខុសត្រូវព្រហ្មទណ្ឌបានទេ ដោយហេតុថាអំពើរបស់គាត់គឺស្តែងចេញពីឆន្ទៈខាងក្រៅរបស់គាត់តែប៉ុណ្ណោះ។

អានុភាពនៃកម្លាំង ឬការបង្ខំមានពីរយ៉ាងគឺ៖ ១.១ ត្រូវមានលក្ខណៈពីរយ៉ាង ១.២. ដើម្បីឲ្យក្លាយទៅជាមូលហេតុនូវការមិនទទួលខុសត្រូវព្រហ្មទណ្ឌ។

### ១.២.២. ប្រភេទអានុភាពនៃកម្លាំង ឬការបង្ខំលើរូបរាងកាយ និង ផ្លូវចិត្ត

ប្រភេទនៃកម្លាំងលើរូបរាងកាយ និងផ្លូវចិត្ត គឺជាព្រឹត្តិការណ៍ដែលស្តែងចេញពីរបស់ធម្មជាតិ សត្វ ឬតតិយជនទៅកាន់ចារីក្នុងរូបភាពដែលមិនអាចទប់ទល់បាន បណ្តាលឲ្យចារីបង្ខំចិត្តត្រូវតែប្រព្រឹត្តបទល្មើសនោះតែម្តង។

ប្រភេទអានុភាពនៃកម្លាំង ឬការបង្ខំមានពីរប្រភេទគឺ៖ ការបង្ខំលើរូបរាងកាយ និងការបង្ខំលើផ្លូវចិត្ត។

#### ១.២.២.១. ការបង្ខំលើរូបរាងកាយ

ការបង្ខំលើរូបរាងកាយសំដៅដល់ការប្រើកម្លាំងតាមរូបភាពណាមួយទៅលើចារី ដែលជាហេតុនាំឲ្យចារីត្រូវតែប្រព្រឹត្តបទល្មើសដោយខ្លួនពុំអាចឃាត់ឃាំងអំពើនោះបាន។ កម្លាំងបង្ខំអាចជាកម្លាំងបង្ខំមកពីឆន្ទៈខាងក្រៅតែប៉ុណ្ណោះ ដូចជាកម្លាំងបង្ខំមកពីព្រឹត្តិការណ៍ធម្មជាតិ មកពីសត្វ ឬមកពីតតិយជនណាមួយ។

ឧទាហរណ៍៖ ខ្យល់ព្យុះ ឬរន្ទះបាញ់ បានបណ្តាលឲ្យអ្នកបើកបរមិនអាចទប់ទល់ចង្កូតឡានបាន ហើយក៏ជ្រុលចង្កូតទៅកិនអ្នកថ្មើរជើងតាមដងផ្លូវបណ្តាលឲ្យស្លាប់បាត់បង់ជីវិត និងរបួសជាច្រើននាក់។

ឧទាហរណ៍៖ បុរសម្នាក់បានបើកបរត្រឹមត្រូវតាមល្បឿនកំណត់នៅលើដងផ្លូវ ពេលកំពុងបើកបរស្រាប់តែមានក្មេងពីរនាក់បានរត់លេងប្រឡែងគ្នា ក៏រត់ជ្រុលចូលចំពីមុខឡានរបស់បុរសកំពុងបើកបរនោះបណ្តាលឲ្យ

10.ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ ២០០៩, មាត្រា ៣៥, ៣៦

បុរសនោះបុកស្លាប់ម្នាក់។ អ្នកបើកបរមិនអាចត្រូវផ្តន្ទាទោសពីបទ បើកបរបណ្តាលឲ្យស្លាប់អ្នកដទៃដោយអចេតនាបានទេ។

**១.២.២.២. ការបង្ខំលើផ្លូវចិត្ត**

ការបង្ខំលើផ្លូវចិត្តមានលក្ខណៈខុសគ្នារវាងការបង្ខំលើរូបរាងកាយត្រង់ថា ការបង្ខំលើរូបរាងកាយ ចារីប្រព្រឹត្តបទល្មើសក្រោមការបង្ខំពីឆន្ទៈខាងក្រៅ។ ចំណែកឯការបង្ខំលើផ្លូវចិត្តវិញគឺ ចារីប្រព្រឹត្តបទល្មើសក្រោមការបង្ខំពីឆន្ទៈខាងក្នុង ការបង្ខំលើផ្លូវចិត្តគឺជាឥទ្ធិពលមួយដែលចារីទទួលរងសម្ពាធយ៉ាងធ្ងន់ធ្ងរបំផុតពីតតិយជនក្នុងការបង្ខំឲ្យចារីនោះចាំបាច់ត្រូវតែប្រព្រឹត្តបទល្មើស ជាហេតុនាំឲ្យចារីចាំបាច់ត្រូវតែបង្ខំចិត្តប្រព្រឹត្តបទល្មើសដោយកើតចេញពីការគំរាមកំហែងនោះតែម្តង។

ឧទាហរណ៍៖ (A) និង(B) ជាមិត្តភក្តិស្និតស្នាលគ្នា ហើយនាក់ទាំងពីរសុទ្ធសឹងតែជាមនុស្សល្អដែលអាចទុកចិត្តគ្នាទៅវិញទៅមកបាន ប៉ុន្តែថៃដន្យថ្ងៃមួយ (A) បានជ្រុលខ្លួនលេងល្បែងស៊ីសងជាមួយ (C) រហូតអស់លុយពីខ្លួនថែមទាំងអស់ឡាន ១ គ្រឿងទៀត។ ដោយ (A) ភ័យខ្លាចប្រពន្ធដឹងរឿងនេះ ថែមពុំអាចដឹងថាមានវិធីណាយកទ្រព្យទាំងនោះមកវិញបានភ្លាមៗ ក៏សម្រេចចិត្តថានឹងប្រព្រឹត្តបទល្មើស តែបែរជាប្រើប្រាស់កលល្បិចខលហៅ (B)ឲ្យមករកខ្លួននៅកន្លែងណាត់ជួបមួយកន្លែង ពេល (B)មកដល់ (A) ក៏បានបង្ខំឲ្យ (B) ប្លន់ភ្លាមៗទៅលើ (C)ជាមួយខ្លួនដើម្បីយកទ្រព្យទាំងនោះមកវិញ បើមិនធ្វើតាមខ្លួនប្រាប់ទេនោះ (A)នឹងបាញ់ (B) ឲ្យស្លាប់ភ្លាមៗ ហើយនឹងបន្តទៅសម្លាប់ទាំងពូជរបស់ (B) ថែមទៀត ជាហេតុនាំឲ្យ (B) ចាំបាច់ត្រូវតែប្រព្រឹត្តបទល្មើសតាមការបញ្ជារបស់ (A)។ ក្នុងករណីនេះ (B) មិនតម្រូវឲ្យទទួលខុសត្រូវព្រហ្មទណ្ឌទ្បើយ។

ការបង្ខំលើផ្លូវចិត្តដែលមានប្រភពមកពីចារីដោយផ្ទាល់ មិនអាចជាមូលហេតុនៃការមិនទទួលខុសត្រូវព្រហ្មទណ្ឌបានឡើយ។

ឧទាហរណ៍៖ ជម្លោះមួយបានកើតឡើងរវាងភាគី (ក) និង (ខ) ហើយជម្លោះនោះបានដោះស្រាយចប់ដាច់ស្រេចអស់រយៈពេលជាយូរហើយ ស្រាប់តែថ្ងៃមួយភាគី (ក) នឹកឃើញដល់ជម្លោះដែលបានកើតនោះក៏ផ្ទុះកំហឹងម្តងទៀត ថែមទាំងបានប្រព្រឹត្តបទល្មើសទៅលើភាគី (ខ) យ៉ាងធ្ងន់ធ្ងរ។ ក្នុងករណីនេះចារីនៅតែទទួលខុសត្រូវព្រហ្មទណ្ឌដដែល ដោយហេតុថាជាការបង្ខំផ្លូវចិត្តនេះមានប្រភពមកពីព្រឹត្តិការណ៍ក្នុងឆន្ទៈរបស់ចារីផ្ទាល់តែម្តង។

**១.២.៣. លក្ខណៈអានុភាពនៃកម្លាំង ឬការបង្ខំ**

ក្នុងលក្ខណៈនេះ ប្រហាក់ប្រហែលទៅនឹងករណីប្រធានសក្តិនៅក្នុងរឿងរដ្ឋប្បវេណីដែរ។ នៅមាត្រា ៣៦ កថាខណ្ឌទី ២ នៃក្រមព្រហ្មទណ្ឌតម្រូវឲ្យកម្លាំង និងការបង្ខំមានលក្ខណៈពីរយ៉ាងដើម្បីឲ្យកម្លាំង ឬការបង្ខំនេះក្លាយជាមូលហេតុនៃការមិនទទួលខុសត្រូវព្រហ្មទណ្ឌបាន ពោលគឺកម្លាំង និងការបង្ខំត្រូវតែមិនអាចមើលឃើញជាមុនបាន។[11]

11.ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧

### ១.២.៣.១. លក្ខណៈអានុភាពនៃកម្លាំង ឬការបង្ខំដែលមិនអាចមើលឃើញជាមុនបាន

កម្លាំង និងការបង្ខំត្រូវតែជាស្ថានភាពមួយដែលមិនអាចមើលឃើញជាមុនបាន ពោលគឺចារីដែលមិនអាចប៉ាន់ស្មានដឹងមុនបាននោះឡើយ ហើយក៏មិនមែនកើតចេញពីកំហុសណាមួយរបស់គាត់ផ្ទាល់ដែរ។ មានន័យថា បទល្មើសទាំងនោះគឺវាកើតឡើងភ្លាមៗដោយពុំមាននរណាម្នាក់អាចដឹង ឬប៉ាន់ស្មានបានជាមុនទាល់តែសោះ ព្រមទាំងកាន់តែពុំមានពេលវេលាគ្រប់គ្រាន់ក្នុងការស្វែងរកដំណោះស្រាយណាមួយក្រៅពីការប្រព្រឹត្តបទល្មើសបានឡើយ។

ឧទាហរណ៍៖ ក្នុងករណីជនដែលខ្វះការប្រុងប្រយ័ត្នក្នុងការទប់ស្កាត់អំពើដែលកើតមកលើខ្លួន មិនអាចរួចផុតពីការទទួលខុសព្រហ្មទណ្ឌបានឡើយ។

ឧទាហរណ៍៖ បុរសម្នាក់បានបើកបរដែលមានល្បឿនត្រឹមត្រូវតាមច្បាប់កំណត់ ប៉ុន្តែពេលកំពុងបើកបរតាមដងផ្លូវ គាត់បានប្រើប្រាស់ទូរស័ព្ទដៃមិនប្រយ័ត្ន បណ្តាលឲ្យជ្រុលចង្កូតទៅបុកអ្នកដែលធ្វើដំណើររួមផ្លូវជាមួយគ្នា បណ្តាលឲ្យមានគ្រោះថ្នាក់ដល់អ្នកធ្វើដំណើររួមផ្លូវជាមួយគ្នា។ ក្នុងករណីនេះអ្នកបើកបរមិនអាចលើកសំអាងថា ខ្លួនបានបើកបរគោរពតាមច្បាប់ចរាចរណ៍បានទេ ហើយគាត់ក៏មិនអាចរួចផុតពីការទទួលខុសត្រូវព្រហ្មទណ្ឌបានឡើយ។

### ១.២.៣.២. លក្ខណៈអានុភាពនៃកម្លាំង ឬការបង្ខំដែលមិនអាចជៀសវាងបាន

កម្លាំង និងការបង្ខំដែលត្រូវនឹងកើតហើយមិនអាចជៀសវាងបានគឺជាកម្លាំង និងការបង្ខំដែលលុបបំបាត់ចោលទាំងស្រុងនូវសេរីភាពក្នុងការប្រព្រឹត្តបទល្មើស។ ចារីត្រូវស្ថិតក្នុងស្ថានភាពមិនអាចទប់ទល់នឹងកម្លាំងបង្ខំខាងលើបាន ហើយមិនអាចជ្រើសរើសអំពើណាមួយផ្សេងទៀតក្រៅពីការប្រព្រឹត្តបទល្មើសឡើយ។ ការវាយតម្លៃអំពីលក្ខណៈមិនអាចជៀសវាងបាននៃកម្លាំង និងការបង្ខំគឺអាស្រ័យទៅតាមករណីនីមួយៗ ទៅតាមសម្បទារបស់ជនណាម្នាក់ក្នុងការទប់ទល់នឹងកម្លាំងនោះ។ ដើម្បីឲ្យរួចផុតពីការទទួលខុសត្រូវព្រហ្មទណ្ឌត្រូវមានភស្តុតាងបញ្ជាក់អំពីជនប្រព្រឹត្តអំពើស្ថិតក្នុងស្ថានភាពមួយដែលខ្លួនមិនអាចជៀសវាងការប្រព្រឹត្តបទល្មើសបានតែម្តង ឬនិយាយបានម្យ៉ាងទៀតថា ចារីស្ថិតក្នុងស្ថានភាពមួយដែលអលទ្ធភាពដាច់ខាតក្នុងការគោរពច្បាប់។

ប្រសិនបើចារីមានលទ្ធភាពដែរ និងជៀសវាងបានខ្លះដែរ ក៏ប៉ុន្តែចារីនោះនៅតែប្រព្រឹត្តបទល្មើសទៀត ចារីនោះមិនអាចលើកសំអាងអំពីកម្លាំង ឬការបង្ខំដើម្បីឲ្យចារីបានរួចផុតពីការទទួលខុសត្រូវព្រហ្មទណ្ឌបានឡើយ។ ជាធម្មតាការរកភស្តុតាងមកបញ្ជាក់អំពីស្ថានភាពមិនអាចជៀសបាន រមែងតែងតែមានការលំបាកយ៉ាងខ្លាំង។

ឧទាហរណ៍៖ បុរសម្នាក់មិនអាចលើកសំអាងឲ្យខ្លួនរួចផុតពីការទទួលខុសត្រូវព្រហ្មទណ្ឌ ដោយមូលហេតុថា ដោយសារតែមានក្រុមចោរមួយក្រុមបានចូលមកក្នុងផ្ទះគាត់ ថែមទាំងបាននាំយករថយន្តខុសច្បាប់មួយគ្រឿងមកលក់ឲ្យគាត់ដោយការគំរាមកំហែងថានឹងសម្លាប់ទាំងពូជនៅថ្ងៃណាមួយឲ្យទាល់តែបាន ប្រសិនបើបុរសនោះមិនទិញរថយន្តខុសច្បាប់នោះ។ ក្នុងករណីនេះវាជាការបង្ខំពិតមែន ប៉ុន្តែការបង្ខំនេះដែរក៏អាចទប់ស្កាត់បានតាមរយៈការប្តឹងទប់ស្កាត់ទៅអាជ្ញាធរមានសមត្ថកិច្ចជាដើម។

# ជំពូកទី២
# មូលហេតុសត្យានុម័តនៃការមិនទទួលខុសត្រូវ ឬការសម្រាលទោសនូវការទទួលខុសត្រូវព្រហ្មទណ្ឌ

មូលហេតុសត្យានុម័តនៃការមិនទទួលខុសត្រូវ ឬយុត្តកម្មនៃបទល្មើសគឺជាអំពើមួយ ដែលជាធម្មតាត្រូវផ្តន្ទាទោសដោយច្បាប់ តែបែរជាត្រូវចាត់ទុកថាត្រឹមត្រូវទៅវិញ នៅពេលដែលអំពើនោះបានបង្ហាញពីការអនុវត្តសិទ្ធិ ឬជាការបំពេញកាតព្វកិច្ចដែលមានប្រយោជន៍សម្រាប់សង្គមជាតិ ឬប្រជាជនទូទៅ។ បានសេចក្តីថា អំពើនោះកើតឡើងគឺដោយសារតែផលប្រយោជន៍ស្របច្បាប់ ម្យ៉ាងវិញទៀតកាលបើជនណាម្នាក់បានប្រព្រឹត្តបទល្មើសអ្វីមួយដែលមានចែងក្នុងច្បាប់ព្រហ្មទណ្ឌ ហើយអំពើដែលបានកើតឡើងនោះប្រព្រឹត្តឡើងដើម្បីតែផលប្រយោជន៍ដល់សង្គម ឬអ្នកដទៃតែបែរជាច្បាប់ចាត់ទុកថាជាបទល្មើសដែលមានស្ថានទម្ងន់ទោសទៅវិញ វាពិតជាអយុត្តិធម៌ខ្លាំងណាស់។ ដូច្នេះហើយទើបច្បាប់បានបញ្ញត្តថា អំពើទាំងឡាយណាដែលបានប្រព្រឹត្តក្រោមការអនុវត្តសិទ្ធិ ឬការបំពេញមុខងារដែលច្បាប់បានអនុញ្ញាត គឺជាអំពើស្របច្បាប់ប្រសើរជាងចាត់ទុកអំពើទាំងនោះជាអំពើខុសច្បាប់។ យុត្តកម្មនៃបទល្មើសកើតឡើងក្នុងករណី ៣ យ៉ាងគឺ៖

១. ការអនុញ្ញាតដោយច្បាប់ ឬអាជ្ញាធរ

២. ការការពារស្របច្បាប់

៣. និងស្ថានភាពចាំបាច់

## ២.១. ការអនុញ្ញាតដោយច្បាប់ ឬអាជ្ញាធរ

យោងតាមមាត្រា ៣២ នៃក្រមព្រហ្មទណ្ឌបានចែងថា៖ បុគ្គលណាដែលប្រព្រឹត្តអំពើដែលបានបញ្ញត្ត ឬមានការអនុញ្ញាតតាមច្បាប់ បុគ្គលនោះមិនត្រូវបានចាត់ទុកថាប្រព្រឹត្តបទល្មើសទេ។ បុគ្គលណាដែលបានប្រព្រឹត្តបទល្មើសតាមការបញ្ជារបស់អាជ្ញាធរស្របច្បាប់ បុគ្គលនោះក៏មិនត្រូវចាត់ទុកថាប្រព្រឹត្តបទល្មើសដែរ។ លើកលែងតែងអំពើនោះជាអំពើខុសយ៉ាងជាក់ច្បាស់។[12]

យោងតាមបញ្ញត្តិក្រមព្រហ្មទណ្ឌខាងលើនេះ អ្នកនីតិបញ្ញត្តិមានបំណងបង្កើតជាយុត្តកម្មនូវអំពើដែលតាមធម្មតាជាបទល្មើស ប៉ុន្តែអំពើនោះបែរជាមិនត្រូវចាត់ទុកថាជាបទល្មើសទៅវិញ ដោយសារតែច្បាប់អនុញ្ញាតឲ្យធ្វើ ឬដោយសារតែអាជ្ញាធរស្របច្បាប់បានបញ្ជាឲ្យធ្វើយ៉ាងដូច្នេះ។ ម្យ៉ាងវិញទៀត នៅពេលដែលបទល្មើសណាមួយបានកើតឡើង ច្បាប់តែងតែស្វែងរកនូវមូលហេតុ ក៏ដូចជាភស្តុតាងនៃអង្គហេតុឲ្យបានគ្រប់គ្រាន់ជាមុនសិនទើបបន្តនីតិវិធីវិនិច្ឆ័យទៅលើអង្គហេតុដែលបានកើតឡើងនោះរហូតឈានដល់ការសម្រេចសេចក្តីថាតើគួរចាត់ទុកអំពើនោះជាអំពើល្មើស ឬរួចផុតពីការទទួលខុសត្រូវព្រហ្មទណ្ឌ។

12.ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ ២០០៩, មាត្រា ៣២ កថាខណ្ឌទី១ និង ទី២

### ២.១.១. ការអនុញ្ញាតដោយច្បាប់

#### ២.១.១.១. និយមន័យ

**អនុញ្ញាត៖** ការយល់ព្រម ការបើកឱកាសឲ្យ ការផ្តល់ឲ្យនូវសិទ្ធិអ្វីមួយ។

ក្នុងករណីច្បាប់បញ្ញត្ត ឬអនុញ្ញាតឲ្យប្រព្រឹត្តអំពើណាមួយ ហើយច្បាប់មិនអាចអនុញ្ញាតឲ្យផ្តន្ទាទោសអំពើដែលកើតចេញពីការបំពេញកាតព្វកិច្ចតម្រូវដោយច្បាប់ ឬការអនុវត្តសិទ្ធិដែលច្បាប់បានអនុញ្ញាតនោះឡើយ។

ករណីអំពើមួយដែលបានប្រព្រឹត្តឡើងដោយការចាំបាច់ ក្នុងការបំពេញមុខងារតាមការបញ្ញត្តរបស់ច្បាប់ ហើយអំពើនោះកាន់តែមានប្រយោជន៍ខ្លាំងសម្រាប់ផលប្រយោជន៍បុគ្គល និងសាធារណៈ ដូច្នេះអំពើទាំងនោះមិនត្រូវឲ្យទទួលខុសត្រូវព្រហ្មទណ្ឌឡើយ។

ឧទាហរណ៍៖ មេធាវីម្នាក់បានការពារក្តីឲ្យកូនក្តីរបស់ខ្លួនដែលត្រូវបានចោទប្រកាន់ពីបទបើកបរដោយការធ្វេសប្រហែសបណ្តាលឲ្យរបួសធ្ងន់ដល់អ្នកដទៃ។ ក្នុងករណីនេះមេធាវីមិនត្រូវបានចាត់ទុកថាជាបទល្មើសឡើយ ព្រោះថាការការពារក្តីមួយនេះជាសិទ្ធិដែលច្បាប់បានផ្តល់ឲ្យមេធាវីក្នុងការបំពេញកាតព្វកិច្ចរបស់ខ្លួនដើម្បីបម្រើផលប្រយោជន៍សាធារណៈ និងឯកជន។

#### ២.១.១.២. ការអនុវត្តជាក់ស្តែង

ក្នុងករណីដែលមានបទល្មើសជាក់ស្តែង ច្បាប់អនុញ្ញាតឲ្យប្រជាពលរដ្ឋអាចចាប់ខ្លួនជនល្មើសបាន។ ការចាប់ខ្លួនជនល្មើសដែលបានប្រព្រឹត្តបទល្មើសជាក់ស្តែង គឺមិនមែនជាបទល្មើសទេ។

ជាទូទៅច្បាប់បានកំណត់នូវនិទណ្ឌភាព ក្នុងករណីដែលភ្នាក់ងារនៃអាជ្ញាធរសារធារណៈបានប្រព្រឹត្តអំពើមួយស្ថិតក្នុងការបំពេញមុខងាររបស់ខ្លួន ដូចជាការចាប់ខ្លួនជនល្មើសស្របទៅតាមនីតិវិធីច្បាប់ការឆែកឆេរ ការចាប់យកវត្ថុតាងជាដើម។[13]

ជួនកាលទៀតវិធានសាសនាក៏ត្រូវបានគេលើកយកមកសំអាងធ្វើជាយុត្តកម្មនៃបទល្មើសដែរ។ ក្នុងករណីអាស្រ័យទៅលើយុត្តសាស្ត្ររបស់តុលាការនៃព្រះរាជាណាចក្រកម្ពុជា ថាតើគួរតែយកបញ្ញត្ត ឬការអនុញ្ញាតនៃវិធានសាសនាមកធ្វើជាយុត្តកម្មនៃបទល្មើសបានដែរឬទេ?

ឧទាហរណ៍៖ ការកាត់ស្បែកចុងអង្គជាតិរបស់មនុស្សប្រុសនៅក្នុងសាសនាឥស្លាម។ ផ្ទុយទៅវិញអត្ថិភាពនៃការអនុញ្ញាតផ្នែករដ្ឋបាល ពុំមែនជាយុត្តកម្មនៃបទល្មើសទេ។

ជារួមមកដើម្បីរួចផុតពីការទទួលខុសត្រូវព្រហ្មទណ្ឌ លុះត្រាតែបានបំពេញនូវគ្រប់លក្ខខណ្ឌដែលច្បាប់បានកំណត់។ ក្រៅពីមន្ត្រីដែលមានឈ្មោះក្នុងក្របខណ្ឌរដ្ឋ ច្បាប់ក៏បានផ្តល់សិទ្ធិជូនប្រជាពលរដ្ឋទូទៅក្នុងការបំពេញកាតព្វកិច្ចជូនច្បាប់ដែរ គ្រាន់តែថាសិទ្ធិនោះពុំមានវិសាលភាពធំធេងដូចគ្នាទៅនឹងមន្ត្រីក្នុងក្របខណ្ឌរដ្ឋនោះទេ។ ដូចការលើកឡើងនៅផ្នែកខាងលើដែរ ប្រជាពលរដ្ឋមានសិទ្ធិឃាត់ខ្លួនជនល្មើសដែលបានប្រព្រឹត្តបទល្មើសជាក់ស្តែងបាន ក្នុងករណីដែលភ្នាក់ងារប៉ូលីសមិនទាន់ទៅដល់កន្លែងកើតហេតុបានភ្លាមៗ ប៉ុន្តែប្រជាពលរដ្ឋពុំមានសិទ្ធិធ្វើទារុណកម្មអ្វីទាំងអស់ទៅលើជនល្មើសនោះឡើយ និយាយរួមមានសិទ្ធិតែឃាត់ទុក

13.ក្រមនីតិវិធីព្រហ្មទណ្ឌទូទៅ លោកមេធាវី ជូ សុភារ៉ា

នូវជនល្មើសដើម្បីរង់ចាំប្រគល់ទៅឲ្យភ្នាក់ងារប៉ូលីសតែប៉ុណ្ណោះ។

ឧទាហរណ៍៖ នារីពីរនាក់ជាអ្នកលក់ខោអាវក្នុងផ្សារកំពង់ស្ពឺបានឈ្លោះប្រកែកគ្នាពីរឿងមួយ ការឈ្លោះនោះបានឈានទៅដល់ការប្រើអំពើហិង្សាដាក់គ្នាទៅវិញទៅមក ឃើញដូច្នោះ បុរសម្នាក់ដែលជាអ្នកលក់ដូរក្នុងផ្សារមានតូបជាប់ៗគ្នានោះ បានចូលទៅធ្វើការរាំងឃាត់នារីទាំងពីររូបនោះ តែការរារាំងឃាត់របស់បុរសនោះ បានធ្វើឲ្យនារីម្នាក់ដួលបោកក្បាលនឹងជ្រុងតូប បណ្តាលឲ្យមានរបួសបែកក្បាលយ៉ាងធ្ងន់ធ្ងរ។ ក្នុងករណីនេះ ទោះបីជាបុរសនោះបានរាំងឃាត់ការប្រព្រឹត្តបទល្មើសក៏ពិតមែន ប៉ុន្តែអំពើរបស់គាត់បានធ្វើឲ្យគ្រោះថ្នាក់ដល់អ្នកដទៃដោយអចេតនា ហើយអំពើនោះលើសពីគោលការណ៍ដែលច្បាប់បានផ្តល់សិទ្ធិឲ្យ ដូច្នេះបុរសនោះចាំបាច់ត្រូវតែទទួលខុសត្រូវព្រហ្មទណ្ឌដដែល។

ជាអញ្ញត្រកម្ម ចំពោះអំពើដែលត្រូវបានចាត់ទុកថា ជាបទប្រល័យពូជសាសន៍ បទឧក្រិដ្ឋប្រឆាំងមនុស្សជាតិ ឬបទឧក្រិដ្ឋសង្គ្រាមចារី សហចារី អ្នកផ្តើមគំនិត ឬអ្នកសមគំនិតមិនអាចលើកលែងឲ្យរួចផុតពីការទទួលខុសត្រូវព្រហ្មទណ្ឌបានឡើយ ទោះបីជាបទល្មើសបានប្រព្រឹត្តអំពើដែលបានបញ្ញត្ត ឬអនុញ្ញាត ឬមិនហាមឃាតដោយច្បាប់ជាធរមានក៏ដោយ។

ឧទាហរណ៍៖ ទោះបីជាច្បាប់ដែលនៅជាធរមាននៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ អនុញ្ញាតឲ្យមានមនុស្សស្លាប់ដូចក្នុងសម័យនោះក្តី ក៏ជនទាំងឡាយណាដែលធ្វើតាមការអនុញ្ញាតដោយច្បាប់នេះនឹងមិនអាចឲ្យរួចផុតពីការទទួលខុសត្រូវព្រហ្មទណ្ឌបានឡើយ ដោយមានការលើកសំអាងពីការអនុញ្ញាតដោយច្បាប់នោះក៏ដោយ។

### ២.១.២. ការអនុញ្ញាតដោយអាជ្ញាធរ

**អាជ្ញាធរ៖** អ្នកទ្រទ្រង់អំណាច អ្នករាជការដែលកាន់អំណាច។

យោងតាមមាត្រា ៣២ កថាខណ្ឌទី ២ នៃក្រមព្រហ្មទណ្ឌថ្មីបានចែងថា៖ បុគ្គលណាដែលប្រព្រឹត្តអំពើតាមបញ្ជារបស់អាជ្ញាធរស្របច្បាប់ បុគ្គលនោះមិនប្រព្រឹត្តបទល្មើសទេ លើកលែងតែអំពើនោះជាអំពើខុសច្បាប់យ៉ាងជាក់ច្បាស់។ ទាញចេញពីបទបញ្ញត្តិនេះ ការអនុញ្ញាតដោយអាជ្ញាធរជាមូលហេតុនៃការមិនទទួលខុសត្រូវព្រហ្មទណ្ឌ លុះត្រាតែអាជ្ញាធរស្របច្បាប់ជាអ្នកចេញបញ្ជាស្របច្បាប់ ។[14]

#### ២.១.២.១. ការអនុញ្ញាតដោយអាជ្ញាធរស្របច្បាប់

អាជ្ញាធរស្របច្បាប់សំដៅលើអាជ្ញាធរសាធារណៈ ដែលអាចជាអាជ្ញាធររដ្ឋបាល អាជ្ញាធរតុលាការ ឬអាជ្ញាធរយោធា ដែលមានអំណាចតាមផ្លូវច្បាប់ក្នុងការបញ្ជាឲ្យអនុវត្តជាប់នឹងលិខិតបទដ្ឋានផ្សេងៗទៀត ។

ឧទាហរណ៍៖ ភ្នាក់ងារប៉ូលីសចរាចរណ៍ទទួលបានបង្គាប់ពីអាជ្ញាធរស្របច្បាប់ឲ្យប្រជាពលរដ្ឋបើកបរទាំងយានជំនិះ និងយានយន្តផ្អាកការធ្វើដំណើរចំនួន ០៥ នាទីនៅលើចញ្ចើមផ្លូវដើម្បីសម្រួលដល់ការដង្ហែរក្បួនរបស់ព្រះមហាក្សត្រ ដូច្នេះអំពើនេះមិនត្រូវបានចាត់ទុកថាជាបទល្មើសនោះទេ។

ហេតុនេះមិនត្រូវចាត់ទុកជាអាជ្ញាធរស្របច្បាប់តាមន័យនៃមាត្រា ៣២ នៃក្រមព្រហ្មទណ្ឌចំពោះ ៖

- និយោជកនៃក្រុមហ៊ុនមួយ (បញ្ជាឲ្យនិយោជិតធ្វើអ្វីមួយដែលខុសច្បាប់)

14.ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ ២០០៩, មាត្រា ៣២ កថាខណ្ឌទី២

- ឪពុកម្ដាយ (បញ្ជាកូនឲ្យធ្វើអ្វីមួយដែលផ្ទុយនឹងច្បាប់)។

### ២.១.២.២. ការបញ្ជាស្របច្បាប់

ក្រមព្រហ្មទណ្ឌមិនអនុញ្ញាតឲ្យជនណាម្នាក់ដែលប្រព្រឹត្តបទល្មើស តាមបញ្ជារបស់អាជ្ញាធរស្របច្បាប់រួចផុតពីការទទួលខុសត្រូវព្រហ្មទណ្ឌបានឡើយ ប្រសិនបើអំពើនោះជាអំពើខុសយ៉ាងជាក់ច្បាស់។ ចំពោះពាក្យថា អំពើខុសច្បាប់យ៉ាងជាក់ច្បាស់ ទាមទារឲ្យមានការវាយតម្លៃតាមករណីនីមួយៗ ដោយត្រូវពិនិត្យលើស្ថានភាពជាក់ស្ដែងរបស់អ្នកទទួលបញ្ជាដូចជា សមត្ថភាព បទពិសោធន៍ និងឋានៈជាដើម។ ដូច្នេះមន្ត្រីរាជការថ្នាក់ខ្ពស់មានសមត្ថភាពអាចធ្វើការវាយតម្លៃកំណត់ពីភាពស្របច្បាប់ ឬមិនស្របច្បាប់នៃបញ្ជាណាមួយរបស់ថ្នាក់លើខ្លួនជាមន្ត្រីធម្មតា ឬជនសាមញ្ញដែលអាជ្ញាធរបញ្ជាឲ្យធ្វើអ្វីមួយ។

ការប្រើពាក្យថា អំពើខុសច្បាប់យ៉ាងជាក់ច្បាស់ឲ្យសន្និដ្ឋានបានថា ប្រសិនបើអំពើដែលបានប្រព្រឹត្តគ្រាន់តែជាអំពើខុសច្បាប់ ប៉ុន្តែមិនមែនជាអំពើខុសច្បាប់យ៉ាងជាក់ច្បាស់នោះទេ អ្នកទទួលបញ្ជាអាចរួចផុតពីការទទួលខុសត្រូវព្រហ្មទណ្ឌបានដោយផ្អែកលើមាត្រា ៣២ នៃក្រមព្រហ្មទណ្ឌ។

ឧទាហរណ៍៖ ជនម្នាក់បានប្រព្រឹត្តបទល្មើសលួចដែលមានស្ថានទម្ងន់ទោស ត្រូវបានឃាត់ខ្លួនដោយភ្នាក់ងារប៉ូលីសប្រចាំការនៅតំបន់ដែលបានប្រព្រឹត្តបទល្មើសលួចនោះ បន្ទាប់មកភ្នាក់ងារប៉ូលីសបានបញ្ជូនទៅឲ្យមន្ត្រីនគរបាលយុត្តិធម៌ មន្ត្រីនគរបាលយុត្តិធម៌បានបញ្ជាឲ្យភ្នាក់ងារប៉ូលីសជាមន្ត្រីថ្នាក់ក្រោមរបស់ខ្លួនធ្វើទារុណកម្មទៅលើជនល្មើសនោះយ៉ាងរណ្ដំក្នុងពេលសួរចម្លើយ។ អំពើនេះ ចំពោះមន្ត្រីនគរបាលយុត្តិធម៌ត្រូវបានចាត់ទុកថាជាអំពើខុសច្បាប់យ៉ាងជាក់ច្បាស់ ចំណែកឯភ្នាក់ងារប៉ូលីសមិនត្រូវឲ្យទទួលខុសត្រូវព្រហ្មទណ្ឌឡើយដោយផ្អែកតាមមាត្រា ៣២ នៃក្រមព្រហ្មទណ្ឌ។

ឧទាហរណ៍៖ មន្ត្រីប៉ូលីសចរាចរណ៍មួយក្រុមបានបញ្ជាឲ្យអ្នកបើករថយន្តធន់ធ្ងន់ម្នាក់ សណ្ដោងរថយន្តដែលចតខុសច្បាប់ចរាចរណ៍ចេញទៅ។ ក្នុងករណីនេះអ្នកបើករថយន្តមិនត្រូវបានចោទប្រកាន់ពីបទលួចមានស្ថានទម្ងន់ទោសបានឡើយ។

ម្យ៉ាងវិញទៀតកាលបើអំពើប្រព្រឹត្តត្រូវបានចាត់ចូលជាបទប្រល័យពូជសាសន៍ បទឧក្រិដ្ឋប្រឆាំងនឹងមនុស្សជាតិ ឬបទឧក្រិដ្ឋសង្គ្រាម ក្រមព្រហ្មទណ្ឌមិនអនុញ្ញាតឲ្យផុតពីការទទួលខុសត្រូវព្រហ្មទណ្ឌដោយសំអាងទៅលើការបញ្ជារបស់អាជ្ញាធរស្របច្បាប់បានឡើយ។ [15]

## ២.២.ការការពារស្របច្បាប់

ក្នុងករណីដែលចារីបានប្រព្រឹត្តបទល្មើសទាំងឡាយណាដោយមានបំណងគ្រាន់តែចង់ការពារខ្លួន ការពារអ្នកដទៃ ឬទ្រព្យសម្បត្តិប្រឈមនឹងការឈ្លានពានណាមួយដែលមិនត្រឹមត្រូវ មិនតម្រូវឲ្យទទួលខុសត្រូវព្រហ្មទណ្ឌឡើយ។

ការការពារខ្លួនទប់ទល់នឹងការឈ្លានពានណាមួយដែលមិនត្រឹមត្រូវ គឺជាសិទ្ធិមួយដែលច្បាប់បាន

១៥. មាត្រា ៣២ កថាខណ្ឌទី ៣

បញ្ញត្តឡើង គឺទុកសម្រាប់ផ្តល់ជូនប្រជាពលរដ្ឋក្នុងការអនុវត្ត ក្នុងករណីចាំបាច់ណាមួយដែលបានកើតឡើង។ ច្បាប់មិនដាក់ទណ្ឌកម្មទៅលើបុគ្គលទាំងឡាយណា ដែលបានប្រព្រឹត្តបទល្មើសគោរពតាមលក្ខខណ្ឌច្បាប់ទេ ករណីបុគ្គលដែលបានប្រព្រឹត្តបទល្មើសដែលលើសពីលក្ខខណ្ឌច្បាប់បញ្ញត្តទុកជាមុន នៅតែទទួលខុសត្រូវដដែល។

ដោយអនុលោមតាមមាត្រា ៣៣ កថាខណ្ឌទី ២ នៃក្រមព្រហ្មទណ្ឌ មិនអាចអនុញ្ញាតឲ្យបុគ្គលណាប្រព្រឹត្តបទល្មើសក្នុងស្ថានភាពការពារស្របច្បាប់ទទួលខុសត្រូវព្រហ្មទណ្ឌឡើយ។

មាត្រា ៣៣ កថាខណ្ឌទី ១ បានកំណត់ពីលក្ខខណ្ឌនៃការការពារស្របច្បាប់ថា ៖

- បទល្មើសត្រូវចាត់ទុកថា ត្រឹមត្រូវដោយការចាំបាច់ដើម្បីការពារខ្លួន ការពារអ្នកដទៃ ឬការពារទ្រព្យសម្បត្តិប្រឈមនឹងការឈ្លានពានណាមួយដែលមិនត្រឹមត្រូវ។
- បទល្មើស និងការឈ្លានពានត្រូវតែកើតឡើងក្នុងពេលជាមួយគ្នា។
- និងគ្មានវិសមាមាត្រ រវាងមធ្យោបាយការពារដែលប្រើប្រាស់ និងទម្ងន់នៃការឈ្លានពាន។[16]

ឧទាហរណ៍៖ អ្នកបម្រើម្នាក់ត្រូវបានគេជួលឲ្យមកមើលថែផ្ទះ ថ្ងៃមួយស្រាប់តែមានចោរពីរនាក់បានលួចចូលក្នុងផ្ទះ និងកំពុងតែធ្វើសកម្មភាពលួចរបស់មានតម្លៃមួយចំនួននៅក្នុងផ្ទះរបស់ម្ចាស់ផ្ទះខ្លួន ឃើញដូច្នេះ អ្នកបម្រើនោះបានទាញយកកាំបិតចិតផ្លែឈើដែលនៅក្បែរនោះចាក់ទៅលើចោរនោះបណ្តាលឲ្យចោរនោះរងរបួសធ្ងន់។ ក្នុងករណីនេះ អ្នកបម្រើនោះមិនតម្រូវឲ្យទទួលខុសត្រូវព្រហ្មទណ្ឌទេ ដោយហេតុថា អ្នកបម្រើនោះប្រព្រឹត្តបទល្មើសដើម្បីការពារខ្លួន និងទ្រព្យសម្បត្តិកំពុងរងការឈ្លានពានដែលមិនត្រឹមត្រូវ។

អាស្រ័យហេតុនេះ ដើម្បីឲ្យរួចផុតពីការទទួលខុសត្រូវព្រហ្មទណ្ឌ ដោយផ្អែកលើការការពារស្របច្បាប់ ជនដែលបានប្រព្រឹត្តបទល្មើសត្រូវតែបង្ហាញឲ្យឃើញអំពីលក្ខខណ្ឌនៃការការពារស្របច្បាប់ ដែលបានកំណត់ក្នុងក្រមព្រហ្មទណ្ឌតាមរយៈភស្តុតាងផ្សេងៗ។

### ២.២.១. លក្ខខណ្ឌនៃការការពារស្របច្បាប់

ការការពារស្របច្បាប់ គឺជាអំពើតបតទៅនឹងឈ្លានពានណាមួយ ដោយការឈ្លានពាននោះគឺជាអំពើឈ្លានពានដែលមិនត្រឹមត្រូវ រាល់អំពើដែលឈ្លានពានដោយមិនត្រឹមត្រូវនោះ លុះត្រាតែវាមិនគ្រប់លក្ខខណ្ឌរបស់វា។ យ៉ាងណាមិញការតបតរបស់យើងទៅលើអំពើនោះគឺមានគោលបំណងក្នុងការការពារខ្លួន ការពារអ្នកដទៃក៏ដូចជាការការពារទ្រព្យសម្បត្តិជាដើម។ ការតបតទៅនឹងការឈ្លានពានដែលកើតឡើង ដោយសារស្ថានភាពមួយដែលតម្រូវឲ្យចាំបាច់ក្នុងការតបត ក្នុងស្ថានភាពដែលបុគ្គលនោះអាចជួបគ្រោះថ្នាក់បំផុត ប្រសិនបើមិនមានការតបតវានឹងអាចឈានទៅដល់ការប៉ះពាល់ដល់បូរណភាពរូបរាង្គកាយ ក៏ដូចជាការខូចខាតទ្រព្យសម្បត្តិ ឬអាចហួតឈានដល់បាត់បង់អាយុជីវិតថែមទៀតផង ដែលករណីទាំងនេះមិនអាចជួសជុល ឬធ្វើឲ្យដូចដើមបានទេ។ ដូច្នេះនៅក្នុងច្បាប់បានកំណត់ថា អំពើដែលបុគ្គលបានតបតក្នុងគោលបំណងការពារខ្លួន នោះគឺមិនត្រូវបានទទួលខុសត្រូវព្រហ្មទណ្ឌឡើយ។

15.ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ ២០០៩, មាត្រា ៣៣

### ២.២.១.១. ការការពារត្រូវតែចាំបាច់

ការការពារត្រូវតែចាំបាច់ សម្រាប់ស្រោចស្រង់ប្រយោជន៍ដែលត្រូវបានគេគំរាមកំហែង មានន័យថា ការការពារត្រូវតែជាការចាំបាច់ដើម្បីការពារខ្លួន ការពារអ្នកដទៃ ឬការពារទ្រព្យសម្បត្តិដែលកំពុងរងការឈ្លានពានមិនត្រឹមត្រូវ។ និយាយម្យ៉ាងទៀតថាជាប្រតិកម្មតបតរបស់អ្នកការពារ គឺមធ្យោបាយតែមួយគត់គឺបញ្ចៀសពីការឈ្លានពាន។

ស្ថិតនៅក្នុងបរិបទនេះ ភាពបន្ទាន់នៃគ្រោះថ្នាក់ គឺជាឧបសគ្គមួយដែលបានធ្វើឲ្យជនរងគ្រោះអាចប្រើប្រាស់មធ្យោបាយផ្សេងៗទៀតបាន ក្រៅតែពីការប្រព្រឹត្តបទល្មើសតបតទៅអ្នកឈ្លានពាន ដូចជាការប្តឹងទៅអាជ្ញាធរមានសមត្ថកិច្ច ឬក៏រត់គេចខ្លួនជាដើម។

ឧទាហរណ៍៖ ក្រោយពីរត់គេចផុតពីការឈ្លានពានម្តងហើយលោក (ក) បានទៅយកកាំភ្លើងនៅផ្ទះរបស់ខ្លួនហើយបាញ់ទៅលើលោក (ខ) ដែលជាអ្នកឈ្លានពានទៅលើខ្លួន បណ្តាលឲ្យស្លាប់ភ្លាមៗនៅនឹងកន្លែងកើតហេតុ ក្នុងករណីបែបនេះអំពើរបស់លោក ( ក ) មិនមែនជាការចាំបាច់សម្រាប់ការការពារស្របច្បាប់ទេ។

### ២.២.១.២. បទល្មើស និងការឈ្លានពានត្រូវតែកើតមានក្នុងពេលជាមួយគ្នា

ការការពារត្រូវតែកើតឡើងក្នុងពេលជាមួយគ្នានឹងការឈ្លានពាន មានន័យថា ការការពារត្រូវតែធ្វើភ្លាមៗ ក្នុងខណៈដែលការឈ្លានពានបានកើតឡើង ប្រសិនបើការឈ្លានពានបានបញ្ចប់ទៅវិញហើយទើបធ្វើការតបតជាក្រោយ នោះវាជាការសងសឹកទៅវិញទេ។ ក្នុងករណីដែលនាំឲ្យមានការការពារជាធម្មានុរូបនៅក្នុងចំណុចនេះ គឺចាំបាច់ទាល់តែការឈ្លានពាននោះកើតឡើងពិតប្រាកដ និងកំពុងកើតឡើងជាក់ស្តែងពីការបំពាន។ មានន័យថា ការឈ្លានពាន ឬគ្រោះថ្នាក់ចំពោះប្រយោជន៍ដែលច្បាប់បានការពារនោះ ត្រូវតែស្ថិតនៅជាសត្យានុម័តពោលគឺពុំមែនស្ថិតនៅក្នុងអារម្មណ៍ជាការគិតស្មាន ឬគំនិតថានឹងមានគេបំពាននោះឡើយ។ ប្រសិនជាការតបតនោះប្រព្រឹត្តឡើងក្នុងពេលតែមួយ និយាយជារួមការតបតនោះប្រព្រឹត្តិនៅក្នុងអំឡុងពេលដែលច្បាប់បានអនុញ្ញាតឲ្យតបតក្នុងបំណងការពារខ្លួន នោះអំពើដែលតបតនោះ ច្បាប់នឹងទទួលស្គាល់ថាគ្មានទោសឡើយ។

ពួកយើងនឹងធ្វើការបញ្ជាក់បន្ថែមនូវចំណុចខាងក្រោមនេះអំពីការការពារធម្មានុរូបទៅលើការឈ្លានពានដែលមិនត្រឹមត្រូវនេះ៖

- ការតបតមិនអាចកើតឡើងក្រោយការឈ្លានពានត្រូវបានបញ្ចប់ឡើយ។ វាមិនត្រូវបានចាត់ទុកជាការការពារស្របច្បាប់នោះឡើយ ពីព្រោះតាមទ្រឹស្តីវានឹងក្លាយទៅជាការសងសឹក ដោយសារតែការការពារហួសពេលកំណត់។

  ឧទាហរណ៍៖ លោក (ក) បានកាន់កាំបិតបម្រុងទៅចាក់លើលោក (ខ) ប៉ុន្តែមិនទាន់បានចាក់ផងលោក (ខ) បានរត់គេចផុតទៅផ្ទះរបស់ខ្លួន។ រយៈពេល ៣ ម៉ោងក្រោយមកលោក (ខ) បានកាន់កាំបិតបម្រុងចាក់ទៅលើលោក (ក) វិញ ដោយសំអាងថាជាការការពារស្របច្បាប់ ដោយសារតែការការពារកើតឡើង ៣ ម៉ោងក្រោយមានការឈ្លានពានហើយលោក (ខ) ក៏បានរត់គេចខ្លួនផុតដែរ។ ដូច្នេះវាជាការសងសឹកទៅវិញ ឬជាការការពារហួសពេលកំណត់។

- ការតបតមិនអាចធ្វើមុនពេលមានអំពើនៃការឈ្លានពានបានដែរ ព្រោះប្រសិនបើការឈ្លានពានពុំទាន់បានឃើញជាក់ស្តែងនោះទេ ឬគ្រាន់តែអាចកើតមានឡើងក្នុងពេលខាងមុខប៉ុណ្ណោះ ហើយការឈ្លានពាននោះ ត្រូវបានកម្រិតត្រឹមត្រូវតែជាការគំរាមកំហែងថានឹងឈ្លានពានដល់ទ្រព្យសម្បត្តិ ឬរូបកាយ នោះមិនអាចចាត់ទុកថាជាការតបតដែលមានលក្ខណៈតបតបានឡើយ ហើយក៏មិនអាចចាត់ទុកថាជាការការពារស្របច្បាប់បានដែរ។
  ឧទាហរណ៍៖ លោក ខ ស្មានថា លោក ក កាន់កាំបិតបម្រុងនឹងចាក់មកលើខ្លួន ក៏ស្ទុះទៅវាយចំកមួយដៃ បណ្តាលឲ្យលោក ក ដួលសន្លប់ភ្លាមៗនៅកន្លែងកើតហេតុតែម្តង តែតាមការពិតលោក ក កាន់កាំបិតបម្រុងនឹងទៅចម្ការទេ។ លោក ខ មិនអាចអះអាងថា ទង្វើរបស់ខ្លួនជាការការពារនោះទេ ព្រោះពុំទាន់ស្តែងចេញនូវការឈ្លានពាននៅឡើយទេ វាគ្រាន់តែជាការស្មានរបស់លោក ខ តែប៉ុណ្ណោះ។ លោក ខ ទេដែលជាអ្នកប្រព្រឹត្តបទល្មើស (អំពើបំពានច្បាប់)។[17]

ដូច្នេះការការពារស្របច្បាប់ចាំបាច់ត្រូវតែកើតឡើងស្របគ្នាជាមួយនឹងការការឈ្លានពាន គឺមិនត្រូវឲ្យឃ្លាតដាច់ចេញពីគ្នាឡើយមានន័យថា សកម្មភាពនៃការការពារត្រូវតែធ្វើឡើងនៅក្នុងពេលតែមួយនឹងការឈ្លានពាន។ និយាយជារួមអំពើឈ្លានពានត្រូវបានបញ្ចប់ ឬគ្រោះថ្នាក់ត្រូវបានបញ្ចប់ នោះសិទ្ធិនៃការការពារស្របច្បាប់ក៏ត្រូវបានរលត់តាមហ្នឹងដែរ។ រីឯការការពារខ្លួនយឺតយ៉ាវក៏អាចបង្កើតបានជាការការពារខ្លួនដែលទទួលស្គាល់ដោយច្បាប់បានដែរ។[18]

### ២.២.១.៣. ភាពគ្មានវិសមាមាត្ររវាងមធ្យោបាយការពារនិងទម្ងន់នៃការឈ្លានពាន

មធ្យោបាយការពារដែលប្រើប្រាស់ត្រូវតែឆ្លើយតបទៅនឹងភាពធ្ងន់ធ្ងរនៃការឈ្លានពានដែលមិនត្រឹមត្រូវ។ ការវាយតម្លៃអំពីវិសមាមាត្រនៃមធ្យោបាយការពារ និងទម្ងន់នៃការឈ្លានពាន គឺអាស្រ័យទៅតាមករណីនីមួយៗ ដូចជាកាលៈទេសៈបុគ្គលិកលក្ខណៈរបស់អ្នកទទួលរងនូវការឈ្លានពានជាដើម។ ការការពារត្រូវតែធ្វើឡើងឲ្យមានលក្ខណៈស្របគ្នាទៅនឹងច្បាប់បានកំណត់ គឺមានន័យថាការឈ្លានពានគឺត្រូវតែសមាមាត្រជាមួយនឹងអំពើដែលគេបានឈ្លានពានដោយត្រូវពិនិត្យលើទំហំគ្រោះថ្នាក់ និងចរិតលក្ខណៈនៃការឈ្លានពាននោះ។ តែប្រសិនបើមានភាពវិសមាមាត្ររវាងទម្ងន់នៃការឈ្លានពាន និងមធ្យោបាយនៃការការពារនោះគឺវាមិនមែនជាមូលហេតុត្រឹមត្រូវ ឬជាការការពារដោយច្បាប់មិនឲ្យរួចផុតពីការទទួលខុសត្រូវបានឡើយ។[19]

ឧទាហរណ៍៖ លោក ក បានកាន់កូនកាំបិតនៅនឹងដៃបម្រុងឆ្លោះទៅប្លន់យកទូរស័ព្ទដៃថ្មីទំនើបរបស់លោក ខ លោក ខ ឃើញដូច្នោះក៏ស្រវ៉ាយកដុំថ្មដែលនៅជិតខ្លួនទៅវាយលើលោក ក បណ្តាលឲ្យស្លាប់ភ្លាមៗ។ ដូច្នេះទង្វើដែលលោក ខ បានធ្វើគឺមិនអាចចាត់ទុកជាការការពារស្របច្បាប់បានឡើយដោយសារតែមធ្យោបាយនៃការការពារ គឺគ្មានវិសមាមាត្រជាមួយនឹងទម្ងន់នៃការឈ្លានពានឡើយ។

16. សារណាបញ្ចប់ការសិក្សារបស់លោកគ្រូ សុធា រស្មី និង អៀង វណ្ណៈ ឆ្នាំ ២០១៦

17. ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ ២០០៩, មាត្រា ៣៣ ផ្នែកទី២

18. ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ ២០០៩, មាត្រា ៣៣ ផ្នែកទី៣

ហេតុដូច្នេះប្រសិនបើគ្រាន់តែមានគោលដៅការពារទ្រព្យសម្បត្តិតែប៉ុណ្ណោះ អ្នកការពារមិនអាចការពារខ្លួនរហូតទៅដល់សម្លាប់អ្នកឈ្លានពានទេ មានន័យថា តម្លៃនៃទ្រព្យសម្បត្តិគ្មានវិសមាមាត្រ ឬប្រៀបផ្ទឹមនឹងជីវិតមនុស្សបានឡើយ។ តែបើការឈ្លានពាននោះលើសព្រំដែនដែលអាចនឹងបង្កឲ្យជនរងគ្រោះស្លាប់បាត់បង់ជីវិតជនរងគ្រោះនោះអាចមានសិទ្ធិតបតវិញបាន។

ឧទាហរណ៍៖ ដើម្បីទប់ស្កាត់នឹងបុរសម្នាក់ដែលបានចាប់ និងបង្ខាំងលើស្ត្រីម្នាក់ ព្រមទាំងមានបំណងរំលោភសេពសន្ថវៈលើរូបនាង ហើយគំរាមថានឹងសម្លាប់រូបនាងថែមទៀត នារីរងគ្រោះក៏ស្រវាយកកាំបិតដែលមានចុងស្រួចនៅជិត ហើយបន្ទាប់មកនាងក៏បានយកកាំបិតនោះទៅចាក់លើបុរសដែលកំពុងតែធ្វើសកម្មភាពឈ្លានពានលើផ្លូវភេទរបស់នាង (សង្កត់លើរូបនាង បម្រុងនឹងធ្វើសកម្មភាពរំលោភសេពសន្ថវៈ) បណ្តាលឲ្យបុរសនោះស្លាប់ភ្លាមៗនៅនឹងកន្លែងកើតហេតុនោះ។ នៅក្នុងករណីនេះផងដែរ គួរតែចាត់ទុកថា អំពើរបស់នារីរងគ្រោះគឺសមាមាត្រជាមួយនឹងទម្ងន់នៃការឈ្លានពាន។ ពោលគឺច្បាប់បានការពារនារីនោះមិនឲ្យមានការទទួលខុសត្រូវព្រហ្មទណ្ឌ ដោយសារតែអំពើសម្លាប់ទៅលើអ្នកឈ្លានពានលើរូបនាង។

### ២.២.២. លក្ខណៈក្នុងការការពារស្របច្បាប់

ច្បាប់បានចែងឡើងដើម្បីការពារជនរងគ្រោះពីអំពើឈ្លានពាន និងអំពើណាដែលមិនគប្បីនៅក្នុងសង្គមក្នុងគោលបំណងដើម្បីឲ្យមានសន្តិសុខសណ្តាប់ធ្នាប់ សន្តិភាព និងសោភ័ណភាពនៅក្នុងសហគមន៍ សង្គម និងប្រទេសជាតិ ឬក៏រដ្ឋទាំងមូល។ ច្បាប់ក៏បានអនុញ្ញាតឲ្យបុគ្គលដែលត្រូវបានគេឈ្លានពាន ឬធ្វើបាប (អំពើដែលមិនគប្បី បៀតបៀន) មកលើខ្លួន បុគ្គលដែលត្រូវបានគេឈ្លានពាននោះអាចមានសិទ្ធិក្នុងការតបតបាន ហើយការតបតនោះទៀតសោតដោយរួមបានទាំងការវាយបក ការប្រើប្រាស់អាវុធ ឬឧបករណ៍ណាដែលអាចការពារខ្លួនបាន។ ជាទូទៅការតបតនេះគឺជាស្ថានភាពមួយដែលតម្រូវឲ្យមានការចាំបាច់ក្នុងការតបតនៅក្នុងស្ថានភាពដែលគ្រោះថ្នាក់បំផុត យ៉ាងណាមិញប្រសិនបើមិនមានការតបតទេនោះ អន្តរាយនៃបទល្មើសអាចប៉ះពាល់ទៅដល់ការស្លាប់បាត់បង់អាយុជីវិត អាចឈានទៅដល់បូរណភាពរូបរាង្គកាយក៏ដូចជាបាត់បង់ទ្រព្យសម្បត្តិ ឬខូចខាតវត្ថុដែលមានតម្លៃជាដើម។ នៅក្នុងក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា មាត្រា ៣៣ វាក្យខណ្ឌទី១ បានបញ្ញត្តថា **បទល្មើសត្រូវចាត់ទុកថាត្រឹមត្រូវដោយការចាំបាច់ដើម្បីការការពារខ្លួន ការពារអ្នកដទៃ ឬការពារទ្រព្យសម្បត្តិប្រឈមមុខនឹងការឈ្លានពានមួយដែលមិនត្រឹមត្រូវ។**

ដូច្នេះដើម្បីឲ្យមានការយល់ដឹងកាន់តែច្បាស់នូវមាត្រាដែលបានលើកឡើងខាងលើ យើងខ្ញុំសូមធ្វើការបកស្រាយបន្ថែមនូវគ្រង់ចំណុច ការការពារខ្លួន ការការពារអ្នកដទៃ និងការការពារទ្រព្យសម្បត្តិប្រឈមនឹងការឈ្លានពានដូចខាងក្រោមនេះ៖

#### ២.២.២.១. ការការពារខ្លួន

ការការពារស្របច្បាប់គឺជាសិទ្ធិមួយដែលក្រមព្រហ្មទណ្ឌ ក៏ដូចជារដ្ឋបានផ្តល់ឲ្យប្រជាពលរដ្ឋអាចធ្វើសកម្មភាពសំដៅដល់ការការពារផលប្រយោជន៍របស់រដ្ឋ សង្គម ឬផលប្រយោជន៍របស់បុគ្គល។ ការការពារខ្លួននោះគឺតម្រូវឲ្យមានសមាមាត្រទៅនឹងការឈ្លានពាន គឺមានន័យថាមិនត្រូវតបតវិញលើសពីទម្ងន់នៃការឈ្លាន

ពាននោះឡើយ ដោយគ្រាន់តែបុគ្គលម្នាក់មានការប៉ងលួចយកទូរស័ព្ទដៃតែប៉ុណ្ណោះ តែបែរជាទៅយកកាំបិតទៅចាក់សម្លាប់គេឲ្យស្លាប់ (ទ្រព្យសម្បត្តិមិនអាចស្មើនឹងអាយុជីវិតមនុស្សម្នាក់បានឡើយ) ដូច្នេះអំពើនេះគឺវាគ្មានភាពវិសមាមាត្រនឹងទម្ងន់នៃការឈ្លានពានទេ ហើយវាមិនមែនជាការការពារខ្លួនដោយស្របច្បាប់ទៀតផង។

ឧទាហរណ៍៖ នៅពេលមានបុរសម្នាក់មានមាឌធំដើរសំដៅទៅឆក់កាបូបរបស់នារីម្នាក់ដែលមានមាឌតូចជាង ក្នុងហេតុការណ៍នោះនារីម្នាក់នោះក៏បានយកកាបូបរបស់ខ្លួន ដែលមានសភាពធ្ងន់ដោយផ្ទុកទៅដោយទូរស័ព្ទ និងឆ្នាំងសាកទូរស័ព្ទទៅវាយលើបុរសនោះភ្លាមៗបណ្តាលឲ្យរងរបួស។

ដូច្នេះអំពើតបតដែលនារីនោះបានវាយ ទៅបុរសនោះគឺមិនតម្រូវឲ្យមានការទទួលខុសត្រូវព្រហ្មទណ្ឌឡើយ គឺព្រោះតែនាងបានសម្រេចចិត្តប្រព្រឹត្តអំពើនោះ ដោយសារតែមានបំណងចង់ការពារខ្លួនតែប៉ុណ្ណោះ ប្រសិនបើមិនមានការតបតទេនោះ នឹងអាចបណ្តាលឲ្យនារីនោះរងរបួស ឬអាចនឹងបាត់បង់វត្ថុដែលមានតម្លៃនៅក្នុងកាបូបរបស់នាងទៀតផង។[20]

**២.២.២.២. ការការពារអ្នកដទៃ**

ក្នុងច្បាប់គឺមិនមែនមានតែព្រំដែនក្នុងការពារខ្លួនឯងតែប៉ុណ្ណោះទេ តែលើសពីនេះទៅទៀតច្បាប់ក៏បានអនុញ្ញាតឲ្យមានការការពារអ្នកដទៃផងដែរ។ នៅពេលដែលយើងឃើញជនរងគ្រោះម្នាក់ត្រូវបានតតិយជនធ្វើសកម្មភាពដូចជា មានការឈ្លានពាន វាយដំ ឬបៀតបៀនណាមួយ ដែលផ្ទុយទៅនឹងច្បាប់បានចែងនៅតាមទីសារធារណៈ យើងអាចមានសិទ្ធិហាមឃាត់តតិយជននោះពីអំពើដែលមិនស្របច្បាប់នោះបាន ហើយនៅក្នុងករណីដែលជនល្មើសនោះមិនព្រមស្តាប់ទៀត យើងអាចមានសិទ្ធិទាញគាត់ចេញ ឬរុញច្រានគាត់ដើម្បីបញ្ឈប់គាត់អំពីអំពើប្រព្រឹត្តបទល្មើសនោះបាន។

ឧទាហរណ៍៖ លោក ក បានកំពុងដើរហាត់ប្រាណនៅតាម សួនសារធារណៈមួយកន្លែងដែលមានសភាពស្ងាត់ស្រាប់តែឃើញមានបុរស ខ ម្នាក់កំពុងតែបៀតបៀនកេរ្ត៍ខ្មាសនារីវ័យក្មេងម្នាក់ ដោយសារនារីជាជនរងគ្រោះនោះមានភាពទន់ខ្សោយ គ្មានកម្លាំងគ្រប់គ្រាន់មិនអាចតបតនឹងបុរស ខ ម្នាក់នោះបាន ក៏សម្រេចចិត្តស្រែកឲ្យគេជួយ។ លោក ក ឃើញដូច្នោះក៏រត់សំដៅទៅបុរស ខ នោះក្នុងគោលបំណងឃាត់មិនឲ្យប្រព្រឹត្តអំពើបែបនេះទៀត តែបុរស ខ មិនព្រមស្តាប់ លោក ក ក៏បានសម្រេចចិត្តរុញបុរស ខ នោះបណ្តាលឲ្យរងរបួសរលាត់ស្បែកជង្គង់ ហើយបុរស ខ នោះក៏បានរត់គេចបាត់ទៅ។ ក្នុងអង្គហេតុនេះលោក ក មិនត្រូវទទួលខុសត្រូវ ឬទទួលទណ្ឌកម្មពីច្បាប់ឡើយ ព្រោះថាទង្វើដែលគាត់បានប្រព្រឹត្តគឺមានគោលបំណងការពារអ្នកដទៃ (នារីវ័យក្មេងរងគ្រោះ) តែប៉ុណ្ណោះ តែប្រសិនបើគាត់មិនបានហាមឃាត់ពីអំពើនោះទេ គឺអាចបណ្តាលឲ្យនារីវ័យក្មេងនោះឈានទៅដល់ការចាប់រំលោភ ឬរងរបួសផ្សេងៗ ដោយសារតែទង្វើរបស់បុរស ខ នោះបាន។[21]

19. ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ ២០០៩, មាត្រា ៣៣ ផ្នែកទី១

២០. ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ ២០០៩, មាត្រា ៣៣ ផ្នែកទី១

### ២.២.២.៣. ការការពារទ្រព្យសម្បត្តិ

យោងតាមមាត្រា ៣៣ ផ្នែកទី ១ បានចែងថា៖ **បទល្មើសត្រូវបានចាត់ទុកថាត្រឹមត្រូវដើម្បីការពារខ្លួន ការពារអ្នកដទៃ ឬទ្រព្យសម្បត្តិប្រឈមមុខនឹងការឈ្លានពានមួយដែលមិនត្រឹមត្រូវ។**

ដើម្បីបញ្ចៀសពីការបាត់បង់ទ្រព្យសម្បត្តិទាំងឯកជន ឬសាធារណៈដែលទ្រព្យសម្បត្តិទាំងនោះគឺប្រឈមមុខនឹងការឈ្លានពានណាមួយដែលមិនត្រឹមត្រូវ បណ្ដាលឲ្យមានការបាត់បង់ ឬខូចខាតជាដើម។

នៅក្នុងក្រមព្រហ្មទណ្ឌកម្ពុជា ក៏បានបញ្ញត្តឡើងដើម្បីការពារទ្រព្យសម្បត្តិដែលប្រឈមនឹងការឈ្លានពានផងដែរ។ ករណីមានជនណាម្នាក់មកឈ្លានពានលើទ្រព្យសម្បត្តិណាមួយទាំងឯកជន និងសាធារណៈនោះចារីអាចមានសិទ្ធិការពារបាន តែការការពារនោះគឺមិនត្រូវលើសពីព្រំដែនដែលច្បាប់បានបញ្ញត្តឲ្យឡើយ។ ពោលគឺមិនត្រូវដល់ថ្នាក់សម្លាប់បានទេ ព្រោះវត្ថុ ឬទ្រព្យសម្បត្តិមិនមានតម្លៃស្មើនឹងអាយុជីវិតមនុស្សម្នាក់បានទេ ដូច្នេះប្រសិនបើនៅក្នុងករណីដែលមានការឈ្លានពានណាមួយ យើងអាចមានសិទ្ធិត្រឹមតែបណ្ដេញចេញ ចាប់ឃាត់ខ្លួន ឬប្ដឹងទៅសមត្ថកិច្ច។ល។

ឧទាហរណ៍៖ លោក ក បានឃើញលោក ខ ដើរលបៗសំដៅមានបំណងទៅលួចស្បែកជើងថ្មីដែលលោក ក ទើបតែទិញ។ លោក ក ឃើញដូច្នោះខ្លួនក៏បានទាញឈើជ្រុងមួយវាយចំកញ្ចឹងកលោក ខ បណ្ដាលឲ្យរងរបួសធ្ងន់។ អំពើដែលលោក ក បានធ្វើទៅលើលោក ខ ដើម្បីទប់ទល់នឹងការលួចមួយនេះហួសដែនកំណត់នៃកម្លាំងនៃការឈ្លានពាន ហើយម្យ៉ាងវិញទៀតអំពើដែលលោក ក បានប្រព្រឹត្តនោះអាចបណ្ដាលឲ្យលោក ខ ស្លាប់បាន។ ទ្រព្យសម្បត្តិមិនអាចប្រៀបនឹងអាយុជីវិតមនុស្សបានទេ ទ្រព្យសម្បត្តិអាចរកវិញបានតាមក្រោយ ប៉ុន្តែជីវិតមនុស្សគ្មានអ្វីយកមកជួសបានឡើយ។ ដូច្នេះសរុបមកវិញទង្វើរបស់លោក ក ដែលបានធ្វើដើម្បីការពារទ្រព្យសម្បត្តិរបស់ខ្លួនគឺគាត់ត្រូវប្រឈមមុខនឹងច្បាប់។

ការការពារទ្រព្យសម្បត្តិ គឺជាកាតព្វកិច្ចចាំបាច់គួរតែត្រូវធ្វើដើម្បីទប់ទល់នឹងការឈ្លានពានរក្សាការពារនូវទ្រព្យឲ្យបានគង់វង្ស តែប្រសិនបើការការពារនោះលើសកម្រិតនៃការឈ្លានពានទៅទៀតនោះ បុគ្គលនោះនឹងត្រូវប្រឈមមុខនឹងច្បាប់ជាក់ជាពុំខាន។ ប្រសិនបើនៅក្នុងករណីមិនអាចគេចបាន យើងត្រូវប្រព្រឹត្តតបតវិញ ហើយប្ដឹងទៅសមត្ថកិច្ចជាដើម។[22]

## ២.៣. សច្ចធារណ៍នៃការការពារស្របច្បាប់

សច្ចធារណ៍ គឺជាការសរុបសេចក្ដីមួយ ឬសេចក្ដីសន្និដ្ឋានមួយដែលទាញចេញពីការយល់ដឹង ភស្តុតាង ការសង្កេត ការពិចារណាអំពីអង្គហេតុ ឬព័ត៌មានខ្លះៗ។

ជនជាប់ចោទដែលលើកសម្អាងពីការការពារស្របច្បាប់ត្រូវរកភស្តុតាងមកបញ្ជាក់ពីអត្ថិភាពនៃការការពារស្របច្បាប់ ក៏ប៉ុន្តែក្រមព្រហ្មទណ្ឌបានសន្មត់ទុកជាមុននូវករណីពីរយ៉ាងថា ជាការការពារស្របច្បាប់ ពោលគឺ ជនជាប់ចោទ (អ្នកដែលលើកសំអាងពីការការពារស្របច្បាប់) មិនចាំបាច់រកភស្តុតាងពីលក្ខខណ្ឌនៃការការពារស្របច្បាប់ឡើយ ដោយគេសន្មត់ទុកជាមុនតែម្ដង។

២០. ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ ២០០៩, មាត្រា ៣៣ ផ្នែកទី១

ដោយយោងតាមអនុលោមមាត្រា ៣៤ នៃក្រមព្រហ្មទណ្ឌបានបញ្ញត្តថា "ត្រូវសន្មត់ថា ជាការការពារស្របច្បាប់នៅក្នុងករណីដូចតទៅ" ៖

១ - បទល្មើសត្រូវបានប្រព្រឹត្ត ដើម្បីរុញច្រានការចូលក្នុងពេលយប់ ដោយការកាប់គាស់ទម្លុះទម្លាយ ដោយហិង្សា ឬដោយកលល្បិចនៅក្នុងទីកន្លែងដែលមានមនុស្សនៅ។

២ - បទល្មើសបានប្រព្រឹត្ត ដើម្បីការពារខ្លួនប្រឆាំងនឹងការលួច ឬការប្លន់ដែលអនុវត្តដោយហិង្សា សច្ចធារណ៍នៃការការពារស្របច្បាប់ ពុំមានលក្ខណៈដាច់ខាតទេ។ សច្ចធារណ៍នេះអាចត្រូវរំលាយដោយភស្តុតាងផ្ទុយ។

ក្នុងករណីនៃសច្ចធារណ៍នៃការការពារស្របច្បាប់ដូចមានចែងខាងលើនេះ ចារីដែលបានប្រព្រឹត្តបទល្មើសគ្រាន់តែបង្ហាញភស្តុតាង អំពីស្ថានភាពដូចមានចែងក្នុងចំណុចទី ១ និងចំណុចទី ២ នៃមាត្រា ៣៤ នៃក្រមព្រហ្មទណ្ឌជាការគ្រប់គ្រាន់ ដោយមិនបាច់បង្ហាញភស្តុតាងពីលក្ខខណ្ឌនៃការការពារស្របច្បាប់ដូចមានចែងនៅមាត្រា ៣៣ នៅក្រមព្រហ្មទណ្ឌឡើយ។[23]

ឧទាហរណ៍៖ ក្នុងករណីដែលមានការឈ្លានពាននៅពេលយប់មួយដោយមានការកាប់គាស់ទ្វារបង្អួច។ នៅពេលដែលបុរស ក ជាម្ចាស់ផ្ទះនោះបានដឹងថាមានអ្នកឈ្លានពានចូលមកក្នុងផ្ទះរបស់ខ្លួន ដើម្បីជៀសវាងពីសកម្មភាពឈ្លានពាន ឬអាចមានការធ្វើទារុណកម្ម ឬអំពើសម្លាប់មកលើខ្លួន លោក ក បានយកកាំភ្លើងរបស់ខ្លួនទៅបាញ់លើបុរស ខ ជាអ្នកឈ្លានពាននោះ (ចោរ) បណ្ដាលឲ្យស្លាប់ភ្លាមៗ។ នៅក្នុងករណីនេះដែរ លោក ក មិនអាចត្រូវបានទទួលខុសត្រូវព្រហ្មទណ្ឌដោយសំអាងលើសច្ចធារណ៍នៃការការពារស្របច្បាប់។ តែប្រសិនបើនៅក្នុងករណីលោក ក តុលាការបានរកឃើញភស្តុតាងមកបញ្ជាក់ដោយសំអាងមាត្រា ៣៣ នៃក្រមព្រហ្មទណ្ឌដើម្បីជាការការពារស្របច្បាប់នោះ លោក ក អាចរួចផុតពីការទទួលខុសត្រូវនេះបាន។[24]

ឧទាហរណ៍៖ នៅកន្លែងធ្វើការមួយកន្លែងមានសភាពស្ងាត់ ដោយមានតែបុរសម្នាក់ ហើយនឹងនារីម្នាក់។ ឃើញសភាពស្ងាត់ដូច្នោះ បុរសនោះក៏បម្រុងនឹងចាប់រំលោភលើរូបនាង ហើយនារីនោះបានប្រកែកភ្លាមៗ ។ បុរសនោះក៏បាននិយាយថា បើនាងមិនព្រមឲ្យគេរំលោភដោយសម្រួលទេនោះ គេនឹងបាញ់សម្លាប់នារីនោះភ្លាម។ នារីម្នាក់នោះបានឮដូច្នោះ នាងក៏បានស្រវាយកកូនកាំបិតដែលនៅក្នុងថតតុរបស់ខ្លួនទៅចាក់លើបុរសនោះបណ្ដាលឲ្យស្លាប់ភ្លាមៗ នៅនឹងកន្លែងកើតហេតុ។ នៅក្នុងករណីនេះផងដែរ នារីម្នាក់នោះពុំអាចលើសម្អាងហេតុដោយសច្ចធារណ៍នៃការការពារស្របច្បាប់បានឡើយ ហើយនាងនៅតែអាចទទួលទោសបាន តែទោសនោះទៀតសោតគឺត្រូវបានសម្រាល។

## ២.៤. ស្ថានភាពចាំបាច់

យោងតាមមាត្រា ៣៥ នៃក្រមព្រហ្មទណ្ឌបានចែងថា៖ **បុគ្គលដែលស្ថិតក្នុងការចាំបាច់ត្រូវតែប្រព្រឹត្តបទល្មើសមិនទទួលខុសត្រូវព្រហ្មទណ្ឌទេ ។**

22.នីតិព្រហ្មទណ្ឌទូទៅ សាស្ត្រាចារ្យ មីន សំអុល

23.ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ ២០០៩, មាត្រា ៣៤

ស្ថានភាពចាំបាច់ត្រូវមានលក្ខខណ្ឌដូចខាងក្រោមនេះ៖

- បទល្មើសត្រូវបានចាត់ទុកថាត្រឹមត្រូវដោយការចាំបាច់ដើម្បីការពារខ្លួន ការពារអ្នកដទៃ ឬ ការពារទ្រព្យសម្បត្តិ ប្រឆាំងនឹងគ្រោះថ្នាក់ដែលនឹងកើតមាន ឬដែលនឹងកើតមាន និង
- គ្មានវិសមាមាត្ររវាងមធ្យោបាយការពារនិងទម្ងន់នៃគ្រោះថ្នាក់។

ស្ថានភាពចាំបាច់ គឺសំដៅទៅលើបុគ្គលដែលស្ថិតនៅក្នុងការចាំបាច់ត្រូវការពារខ្លួន ជាស្ថានភាពដែលបុគ្គលម្នាក់ៗឈានទៅដល់ការប្រព្រឹត្តបទល្មើសណាមួយ ដោយសារតែមានបំណងចង់ស្តារផលប្រយោជន៍ផ្ទាល់ខ្លួន ផលប្រយោជន៍អ្នកដទៃ ក៏ដូចជាផលប្រយោជន៍របស់រដ្ឋផងដែរ ដែលត្រូវបានគម្រាមកំហែងនូវគ្រោះថ្នាក់ដែលកំពុងតែកើតមាន ឬដែលនឹងកើតមាននោះមកវិញ។[25]

ចំពោះស្ថានភាពចាំបាច់ចារីមានជម្រើសពីរយ៉ាងគឺ៖

១. ទទួលយកការខូចខាតដែលត្រូវនឹងកើតឡើង ដោយសុខចិត្តបដិសេធមិនព្រមប្រព្រឹត្តបទល្មើស

២. ត្រូវតែប្រព្រឹត្តបទល្មើសដើម្បីបញ្ចៀសការខូចខាត។

នៅក្នុងស្ថានភាពចាំបាច់ គឺធ្វើឲ្យកើតឡើងនូវវិវាទផលប្រយោជន៍ដែលតម្រូវឲ្យបុគ្គលម្នាក់ធ្វើការជ្រើសរើសជាចាំបាច់ដើម្បីការពារផលប្រយោជន៍ណាមួយដោយខានមិនបាន។ បើផ្អែកតាមសីលធម៌ចៅក្រម មានការលំបាកនឹងសម្រេចនូវការផ្តន្ទាទោសបុគ្គលម្នាក់ដែលសុខចិត្តជ្រើសរើសយកការប្រព្រឹត្តបទល្មើសដើម្បីបញ្ចៀសកុំឲ្យមានព្យសនកម្មធ្ងន់ធ្ងរកើតឡើង។

ស្ថិតក្នុងបដិការនេះ ស្ថានភាពចាំបាច់មានការខុសប្លែកគ្នាពីកម្លាំង និងការបង្ខំ ដែលជម្រុញឲ្យចារីប្រព្រឹត្តបទល្មើស ពីព្រោះតែខ្លួនមិនអាចទប់ទល់បានដោយគ្មានជម្រើសអ្វីដែលល្អទាល់តែសោះ។

ដូចនេះដើម្បីឲ្យមានការរួចផុតពីការទទួលខុសត្រូវព្រហ្មទណ្ឌនូវស្ថានភាពចាំបាច់មួយនេះ អ្នកដែលបានប្រព្រឹត្តបទល្មើស (ចារី) ត្រូវតែបង្ហាញភស្តុតាងពីព្រឹត្តការណ៍នៃគ្រោះថ្នាក់នោះ ដែលកំពុងកើតមាន ឬរៀបនឹងកើតមាន។

### ២.៤.១. គ្រោះថ្នាក់កំពុងមាន ឬដែលនឹងកើតមាន

ជាបឋមជនដែលប្រព្រឹត្តបទល្មើស ដោយសារស្ថានភាពចាំបាច់ត្រូវរកភស្តុតាងអំពីគ្រោះថ្នាក់ដែលជម្រុញឲ្យខ្លួនប្រព្រឹត្តបទល្មើស។ គ្រោះថ្នាក់អាចជាគ្រោះថ្នាក់ដែលគំរាមកំហែងចារីផ្ទាល់តែម្តង ឬគំរាមកំហែងពីតតិយជន ឬមួយក៏គ្រាន់តែគម្រាមកំហែងលើទ្រព្យសម្បត្តិណាមួយក៏បានដែរ។

ឧទាហរណ៍ ១៖ ដោយសារតែមានការឆាបឆេះផ្ទះសម្បែងរបស់ប្រជាពលរដ្ឋមួយកន្លែងនៅជិតវត្តអារាម ប្រជាជនបានវាយផ្ទះចំនួន ១ ខ្នងដើម្បីបញ្ចៀសពីការឆាបឆេះដល់វត្តនោះទាន់។ នេះជាករណីដែលគេប្រព្រឹត្តឡើងដើម្បីការពារ និងបញ្ចៀសពីការគ្រោះថ្នាក់នៃការឆាបឆេះរីករាលដាលទៅដល់វត្តអារាម ឬផ្ទះសម្បែងរបស់ប្រជាពលរដ្ឋដទៃទៀត។

---

24.ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ ២០០៩, មាត្រា ៣៥

ឧទាហរណ៍ ២៖ ក្នុងករណីមានភ្លើងឆេះក្នុងផ្ទះបាយ នៅពេលដែលនារីម្នាក់កំពុងធ្វើម្ហូបក្នុងផ្ទះបាយ ដើម្បីបញ្ចៀសពីការឆាបឆេះនោះ នារីម្នាក់នោះបានឃើញបំពង់បន្លត់អគ្គីភ័យរបស់អ្នកជិតខាង ខ្លួនក៏ស្រវ៉ាទៅយកមកដើម្បីពន្លត់ដោយមិនបានសុំការអនុញ្ញាតពីម្ចាស់ផ្ទះជាមុន។ នេះគឺជាការបញ្ចៀសគ្រោះថ្នាក់ដល់សម្បត្តិរបស់ចារីដែលបានប្រព្រឹត្តបទល្មើសលួច ប្រសិនបើគ្មានការពន្លត់ទេនោះ វាបណ្តាលឲ្យឆេះទៅដល់ផ្ទះអ្នកជិតខាងរបស់នាងថែមទៀត។

ឧទាហរណ៍ ៣៖ ដោយសារតែឃើញប្អូនជាក្មេងអនាថាដូចគ្នាកំពុងតែដេកឃ្លានអាហារ ហើយមានសភាពល្ហិតល្ហៃខ្លាំង មើលទៅអាចបណ្តាលឲ្យស្លាប់ដោយសារការឃ្លាននោះ បងរបស់គេក៏បានសម្រេចលួចបាយដើម្បីឲ្យប្អូននោះបានញ៉ាំ។ ក្នុងករណីអំពើលួចរបស់បងដែលជាក្មេងអានាថានោះ គឺជាអំពើដែលបញ្ចៀសអំពីគ្រោះថ្នាក់ដល់អាយុជីវិត។

គ្រោះថ្នាក់ត្រូវតែមានការជាក់លាក់ មានន័យថាជាគ្រោះថ្នាក់កំពុងមាន ឬដែលនឹងមានយ៉ាងពិតប្រាកដ មិនមែនជាគ្រោះថ្នាក់ជាយថាហេតុតាមការរវើរវាយ ឬតាមការប៉ាន់ស្មានជាអត្តនោម័តរបស់ចារីឡើយ។ ហេតុដូច្នេះ ការវាយតម្លៃអំពីគ្រោះថ្នាក់ដែលនឹងកើតមាន ត្រូវធ្វើដោយលក្ខណៈសត្យានុម័តមិនអាចទាញចេញ ពីការភ័យព្រួយបារម្ភរបស់ចារីតែម្នាក់ឯងបានឡើយ។

### ២.៤.២. ការការពារចាំបាច់

ការពារចាំបាច់គឺជា អំពើ ឬសកម្មភាពណាមួយដែលត្រូវតែការពារ ដោយមានកាតព្វកិច្ចចាំបាច់បំផុតក្នុងការការពារនោះ គឺជាជម្រើសដ៏ត្រឹមត្រូវ ឬជាជម្រើសចុងក្រោយ និងល្អបំផុតក្នុងការបញ្ចៀសពីគ្រោះថ្នាក់ដែលកំពុងកើតមាន ឬរៀបនឹងកើតឡើង។ ដើម្បីឲ្យមានយុត្តិកម្មនៃបទល្មើសដែលប្រព្រឹត្តដោយចារីត្រូវតែជាអំពើចាំបាច់ដើម្បីការពារខ្លួនឯង ការពារអ្នកដទៃ ឬទ្រព្យសម្បត្តិ។ នៅចំណុចនេះមានន័យថាការប្រព្រឹត្តបទល្មើសជាជម្រើសដ៏ប្រសើរបំផុត និងជាជម្រើសតែមួយគត់ ដើម្បីបញ្ចៀសគ្រោះថ្នាក់បាន។ ការវាយតម្លៃថាជាការការពារតាមរយៈការប្រព្រឹត្តបទល្មើសជាការចាំបាច់ ឬអត់ ឬយ៉ាងណានោះ គឺអាស្រ័យទៅតាមអង្គហេតុនៃករណីនីមួយៗ។

ឧទាហរណ៍៖ បុរសម្នាក់បានរុញច្រានរទេះរបស់អ្នកលក់លតឆាមួយ ដែលគាត់កំពុងលក់នៅតាមដងផ្លូវដោយមូលហេតុចង់បង្វាំង និងបញ្ចៀសពីគ្រោះថ្នាក់ដែលមានរថយន្តមួយរេចង្កូតសំដៅទៅលោកយាយម្នាក់ដែលកំពុងនៅលក់បន្លែនៅក្បែរនោះ ដែលបានបណ្តាលឲ្យរទេះលតឆានោះខូចខាត។ នៅក្នុងករណីនេះ បុរសដែលបានប្រព្រឹត្តនោះ មិនបានទទួលខុសត្រូវព្រហ្មទណ្ឌបានទេ ក៏ព្រោះតែមូលហេតុចាំបាច់ក្នុងការការពារលោកយាយដែលកំពុងតែលក់បន្លែនោះពីគ្រោះថ្នាក់ តែប្រសិនបើបុរសនោះមិនបានរុញរទេះនោះទេនោះអាចបណ្តាលឲ្យលោកយាយរងរបួសដោយសាររថយន្តដែលរេចង្កូតនោះ ឬអាចបង្កគ្រោះថ្នាក់ដល់អាយុជីវិតបាន។

### ២.៤.៣. គ្មានវិសមាមាត្ររវាងមធ្យោបាយការពារជាមួយនឹងទម្ងន់នៃគ្រោះថ្នាក់

ចារីដែលបានប្រព្រឹត្តបទល្មើសត្រូវរកភស្តុតាងមកបញ្ជាក់ឲ្យឃើញច្បាស់ថា បទល្មើសដែលខ្លួនបានប្រព្រឹត្តមានលក្ខណៈសមាមាត្ររវាងមធ្យោបាយការពារ និងទម្ងន់នៃគ្រោះថ្នាក់នោះ។ ផលវិបាកនៃបទល្មើសត្រូវតែ

មានតម្លៃតិចជាង ឬស្មើនឹងតម្លៃដែលចារីមានបំណងចង់ជួយសង្គ្រោះ។ ភាពសមាត្រនៃមធ្យោបាយការពារ និងទម្ងន់នៃគ្រោះថ្នាក់ត្រូវវាយតម្លៃទៅតាមស្ថានភាពនៃករណីនីមួយៗ។

ឧទាហរណ៍៖ ក្នុងករណីមានរថយន្តដឹកអីវ៉ាន់ធន់ធ្ងន់មួយបានដាច់ហ្វ្រាំងនៅពេលកំពុងតែធ្វើដំណើរចុះពីលើស្ពានមួយ ដើម្បីបញ្ចៀសពីការរួចផុតពីគ្រោះថ្នាក់របស់អ្នកដំណើរដែលជិះម៉ូតូស្របទិសគ្នា គាត់ក៏បានសម្រេចចិត្តទៅបុករង្វង់មូលគល់ស្ពាននោះបណ្ដាលឲ្យមានការខូចខាត។ ក្នុងករណីនេះគេគួរតែចាត់ទុកថាជាស្ថានភាពចាំបាច់មួយដែលមានលក្ខណៈសមាមាត្រ ហើយនៅក្នុងករណីនេះទៀតសោតអ្នកបើកបររថយន្តពុំត្រូវបានទទួលខុសព្រហ្មទណ្ឌឡើយ។[26]

25.ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ ២០០៩, មាត្រា ៣៥ផ្នែកទី២

# ជំពូកទី ៣
# មូលហេតុនីត្យានុកូលភាពនៃការមិនទទួលខុសត្រូវ ឬការសម្រាលទោសនូវការទទួលខុសត្រូវព្រហ្មទណ្ឌ

## ៣.១. ការមិនទទួលខុសត្រូវរបស់អនីតិជន

បើតាមបញ្ញត្តិក្នុងក្រមព្រហ្មទណ្ឌ យោងតាមក្នុងមាត្រា ៣៨ បានបញ្ញត្តថា នីតិភាពនៃការទទួលខុសត្រូវព្រហ្មទណ្ឌ ត្រូវបានកំណត់អាយុចាប់ពី ១៨ (ដប់ប្រាំបី) ឆ្នាំឡើងទៅ។ តាមមាត្រានេះគឺមានន័យថាជាការចាំបាច់ការទទួលខុសត្រូវព្រហ្មទណ្ឌគឺជានីតិជន។[27] ក៏ប៉ុន្តែនៅក្នុងក្រមព្រហ្មទណ្ឌ ក៏ត្រូវបានគេបញ្ញត្តឲ្យតុលាការអាចប្រកាសទណ្ឌកម្មព្រហ្មទណ្ឌទៅលើអនីតិជន ចាប់ពីអាយុ ១៤ឆ្នាំ ឡើងទៅបានដែរប្រសិនបើកាលៈទេសៈនៃបទល្មើស ឬបុគ្គលិកលក្ខណៈរបស់អនីតិជនតម្រូវ។

### ៣.១.១. និយមន័យ

បើយោងតាមមាត្រា ៤ នៃច្បាប់ស្ដីពីយុត្តិធម៌អនីតិជននៅត្រង់វាក្យសព្ទ ៣ បានចែងថា **អនីតិជន** សំដៅដល់ជនដែលមានអាយុតិចជាង ១៨ (ដប់ប្រាំបី) ឆ្នាំនៅពេលប្រព្រឹត្តបទល្មើស។[28]

### ៣.១.២. អនីតិជនដែលមានអាយុក្រោម ១៤ ឆ្នាំ

អនីតិជនគឺជាជនដែលច្បាប់បានបញ្ញត្តថា ជាជនដែលមិនទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌទេ ពីព្រោះគេជាជនដែលមិនអាចយល់ដឹងពីអំពើដែលខ្លួនបានប្រព្រឹត្តថាជាបទល្មើសព្រហ្មទណ្ឌបានឡើយ។ ទាក់ទងក្មេងអាយុនៅក្រោម ១៤ ឆ្នាំ ហើយគាត់ទៅបង្កបទល្មើសដូចជាសម្លាប់មនុស្សស្លាប់ក្នុងមធ្យោបាយណាមួយនោះបើតាមច្បាប់ក្មេងនោះមិនត្រូវទទួលទោសទេ ហើយត្រូវប្រគល់ក្មេងនោះត្រូវប្រគល់ឲ្យឪពុកម្ដាយវិញ។ ប៉ុន្តែករណីនេះ ឪពុក ម្ដាយមិនអាចទទួលទោសជំនួសកូនបានទេនៅក្នុងរឿងព្រហ្មទណ្ឌគឺអ្នកណាប្រព្រឹត្ត អ្នកនោះជាអ្នកទទួល តែពួកគាត់នឹងចេញសំណងរដ្ឋប្បវេណីជំនួសឲ្យកូនដែលបង្កបទល្មើសនោះ។ ការយល់ដឹងគឺជាកត្តាមួយដ៏សំខាន់ដែលច្បាប់អាចកំណត់ពីការទទួលខុសត្រូវរបស់បុគ្គលម្នាក់ ដូច្នេះអនីតិជនដែលមានអាយុក្រោម ១៤ ឆ្នាំមិនត្រូវបានទទួលខុសត្រូវព្រហ្មទណ្ឌឡើយ។[29]

ឧទាហរណ៍៖ មានកុមារាម្នាក់មានអាយុក្រោម ១៤ ឆ្នាំម្នាក់ បានទៅលួចម៉ូតូដែលគេទុកនៅក្រោមផ្ទះ បន្ទាប់មកត្រូវបានម្ចាស់ផ្ទះតាមទាន់ថៃមទាំង បានស្រែកដើម្បីបញ្ឈប់សកម្មភាពរបស់កុមារាម្នាក់នោះ។ ដូច្នេះក្នុងករណីនេះកុមារានោះមិនបានទទួលខុសត្រូវព្រហ្មទណ្ឌ ឬទណ្ឌកម្មណាមួយពីច្បាប់ឡើយ ហើយតុលាការក៏មិនអាចប្រការទណ្ឌកម្មទៅលើកុមារាម្នាក់នោះបានដែរ។

26.ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ ២០០៩,មាត្រា ៣៨

27.ច្បាប់ស្ដីពីយុត្តិធម៌អនីតិជនឆ្នាំ ២០១៦

28.នីតិព្រហ្មទណ្ឌ និង គ្រួសារ រៀបរៀងដោយៈ សាស្ត្រាចារ្យ រុន ពណ្ណារិទ្ធ និង ចាំង ស៊ីណាត

បើយោងតាមច្បាប់ស្តីពីយុត្តិធម៌អនីតិជននៅត្រង់មាត្រា ១៤ បានចែងថា អនីតិជនមានអាយុក្រោម ១៤ (ដប់បួន) ឆ្នាំ ដែលជាប់សង្ស័យថា បានប្រព្រឹត្តបទល្មើសពុំអាចត្រូវឃាត់ខ្លួនឡើយ ហើយមន្ត្រីនគរបាលយុត្តិធម៌ ត្រូវប្រគល់អនីតិជននោះទៅឲ្យអ្នកតំណាងដែលច្បាប់បានកំណត់។ ក្នុងករណីអនីតិជនត្រូវការកិច្ចការពារ និងថែទាំ មន្ត្រីនគរបាលយុត្តិធម៌ត្រូវបញ្ជូនជននោះទៅមន្ទីរ ឬការិយាល័យទទួលបន្ទុកវិស័យសង្គមកិច្ចរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ដើម្បីចាត់វិធានការសមស្របទៅតាមសុខុមាលភាព និងស្ថានភាពសង្គមរបស់អនីតិជន។ មន្ទីរ ឬការិយាល័យទទួលបន្ទុកវិស័យសង្គមកិច្ចរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវធ្វើរបាយការណ៍អំពីការទទួលខុសត្រូវអនីតិជនពីមន្ត្រីនគរបាលយុត្តិធម៌ជូនទៅព្រះរាជអាជ្ញា។

ក្នុងករណីយល់ឃើញថា អនីតិជនត្រូវការកិច្ចការពារ និងថែទាំ នោះមន្ទីរ ឬការិយាល័យត្រូវចាត់វិធានការស្នើសុំព្យួរ ឬដកហូតអំណាចមេបា ឬបញ្ឈប់អ្នកអាណាព្យាបាលសម្រាប់អនីតិជន ឬអ្នកអាណាព្យាបាលទូទៅ ក្នុងករណីដែលអនីតិជនមានអ្នកតំណាងដែលច្បាប់បានកំណត់ដើម្បីឲ្យតុលាការសម្រេចអំពីការព្យួរ ឬការដកហូត ឬការបញ្ឈប់អ្នកតំណាងដែលច្បាប់បានកំណត់ និងសិទ្ធិអាណាព្យាបាលលើអនីតិជននោះ។ តែបើក្នុងករណីដែលអនីតិជនគ្មានអ្នកតំណាងដែលច្បាប់បានកំណត់មន្ទីរ ឬការិយាល័យត្រូវសុំទៅតុលាការដើម្បីសម្រេចអំពីសិទ្ធិអាណាព្យាបាលលើអនីតិជននោះ។ គ្រប់អំពើជាបទល្មើសទាំងអស់ដែលប្រព្រឹត្តដោយអនីតិជនអាយុក្រោម ១៤ (ដប់បួន) ឆ្នាំមន្ត្រីនគរបាលយុត្តិធម៌ត្រូវបញ្ជូនសំណុំរឿងទៅព្រះរាជអាជ្ញា។

### ៣.១.៣. អនីតិជនដែលមានអាយុចាប់ពី ១៤ ឆ្នាំរហូតទៅដល់ក្រោម ១៨ ឆ្នាំ

អនីតិជន គឺសំដៅដល់ជនទាំងឡាយណាដែលច្បាប់បានកំណត់ថា ជាជនដែលរួចផុតពីការទទួលខុសត្រូវព្រហ្មទណ្ឌ ប៉ុន្តែនៅតែក្នុងករណីនេះ អនីតិជនដែលមានអាយុចាប់ពី ១៤ឆ្នាំ រហូតដល់ក្រោម ១៨ឆ្នាំ ចាំបាច់ត្រូវតែទទួលខុសត្រូវដដែល ក្នុងករណីដែលកាលៈទេសៈនៃបទល្មើស ឬបុគ្គលិកលក្ខណៈរបស់អនីតិជនតម្រូវ ។[30]

**ចំពោះបទឧក្រិដ្ឋ៖**

- ក្រោមអាយុ ១៦ ឆ្នាំ មិនអាចលើសពី ៤ ខែ (ពន្យាបានម្តង)
- ចាប់ពីអាយុ ១៦ ឆ្នាំ ដល់ក្រោម ១៨ ឆ្នាំ មិនអាចលើសពី ៦ ខែ (ពន្យាបានម្តង ៦ ខែ)

**ចំពោះបទមជ្ឈិម**

- ក្រោមអាយុ ១៦ ឆ្នាំ មិនអាចលើសពី ២ ខែ (ពន្យាបានម្តង)
- អាយុចាប់ពី ១៦ ឆ្នាំ ដល់ក្រោម ១៨ ឆ្នាំ មិនអាចលើសពី ៤ ខែ (ពន្យាបានម្តង ៤ ខែ)

❖ ប្រសិនបើអនីតិជនអាយុក្រោម ១៤ ឆ្នាំ មិនអាចឃុំខ្លួនបានទេ (ត្រូវតែប្រគល់ទៅឲ្យ ឪពុក ម្តាយ អាណាព្យាបាល ឬក៏ប្រគល់ឲ្យអង្គការ សមាគម៏ដែលមើលថែរកូនក្មេង)។[31]

29.ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ ២០០៩, មាត្រា ៣៩ កថាខណ្ឌទី ២

30.ក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ ២០០៧, មាត្រា ២០៤

ឧទាហរណ៍៖ មានក្មេងប្រុសម្នាក់ អាយុ ១៧ ឆ្នាំបានធ្វើសកម្មភាពលួចទូរស័ព្ទមិត្តរួមថ្នាក់របស់ខ្លួន។ ក្នុងករណីនេះក្មេងប្រុសម្នាក់នេះត្រូវតែប្រឈមមុខនឹងច្បាប់ជាដាច់ខាត ដោយសារតែខ្លួនមានការយល់ដឹងច្បាស់ថា អំពើដែលខ្លួនបានប្រព្រឹត្តនោះវាគឺជាបទល្មើសដែលត្រូវប្រឈមនឹងច្បាប់ ដូច្នេះតុលាការអាចសម្រេចប្រកាសទណ្ឌកម្មព្រហ្មទណ្ឌលើកុមារនោះបាន។ ក្នុងករណីអនីតិជនចាប់ពីអាយុ ១៤ ឆ្នាំឡើងដល់ក្រោមអាយុ ១៨ ឆ្នាំ ហើយគាត់បានទៅប្រព្រឹត្តបទល្មើសនោះ គឺគាត់ត្រូវទទួលទោស។ ក៏ប៉ុន្តែទោសរបស់គាត់ស្មើនឹងពាក់កណ្ដាលនៃមនុស្សពេញវ័យ។ មានន័យថាគាត់ត្រូវតុលាការផ្ដន្ទាទោសពី ៥ ទៅ ១០ ឆ្នាំ ដូច្នេះគាត់ត្រូវតែជាប់ទោសត្រឹមតែ ២ ឆ្នាំកន្លះទេ បានន័យថាអប្បបរមានៃទោសគឺ ទោសណាដែលស្រាលជាងគេ គឺយកទោសនោះមកចែកជា ២ ទៀត។

បើយោងតាមមាត្រា ១៦០ នៃក្រមព្រហ្មទណ្ឌបានចែងថា កាលណាតុលាការសម្រេចផ្ដន្ទាទោសព្រហ្មទណ្ឌទៅលើអនីតិជនអាយុចាប់ពី ១៤ (ដប់បួន) ឆ្នាំឡើងទៅ មូលទោសលើបទល្មើសដែលចោទប្រកាន់ត្រូវបានបន្ថយក្នុងលក្ខខណ្ឌដូចតទៅ ៖

១ - អតិបរមានៃទោសដាក់ពន្ធនាគារត្រូវបន្ថយពាក់កណ្ដាល។

២ - ប្រសិនបើអតិបរមានៃទោសនោះ គឺជាទោសដាក់ពន្ធនាគារអស់មួយជីវិត អតិបរមាត្រូវបន្ថយដាក់ពន្ធនាគារអស់មួយជីវិត អតិបរមាត្រូវបន្ថយមកដាក់ពន្ធនាគារ ២០ (ម្ភៃ) ឆ្នាំ។

៣ - អប្បបរមានៃទោសដាក់ពន្ធនាគារ ត្រូវបន្ថយពាក់កណ្ដាល ប្រសិនបើអប្បបរមានេះលើសពី ១ ( មួយ) ថ្ងៃ ។

៤ - អប្បបរមា និងអតិបរមានៃទោសពិន័យជាប្រាក់ ត្រូវបន្ថយពាក់កណ្ដាល។

ក្នុងករណីចោទប្រកាន់ពីបទឧក្រិដ្ឋ ប្រសិនបើបទប្បញ្ញត្តិនៃមាត្រានេះមានអានុភាពបន្ថយអតិបរមានៃទោសដាក់ពន្ធនាគារមកត្រឹមថិរវេលាមួយស្មើ ឬតិចជាង ៥ ( ប្រាំ )ឆ្នាំ នោះ បទល្មើសដែលចោទប្រកាន់នៅតែជាបទឧក្រិដ្ឋដដែល ។

## ៣.២. ការមិនទទួលខុសត្រូវរបស់នីតិបុគ្គលសាធារណៈ

នីតិបុគ្គលសាធារណៈ គឺជាបុគ្គលអរូបដែលច្បាប់បង្កើតមកសម្រាប់បម្រើផលប្រយោជន៍សាធារណៈ ដោយមិនស្វែងរកប្រាក់ចំណេញមានដូចជា ឃុំ សង្កាត់ ក្រសួងស្ថាប័នរបស់រដ្ឋ រួមបញ្ចូលទាំងរដ្ឋផងដែរ។

ដូច្នេះសរុបជារួមមកមានន័យថាគ្រប់នីតិបុគ្គលទាំងអស់ ដែលស្ថិតនៅក្នុងនីតិសាធារណៈ រួមទាំងរដ្ឋផងគឺ នីតិបុគ្គលសាធារណៈ។[32]

ឧទាហរណ៍៖ ឃុំ សង្កាត់ បង្កើតឡើងដើម្បីបម្រើផលប្រយោជន៍ជូនប្រជាពលរដ្ឋ ដែលរស់នៅក្នុង ឃុំ សង្កាត់នោះ សេវាទាំងនោះមានដូចជា ការធ្វើសំបុត្រកំណើត សំបុត្រអាពាហ៍ពិពាហ៍។ល។ ដោយបម្រើជូនប្រជាពលរដ្ឋដោយពុំគិតសេវាអ្វីទាំងអស់។

31. ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ ២០០៩, មាត្រា ៤២ កថាខណ្ឌទី១

បើយោងតាមក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា មាត្រា ៤២ កថាខណ្ឌទី ១ បានបញ្ញត្តថា " នៅក្នុងករណីដែលបានចែងជាក់លាក់ក្នុងច្បាប់ និងបទដ្ឋានគតិយុត្តផ្សេងទៀត។ នីតិបុគ្គល **លើកលែងតែរដ្ឋចេញ** អាចត្រូវបានប្រកាសថាត្រូវទទួលខុសត្រូវព្រហ្មទណ្ឌ ពីបទល្មើសដែលប្រព្រឹត្តដោយ អង្គការ ឬអ្នកតំណាងរបស់ខ្លួនដើម្បីជាប្រយោជន៍របស់នីតិបុគ្គលនោះ។ តែប្រសិនបើនីតិបុគ្គលធារណៈបាន ប្រព្រឹត្តនូវអំពើដែលផ្ទុយពីច្បាប់ ឬអាចនិយាយថាអំពើដែលច្បាប់បានចែងជាអំពើខុសច្បាប់ នីតិបុគ្គល សាធារណៈនោះមិនត្រូវបានទទួលខុសត្រូវព្រហ្មទណ្ឌឡើយ។ ទោះបីជាមានការប្រព្រឹត្តដោយតំណាងរបស់ នីតិបុគ្គល ហើយវាជាផលប្រយោជន៍សម្រាប់នីតិបុគ្គលនោះក៏ដោយ ក៏មានលក្ខខណ្ឌ ពិសេសមួយទៀត ដែលអនុញ្ញាតឲ្យនីតិបុគ្គលសាធារណៈពិសេសនេះមិនទទួលខុសត្រូវព្រហ្មទណ្ឌគឺ **រដ្ឋ**។ រដ្ឋជានីតិបុគ្គលសាធារណៈដែលមិនទទួលខុសត្រូវព្រហ្មទណ្ឌឡើយ ព្រោះរដ្ឋជាអ្នកបង្កើតច្បាប់សម្រាប់ដាក់ទណ្ឌកម្មដល់បុគ្គលណាដែលមិនប្រព្រឹត្តតាម ពោលគឺរដ្ឋមិនបង្កើតច្បាប់ដាក់ទោសខ្លួនឯងឡើយ។

# សេចក្តីសន្និដ្ឋាន

ជាការពិតណាស់ មនុស្សយើងគ្រប់ៗរូបកើតមករមែងតែងតែមានសិទ្ធិ និងកាតព្វកិច្ចមកជាមួយរៀងៗខ្លួន មិនថាក្នុងសង្គមនៅប្រទេសកម្ពុជាទេ គឺប្រជាជនទាំងអស់ទូទាំងពិភពលោកសុទ្ធតែមានសិទ្ធិស្មើៗភាពគ្នា។ តួយ៉ាងដូចដែលនៅក្នុងរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាបានចែងថា "ប្រជាពលរដ្ឋខ្មែរមានភាពស្មើគ្នាចំពោះមុខច្បាប់ មានសិទ្ធិសេរីភាព និងករណីយកិច្ចដូចគ្នាទាំងអស់ ដោយឥតប្រកាន់ពូជសាសន៍ ពណ៌សម្បុរ ភេទ ភាសា ជំនឿសាសនា និន្នាការនយោបាយ ដើមកំណើតជាតិ ឋានៈសង្គម ធនធាន ឬ ស្ថានភាពឯទៀតឡើយ។ ការប្រើសិទ្ធិសេរីភាពផ្ទាល់ខ្លួនរបស់បុគ្គលម្នាក់ៗ មិនត្រូវឲ្យប៉ះពាល់ដល់សិទ្ធិសេរីភាពអ្នកដទៃឡើយ។ ការប្រើសិទ្ធិសេរីភាពនេះ ត្រូវប្រព្រឹត្តតាមលក្ខខណ្ឌកំណត់ក្នុងច្បាប់"។ ប៉ុន្តែមានមនុស្សមួយចំនួនតូចមានភាពលោភលន់ក្នុងការប្រើប្រាស់សិទ្ធិដែលខ្លួនមាន ហើយថែមទាំងឈានទៅដល់ការប្រើប្រាស់សិទ្ធិរបស់ខ្លួនទៅបំពានលើអ្នកដទៃ ដែលបង្កអសន្តិសុខដល់សង្គម គ្មានសណ្តាប់ធ្នាប់ និងគ្មានរបៀបរៀបរយជាដើម។ ហេតុដូច្នេះហើយទើបបានជាគេបង្កើតឡើងនូវក្រមព្រហ្មទណ្ឌ ដើម្បីរក្សានូវសិទ្ធិសេរីភាពរបស់បុគ្គលដែលត្រូវបានគេបំពានមកលើខ្លួន ក៏ដូចជាការពារ ឬទប់ស្កាត់នូវអំពើណាដែលមានលក្ខណៈឈ្លានពានអំពើដែលមិនគប្បីនៅក្នុងសង្គម ដូចជាការគំរាមកំហែងដល់អ្នកទន់ខ្សោយជាង ការគៀបសង្កត់នូវសិទ្ធិសេរីភាពរបស់អ្នកទន់ខ្សោយ មិនថាអំពើនោះជាអំពើចេតនា ឬអចេតនានោះឡើយ។

ដូចនេះការស្រាវជ្រាវលើប្រធានបទនេះបានផ្តល់នូវផលប្រយោជន៍ ការយល់ដឹង និងការបកស្រាយបានទូលាយស្តីអំពី **"មូលហេតុនៃការមិនទទួលខុសត្រូវ ឬការសម្រាលទោសនូវការទទួលខុសត្រូវព្រហ្មទណ្ឌ"**។ នៅក្នុងមូលហេតុនៃការមិនទទួលខុសត្រូវព្រហ្មទណ្ឌនេះ មានលក្ខណៈដូចជា ភាពដែលមិនអាចទម្លាក់កំហុសបាន គឺមានន័យថា ចារីដែលប្រព្រឹត្តបទល្មើសនោះគឺមាន វិបត្តិវិបល្លាសស្មារតីនៅពេលប្រព្រឹត្តបទល្មើស នៅក្នុងក្រមព្រហ្មទណ្ឌថ្មីពុំបានកម្រិតដាក់ទណ្ឌកម្មទៅលើបុគ្គលណាដែលប្រព្រឹត្តបទល្មើស នៅពេលដែលខ្លួនមាវិបត្តិវិបល្លាសស្មារតីឡើយ នេះគឺមានន័យថាបុគ្គលនោះអាចរួចផុតពីការទទួលខុសត្រូវបាន។ មូលហេតុដែលជាការបញ្ជាដោយច្បាប់ ដោយអាជ្ញាធរ ទៅលើស្ថានភាពចាំបាច់ និងការការពារដោយស្របច្បាប់ (យុត្តិកម្មនៃបទល្មើស) អំពើទាំងនេះក៏អាចរួចផុតពីការទទួលខុសត្រូវបាន ក៏ព្រោះតែវាសុទ្ធសឹងតែជាករណីដែលឲ្យគោរពតាមលក្ខខណ្ឌនៃច្បាប់បានកំណត់មក។ លើសពីនេះទៅទៀតការការពារស្របច្បាប់ក៏អាចរួចផុតពីការទទួលខុសត្រូវព្រហ្មទណ្ឌបានដែរ ដូចជាការការពារខ្លួន ការពារអ្នកដទៃ ឬការការពារទ្រព្យ សម្បត្តិប្រឈមមុខនឹងការឈ្លានពានមួយដែលមិនត្រឹមត្រូវ ក្នុងករណីនេះគឺចង់រក្សាការពារនៃការឈ្លានពានណាមួយដែលមិនត្រឹមត្រូវមួយ ដូច្នេះបុគ្គលដែលតបតទៅនឹងតតិយជនដែលកំពុងរងនូវការឈ្លានពាននោះ គឺមិនត្រូវបានទទួលខុសត្រូវព្រហ្មទណ្ឌឡើយ ។

សរុបមកវិញនៅក្នុងសារណានេះគឺផ្តោតសំខាន់ទៅលើការរួចផុតពីការទទួលខុសត្រូវព្រហ្មទណ្ឌ យើងអាចបញ្ជាក់ឲ្យឃើញថាអំពើ ឬបទល្មើសទាំងអស់គឺមិនមែនសុទ្ធសឹងតែត្រូវការទទួលខុសត្រូវទាំងអស់ឡើយ អំពើខ្លះបុគ្គលបានប្រព្រឹត្តដោយមិនបានយល់ដឹងច្បាស់ថាជាអំពើល្មើសនឹងច្បាប់ អំពើខ្លះទៀតបានប្រព្រឹត្តឡើងក្នុងគោលបំណងក្នុងការការពារ បង្ការ ឬទប់ស្កាត់ នូវគ្រោះថ្នាក់ទាំងឡាយណាដែលរៀបនឹងកើតមានឡើងដែលនឹងអាចគ្រោះថ្នាក់ដល់រូបរាងកាយ ឬអាចឈានទៅដល់ការបាត់បង់ជីវិតជាដើម។

# អនុសាសន៍

គ្រប់បញ្ហា និងដំណោះស្រាយទៅលើបញ្ហាគ្រប់ផ្នែកទាំងអស់ដែលបានរៀបរាប់ខាងលើនេះ ទោះបីជាច្បាប់បានចែងយ៉ាងជាក់ច្បាស់ទៅលើបញ្ហាគតិយុត្តនីមួយៗ ក្នុងការទាញយកហេតុផលសមស្របក្នុងការឲ្យចារីរួចផុតពីការទទួលខុសត្រូវព្រហ្មទណ្ឌ ហើយច្បាប់ពិតជាអនុញ្ញាតឲ្យបុគ្គលណាដែលបានប្រព្រឹត្តបទល្មើសណាមួយដែលមានហេតុផលសមស្របរួចផុតពីការទទួលខុសត្រូវព្រហ្មទណ្ឌក៏ពិតមែន ប៉ុន្តែនៅជុំវិញបញ្ហាគតិយុត្តទាំងអស់នេះរាជរដ្ឋាភិបាល ក៏ដូចជាអ្នកនីតិប្បញ្ញត្តិ គួរតែមានវិធានការបន្ថែមទៅបញ្ហាគតិយុត្តខាងលើនេះបន្ថែមទៀតដើម្បីទប់ស្កាត់ភាគរយនៃការកើនឡើងនៃចំនួនបទល្មើសដដែលជារៀងរាលថ្ងៃ។ បញ្ហាគតិយុត្តខាងលើ បទល្មើសមួយចំនួនសមស្របក្នុងការដែលឲ្យចារីរួចផុតពីការទទួលខុសត្រូវព្រហ្មទណ្ឌដោយមានករណីដូចជា៖ បទល្មើសដែលកើតចេញពីជនវិបល្លាសស្មារតី អានុភាពនៃកម្លាំង ឬការបង្ខំណាមួយដែលមិនអាចមើលឃើញ និងប៉ាន់ស្មានដឹងបានជាមុនទាល់តែសោះ ការអនុញ្ញាតដោយច្បាប់ ឬអាជ្ញាធរស្របច្បាប់ ការការពារ ស្របច្បាប់ក្នុងស្ថានភាពចាំបាច់ណាមួយ។ ប៉ុន្តែបើយើងសង្កេតទៅបទល្មើសដែលកើតចេញពីអនីតិជនវិញ វាហាក់ដូចជាមិនសូវសមស្របទាល់តែសោះ ក្នុងការលើកលែងឲ្យចារីដែលជាអនីតិជនរួចផុតពីការទទួលខុសត្រូវរាល់អំពើល្មើសរបស់ខ្លួនទៅវិញ។ វាពិតជាអយុត្តិធម៌ខ្លាំងបំផុតសម្រាប់ជនរងគ្រោះ បើទោះបីជាតុលាការ មានវិធានការមួយចំនួនសម្រាប់អនុវត្តទៅលើអនីតិជនក៏ដោយ ក៏នៅតែគ្មានភាពវិសមាមាត្ររវាងជនរងគ្រោះដែរ។ ជាក់ស្តែងបទល្មើសឃាតកម្មដោយអចេតនា បានបណ្តាលឲ្យជនរងគ្រោះស្លាប់បាត់ជីវិតជារៀងរហូត ចំណែកចារីដែលជាអនីតិជន បែរជារួចផុតពីការទទួលខុសត្រូវព្រហ្មទណ្ឌទៅវិញ ដោយសារតែចារីពុំទាន់ដល់ នីតិភាពក្នុងការទទួលទណ្ឌកម្មទៅវិញដោយគ្រាន់តែឪពុកម្តាយ ឬអាណាព្យាបាលរបស់ចារីដែលជាអនីតិជន នោះសងជាសំណងរដ្ឋប្បវេណីទៅគ្រួសារជនរងគ្រោះតែប៉ុណ្ណោះ។ ដំណោះស្រាយក្នុងបញ្ហាគតិយុត្តនេះ គួរតែបង្កើតឲ្យមានតុលាការអនីតិជន ផ្សព្វផ្សាយច្បាប់ដែលពាក់ព័ន្ធអនីតិជនឲ្យបានទូលំទូលាយ ពង្រឹងនីតិវិធីក្នុងការអនុវត្តទណ្ឌកម្មទៅលើអនីតិជនឲ្យបានគ្រប់ដំណាក់កាល យ៉ាងសុក្រឹតបំផុតទៅតាមប្រភេទបទល្មើស និងជាពិសេសគួរតែបង្កើតឲ្យមានពន្ធនាគារសម្រាប់ចារី ដែលជាអនីតិជនឲ្យនៅដាច់ដោយឡែកពីចារីដែលជានីតិជន។

## ឯកសារយោង

## ច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត

១. រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ដែលត្រូវបានប្រកាសឲ្យប្រើនៅថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ១៩៩៣

២. អនុសញ្ញាស្តីពីសិទ្ធកុមារ ខែ មិថុនា ឆ្នាំ ២០០៩

៣. ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ដែលប្រកាសឲ្យប្រើប្រាសតាមរយៈរាជក្រមលេខ នស/រកម ១១០៩/០២២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ២០០៩

៤. ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ប្រកាសឲ្យប្រើតាមរយៈរាជក្រមលេខ នស/រកម/០៨០៧/០២៤ ចុះថ្ងៃទី ១០ ខែ សីហា ឆ្នាំ ២០០៧

៥. ច្បាប់ស្តីពីយុត្តិធម៌អនីតិជន ប្រកាសឲ្យប្រើតាមព្រះរាជក្រមលេខ នស/រកម/០៧១៦/០០៩ ចុះថ្ងៃទី ១៤ ខែ កក្កដា ឆ្នាំ ២០១៦

## សៀវភៅ និងអត្ថបទផ្សេងៗ

១. លោក រុន ពណ្ណារិទ្ធ និងលោកស្រី ចាំង ស៊ីណាត "នីតិព្រហ្មទណ្ឌទូទៅ" ឆ្នាំ ២០១១

២. លោក រុន ពណ្ណារិទ្ធ និងលោកស្រី ចាំង ស៊ីណាត "នីតិព្រហ្មទណ្ឌ និងនីតិគ្រួសារ" ឆ្នាំ ២០១៧

៣. លោក ជូ សុភារ៉ា "ឯកសារជំនួយស្មារតីនីតិព្រហ្មទណ្ឌទូទៅ" ឆ្នាំ ២០២០

៤. សារណាបញ្ចប់ការសិក្សារបស់លោកគ្រូ សុជា រស្មី និង អៀង វណ្ណៈ ឆ្នាំ ២០១៦

## វចនានុក្រម និងសន្ទានុក្រម

១. វចនានុក្រមខ្មែរសម្តេចសង្ឃរាជ ជួន ណាត ចេញផ្សាយដោយវិទ្យាស្ថានពុទ្ធសាសនាបណ្ឌិត ឆ្នាំ ១៩៦៧

២. សន្ទានុក្រមពាក្យច្បាប់ខ្មែរ អងគ្លេស បារាំង ផ្នែកព្រហ្មទណ្ឌ ចេញផ្សាយដោយទីស្តីគណៈរដ្ឋមន្ត្រីឆ្នាំ ២០១១

# ឧបសម្ព័ន្ធ

# ក្រមព្រហ្មទណ្ឌ

# ព្រះរាជក្រម

នស/រកម/១១០៩/០២២

## យើង

## ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
## សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
## ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
## ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

-បានទ្រង់យល់ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែកញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យ ប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានទ្រង់យល់ ព្រះរាជក្រមលេខ នស/រកម/១៩៦/០៤ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងយុត្តិធម៌

-បានទ្រង់យល់ សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា និងរដ្ឋមន្ត្រី ក្រសួងយុត្តិធម៌

## ប្រកាសឱ្យប្រើ

ក្រមព្រហ្មទណ្ឌ ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី ១២ ខែតុលា ឆ្នាំ ២០០៩ នាសម័យប្រជុំរដ្ឋសភាលើកទី ៣ នីតិកាលទី ៤ និងដែលព្រឹទ្ធសភាបានយល់ស្របតាមទម្រង់ និងគតិនៃច្បាប់នេះ ទាំងស្រុង ដោយគ្មានការកែប្រែអ្វីឡើយ កាលពីថ្ងៃទី ១៧ ខែវិច្ឆិកា ឆ្នាំ ២០០៩ នាសម័យប្រជុំពេញអង្គព្រឹទ្ធសភាលើកទី ៦ នីតិកាលទី ២ ហើយ ដែលមានសេចក្តីទាំងស្រុង ដូចតទៅនេះ :

២-ពលរដ្ឋទទួលអាណត្តិសាធារណៈដោយការបោះឆ្នោត មានន័យថា ជាសមាជិកព្រឹទ្ធសភា រដ្ឋសភា ក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ និងសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ ព្រមទាំងពលរដ្ឋដែលទទួលអាណត្តិសាធារណៈដោយការបោះឆ្នោត ដើម្បីបំពេញមុខងារសាធារណៈដទៃទៀត ។

## ជំពូកទី ២
## មូលហេតុនៃការមិនទទួលខុសត្រូវ ឬការសម្រាលនូវការទទួលខុសត្រូវព្រហ្មទណ្ឌ

**មាត្រា ៣១.-** ការមិនទទួលខុសត្រូវដោយសារមូលហេតុវិបល្លាសស្មារតី

កាលបើជនណាម្នាក់ប្រព្រឹត្តបទល្មើស នៅពេលដែលជននោះកើតវិបល្លាសស្មារតី ដែលធ្វើឱ្យបាត់បង់នូវការដឹងខុសត្រូវរបស់ខ្លួន ជននោះមិនទទួលខុសត្រូវព្រហ្មទណ្ឌទេ ។

កាលបើជនណាម្នាក់ប្រព្រឹត្តបទល្មើស នៅពេលដែលជននោះកើតវិបល្លាសស្មារតី ដែលបន្ថយនូវការដឹងខុសត្រូវរបស់ខ្លួន ជននោះនៅតែទទួលខុសត្រូវព្រហ្មទណ្ឌដដែល ។ ប៉ុន្តែ តុលាការត្រូវគិតគូរអំពីបញ្ហានេះ កាលណាតុលាការកំណត់ទោស ។

កាលបើជនណាម្នាក់ប្រព្រឹត្តបទល្មើស នៅពេលដែលជននោះកើតវិបល្លាសស្មារតី ដោយសារការប្រើប្រាស់គ្រឿងស្រវឹង គ្រឿងញៀន ឬសារធាតុដែលច្បាប់ហាមឃាត់ មិនអាចរួចផុតពីការទទួលខុសត្រូវព្រហ្មទណ្ឌឡើយ ។

**មាត្រា ៣២.-** ការអនុញ្ញាតដោយច្បាប់ ឬអាជ្ញាធរ

បុគ្គលណាដែលប្រព្រឹត្តអំពើដែលបានបញ្ញត្ត ឬអនុញ្ញាតតាមច្បាប់ បុគ្គលនោះ មិនប្រព្រឹត្តបទល្មើសទេ ។

បុគ្គលណាដែលប្រព្រឹត្តអំពើតាមបញ្ជារបស់អាជ្ញាធរស្របច្បាប់ បុគ្គលនោះមិនប្រព្រឹត្តបទល្មើសទេ លើកលែងតែអំពើនេះជាអំពើខុសច្បាប់យ៉ាងជាក់ច្បាស់ ។

ប៉ុន្តែ ចារី សហចារី អ្នកផ្ដើមគំនិត ឬអ្នកសមគំនិតក្នុងបទប្រល័យពូជសាសន៍ បទឧក្រិដ្ឋប្រឆាំងនឹងមនុស្សជាតិ ឬបទឧក្រិដ្ឋសង្គ្រាម មិនអាចលើកលែងឱ្យផុតពីការទទួលខុសត្រូវព្រហ្មទណ្ឌរបស់ខ្លួនទេ ទោះបីជាក្នុងករណីមានមូលហេតុដូចខាងក្រោមក៏ដោយ :

១-ជនល្មើសនោះបានប្រព្រឹត្តអំពើដែលបញ្ញត្ត អនុញ្ញាត ឬមិនហាមឃាត់ដោយច្បាប់ជាធរមាន ។

២-បុគ្គលនោះបានប្រព្រឹត្តតាមបញ្ជារបស់អាជ្ញាធរស្របច្បាប់ ។

**មាត្រា ៣៣.-** ការការពារស្របច្បាប់

បុគ្គលណាដែលប្រព្រឹត្តបទល្មើសក្នុងសភាពការការពារស្របច្បាប់ មិនទទួលខុសត្រូវព្រហ្មទណ្ឌទេ ។

ការការពារស្របច្បាប់ ត្រូវមានលក្ខខណ្ឌដូចខាងក្រោមនេះ :

-បទល្មើសត្រូវចាត់ទុកថាត្រឹមត្រូវដោយការចាំបាច់ដើម្បីការពារខ្លួន ការពារអ្នកដទៃ ឬការពារទ្រព្យសម្បត្តិប្រឈមមុខនឹងការឈ្លានពានមួយដែលមិនត្រឹមត្រូវ

-បទល្មើស និងការឈ្លានពាន ត្រូវតែកើតឡើងក្នុងពេលជាមួយគ្នា និង

-គ្មានវិសមាមាត្រ រវាងមធ្យោបាយការពារដែលប្រើប្រាស់ និងទម្ងន់នៃការឈ្លានពាន ។

**មាត្រា ៣៤.-** សច្ចធារណីនៃការការពារស្របច្បាប់

ត្រូវសន្មតថាជាការការពារស្របច្បាប់ នៅក្នុងករណីដូចតទៅ :

១-បទល្មើសត្រូវបានប្រព្រឹត្ត ដើម្បីរុញច្រានការចូលក្នុងពេលយប់ ដោយការកាប់គាស់ទម្លុះទម្លាយ ដោយហិង្សា ឬដោយកលល្បិចនៅក្នុងទីកន្លែងដែលមានមនុស្សនៅ ។

២-បទល្មើសបានប្រព្រឹត្ត ដើម្បីការពារខ្លួនប្រឆាំងនឹងការលួច ឬការប្លន់ដែលអនុវត្តដោយហិង្សា ។

សច្ចធារណីនៃការការពារស្របច្បាប់ ពុំមានលក្ខណៈដាច់ខាតទេ ។ សច្ចធារណីនេះ អាចត្រូវរំលាយដោយភស្តុតាងផ្ទុយ ។

**មាត្រា ៣៥.-** ស្ថានភាពចាំបាច់

បុគ្គលដែលស្ថិតនៅក្នុងការចាំបាច់ត្រូវតែប្រព្រឹត្តបទល្មើស មិនទទួលខុសត្រូវព្រហ្មទណ្ឌទេ ។

ស្ថានភាពចាំបាច់ត្រូវមានលក្ខខណ្ឌដូចខាងក្រោមនេះ :

-បទល្មើសត្រូវបានចាត់ទុកថា ត្រឹមត្រូវដោយការចាំបាច់ដើម្បីការពារខ្លួន ការពារអ្នកដទៃ ឬការពារទ្រព្យសម្បត្តិ ប្រឆាំងនឹងគ្រោះថ្នាក់ដែលកំពុងកើតមាន ឬដែលនឹងកើតមាន និង

-គ្មានវិសមាមាត្ររវាងមធ្យោបាយការពារនិងទម្ងន់នៃគ្រោះថ្នាក់ ។

**មាត្រា ៣៦.-** អានុភាពនៃកម្លាំង ឬការបង្ខំ

បុគ្គលដែលប្រព្រឹត្តបទល្មើសក្រោមអានុភាពនៃកម្លាំង ឬការបង្ខំ ដែលបុគ្គលនេះ មិនអាចទប់ទល់បាន បុគ្គលនេះមិនទទួលខុសត្រូវព្រហ្មទណ្ឌទេ ។

កម្លាំង និងការបង្ខំ អាចចេញមកពីព្រឹត្តិការណ៍ក្រៅឆន្ទៈរបស់មនុស្សតែប៉ុណ្ណោះ ។ កម្លាំង និងការបង្ខំនេះត្រូវតែមិនអាចមើលឃើញជាមុនបាន និងមិនអាចជៀសវាងបាន ។

**មាត្រា ៣៧.-** ការមិនទទួលខុសត្រូវព្រហ្មទណ្ឌ

បុគ្គលដែលមិនទទួលខុសត្រូវព្រហ្មទណ្ឌ មិនត្រូវទទួលទណ្ឌកម្មព្រហ្មទណ្ឌណាមួយទេ ។

## ជំពូកទី ៣

## ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់អនីតិជន

**មាត្រា ៣៨.-** នីតិភាពនៃការទទួលខុសត្រូវព្រហ្មទណ្ឌ

នីតិភាពនៃការទទួលខុសត្រូវព្រហ្មទណ្ឌ ត្រូវបានកំណត់អាយុចាប់ពី ១៨ (ដប់ប្រាំបី) ឆ្នាំ ឡើងទៅ ។

# ជំពូកទី ៦
# ទោសដែលអាចអនុវត្តចំពោះអនីតិជន
## ផ្នែកទី ១
## បទប្បញ្ញត្តិទូទៅ

**មាត្រា ១៦០.-** មូលទោសអនុវត្តចំពោះអនីតិជនអាយុចាប់ពី ១៤ ឆ្នាំ ឡើងទៅ

កាលណាតុលាការ សម្រេចផ្តន្ទាទោសព្រហ្មទណ្ឌទៅលើអនីតិជនអាយុចាប់ពី ១៤ (ដប់បួន) ឆ្នាំ ឡើងទៅ មូលទោសលើបទល្មើសដែលចោទប្រកាន់ ត្រូវបាន បន្ថយក្នុងលក្ខខណ្ឌដូចតទៅ :

១-អតិបរមានៃទោសដាក់ពន្ធនាគារត្រូវបន្ថយពាក់កណ្តាល ។

២-ប្រសិនបើអតិបរមានៃទោសនោះ គឺជាទោសដាក់ពន្ធនាគារអស់មួយជីវិត អតិបរមាត្រូវបន្ថយមកដាក់ពន្ធនាគារ ២០ (ម្ភៃ) ឆ្នាំ ។

៣-អប្បបរមានៃទោសដាក់ពន្ធនាគារ ត្រូវបន្ថយពាក់កណ្តាល ប្រសិនបើអប្បបរមានេះលើសពី ១ (មួយ) ថ្ងៃ ។

៤-អប្បបរមា និងអតិបរមានៃទោសពិន័យជាប្រាក់ ត្រូវបន្ថយពាក់កណ្តាល ។

ក្នុងករណីចោទប្រកាន់ពីបទឧក្រិដ្ឋ ប្រសិនបើបទប្បញ្ញត្តិនៃមាត្រានេះមានអានុភាពបន្ថយអតិបរមានៃទោសដាក់ពន្ធនាគារមកត្រឹមថិរវេលាមួយស្មើ ឬតិចជាង ៥ (ប្រាំ) ឆ្នាំ នោះបទល្មើសដែលចោទប្រកាន់នៅតែជាបទឧក្រិដ្ឋដដែល ។

**មាត្រា ១៦១.-** ទោសបន្ថែម

មានតែទោសបន្ថែមដូចតទៅនេះប៉ុណ្ណោះ ដែលអាចអនុវត្តទៅលើអនីតិជន :

១-ការរឹបអូសឧបករណ៍ សម្ភារៈ ឬវត្ថុអ្វីមួយដែលបានប្រើក្នុងការប្រព្រឹត្តបទល្មើស ឬដែលមានគោលដៅប្រព្រឹត្តបទល្មើស ។

២-ការរឹបអូសវត្ថុ ឬមូលនិធិដែលជាកម្មវត្ថុនៃបទល្មើស ។

៣-ការរឹបអូសផលទុន ឬទ្រព្យសម្បត្តិដែលជាផលកើតចេញពីបទល្មើស ។

៤-ការរឹបអូសឧបភោគភណ្ឌ សម្ភារៈ ឬចលនវត្ថុនៅក្នុងទីកន្លែងដែលបទល្មើសត្រូវបានប្រព្រឹត្ត ។

៥-ការហាមឃាត់ចំពោះការកាន់កាប់ ឬការយកតាមខ្លួននូវអាវុធ គ្រឿងផ្ទុះ និងគ្រាប់រំសេវគ្រប់ប្រភេទ ។

**មាត្រា ១៦២.-** ទោសការងារសហគមន៍

ទោសដែលជាការងារសហគមន៍ អាចអនុវត្តទៅលើអនីតិជនដែលមានអាយុយ៉ាងតិច ១៦ (ដប់ប្រាំមួយ) ឆ្នាំ ប៉ុន្តែ ថិរវេលានៃការងារមិនអាចលើសពី ១០០ (មួយរយ) ម៉ោង ។

ការងារសហគមន៍ត្រូវតែសម្របសម្រួលទៅលើអនីតិជន មានលក្ខណៈជាការបណ្តុះបណ្តាល និងសម្រួលដល់ការបញ្ចូលខ្លួនទៅរស់នៅក្នុងសង្គមវិញ ។

**មាត្រា ១៦៣.-** ការមិនអនុវត្តបទប្បញ្ញត្តិស្តីពីការមិនរាងចាល

បទប្បញ្ញត្តិស្តីពីការមិនរាងចាល មិនអនុវត្តទៅលើអនីតិជនទេ ។

**មាត្រា ១៦៤.-** ការទទួលប្រយោជន៍នៃស្ថានសម្រាលទោស

ស្ថានសម្រាលទោសត្រូវអនុវត្តទៅលើអនីតិជន ។

កាលបើតុលាការបានសម្រេចឱ្យមានស្ថានសម្រាលទោស អប្បបរមានៃមូលទោស លើអនីតិជនពីបទឧក្រិដ្ឋ ឬបទមជ្ឈិម ត្រូវបន្ថយតាមខ្នាតដោយឡែកដូចតទៅ :

១-ប្រសិនបើអប្បបរមានៃទោសដាក់ពន្ធនាគារស្មើ ឬលើសពី ១០ (ដប់) ឆ្នាំ នោះអប្បបរមា ត្រូវបន្ថយមកនៅត្រឹម ១ (មួយ) ឆ្នាំ ។

២-ប្រសិនបើអប្បបរមានៃទោសជាប់ពន្ធនាគារស្មើ ឬលើសពី ៥ (ប្រាំ) ឆ្នាំ និងតិចជាង ១០ (ដប់) ឆ្នាំ នោះអប្បបរមា ត្រូវបន្ថយមកត្រឹម ៦ (ប្រាំមួយ) ខែ ។

៣-ប្រសិនបើអប្បបរមានៃទោសដាក់ពន្ធនាគារស្មើ ឬលើសពី ២ (ពីរ) ឆ្នាំ និងតិចជាង ៥ (ប្រាំ) ឆ្នាំ នោះអប្បបរមា ត្រូវបន្ថយមកត្រឹម ៣ (បី) ខែ ។

៤-ប្រសិនបើអប្បបរមានៃទោសដាក់ពន្ធនាគារស្មើ ឬលើសពី ៦ (ប្រាំមួយ) ថ្ងៃ និងតិចជាង ២ (ពីរ) ឆ្នាំ នោះអប្បបរមា ត្រូវបន្ថយត្រឹម ១ (មួយ) ថ្ងៃ ។

៥-អប្បបរមានៃទោសពិន័យជាប្រាក់ ត្រូវបន្ថយពាក់កណ្តាល ។

**មាត្រា ១៦៥.-** កាតព្វកិច្ចដោយឡែកក្នុងករណីនៃការព្យួរទោសសាកល្បង

នៅក្នុងករណីនៃការព្យួរទោសសាកល្បង មានតែកាតព្វកិច្ចដោយឡែកដូចតទៅនេះប៉ុណ្ណោះដែលអាចអនុវត្តទៅលើអនីតិជន :

១-ទទួលការបង្ហាត់បង្រៀន ឬការបណ្តុះបណ្តាលវិជ្ជាជីវៈ ។

២-ស្ថិតនៅទីកន្លែងមួយជាកំណត់ ។

៣-ដាក់ខ្លួនឱ្យពេទ្យពិនិត្យ ឬព្យាបាល ។

៤-ជួសជុលព្យសនកម្មដែលបណ្តាលមកអំពីបទល្មើស ទៅតាមធនធានរបស់ខ្លួន ។

៥-បង្ហាញភស្តុតាង បញ្ជាក់ថាខ្លួនបង់ទឹកប្រាក់ដែលជំពាក់ជូនរដ្ឋរួចហើយ តាមលទ្ធភាពនៃធនធានរបស់ខ្លួន បន្ទាប់ពីការផ្តន្ទាទោស ។

៦-មិនត្រូវបង្ហាញមុខនៅទីកន្លែងខ្លះ ។

៧-មិនត្រូវសេពគប់ ទីកន្លែងលក់ភេសជ្ជៈស្រវឹង ។

៨-មិនត្រូវសេពគប់ជាមួយបុគ្គលខ្លះ ដោយឡែកជាមួយសហចារី អ្នកផ្តើមគំនិត អ្នកសមគំនិត ឬជនរងគ្រោះនៃបទល្មើស ។

៩-មិនត្រូវកាន់កាប់ ឬយកតាមខ្លួននូវអាវុធ គ្រឿងផ្ទុះ និងគ្រាប់រំសេវគ្រប់ប្រភេទ ។ល

## ផ្នែកទី ២

## បទប្បញ្ញត្តិដោយឡែក

**មាត្រា ១៦៦.-** លក្ខខណ្ឌនៃការឃុំខ្លួនអនីតិជនក្នុងពន្ធនាគារ

អនីតិជនដែលជាប់ពន្ធនាគារ ត្រូវឃុំខ្លួននៅទីកន្លែងពិសេស ខណ្ឌដាច់ពីនីតិជន ។ អនីតិជនស្ថិតនៅក្រោមរបបដោយឡែកជាឯកត្តបុគ្គល ដែលជាទីកន្លែង

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# ក្រមនីតិវិធីព្រហ្មទណ្ឌ

# នៃ

# ព្រះរាជាណាចក្រកម្ពុជា



ឆ្នាំ ២០០៧

ក្រសួងយុត្តិធម៌

Ministère de la Justice

នស/រកម/០៨០៧/០២៤

# ព្រះរាជក្រម

## យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី

សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ

ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា

ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

-បានទ្រង់យល់ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានទ្រង់យល់ ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៤ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងយុត្តិធម៌

-បានទ្រង់យល់ សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា និង រដ្ឋមន្ត្រីក្រសួងយុត្តិធម៌

## ប្រកាសឱ្យប្រើ

ក្រមនីតិវិធីព្រហ្មទណ្ឌ ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០០៧ នាសម័យប្រជុំរដ្ឋសភាលើកទី ៦ នីតិកាលទី ៣ និងដែលព្រឹទ្ធសភាបានយល់ស្របតាមទម្រង់ និងគតិនៃក្រមនេះទាំងស្រុង ដោយគ្មានការកែប្រែអ្វីឡើយ កាលពីថ្ងៃទី២៤ ខែកក្កដា ឆ្នាំ២០០៧ នាសម័យប្រជុំពេញអង្គព្រឹទ្ធសភាលើកទី ៣ នីតិកាលទី ២ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅនេះ :

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL

## គន្ថីទី ៣
## ការស៊ើបអង្កេត
### មាតិកាទី ១
### បទប្បញ្ញត្តិទូទៅ
### ជំពូកតែមួយ
### បទប្បញ្ញត្តិទូទៅ

**មាត្រា ៨៣.** – ការសម្ងាត់នៃការស៊ើបអង្កេត

ការស៊ើបអង្កេត ត្រូវតែជាការសម្ងាត់ ។ បុគ្គលទាំងឡាយ ដែលចូលរួមក្នុងការស៊ើបអង្កេត ជាពិសេសចៅក្រមខាងអយ្យការ មេធាវី ក្រឡាបញ្ជី នគរបាល កងរាជអាវុធហត្ថ មន្ត្រីរាជការ អ្នកជំនាញ អ្នកបកប្រែ គ្រូពេទ្យ និងបុគ្គលដែលមានសមត្ថកិច្ចដូចមានចែងក្នុងមាត្រា ៩៥ (ការត្រួតពិនិត្យខាងផ្នែកបច្ចេកទេស ឬវិទ្យាសាស្ត្រ) នៃក្រមនេះ ត្រូវរក្សាការសម្ងាត់នៃវិជ្ជាជីវៈ ។

ប៉ុន្តែ ការគោរពនូវការសម្ងាត់វិជ្ជាជីវៈ មិនមែនជាឧបសគ្គដល់ការប្រើសិទ្ធិនៃការការពារខ្លួនឡើយ ។

ម្យ៉ាងទៀត ព្រះរាជអាជ្ញាត្រូវបានអនុញ្ញាតឱ្យធ្វើសេចក្ដីថ្លែងការណ៍ជាសាធារណៈ កាលណាខ្លួនយល់ឃើញថាព័ត៌មានដែលផ្សព្វផ្សាយពីរឿងណាមួយនោះ ជាព័ត៌មានមិនពិត ។

ការបំពានលើការសម្ងាត់នៃការស៊ើបអង្កេត គឺជាបទល្មើសដែលត្រូវផ្តន្ទាទោសតាមច្បាប់ព្រហ្មទណ្ឌជាធរមាន ។

**មាត្រា ៨៤.** – ភាពខុសគ្នានៃអំណាចរបស់មន្ត្រីនគរបាលយុត្តិធម៌ទៅតាមការស៊ើបអង្កេត

អំណាចទាំងឡាយ ដែលផ្តល់ឱ្យមន្ត្រីនគរបាលយុត្តិធម៌ ខុសគ្នាទៅតាមពេលដែលមន្ត្រីនោះបំពេញការក្នុងក្របខ័ណ្ឌនៃការស៊ើបអង្កេតករណីជាក់ស្តែង ឬក្នុងក្របខ័ណ្ឌនៃការស៊ើបអង្កេតបឋម ។

### មាតិកាទី ២
### ការស៊ើបអង្កេតករណីជាក់ស្តែង
### ជំពូកទី ១
### បទឧក្រិដ្ឋ ឬបទមជ្ឈិមជាក់ស្តែង

**មាត្រា ៨៥.** – អំណាចរបស់មន្ត្រីនគរបាលយុត្តិធម៌ នៅក្នុងករណីស៊ើបអង្កេតបទល្មើសជាក់ស្តែង

ក្នុងករណីមានបទឧក្រិដ្ឋ ឬបទមជ្ឈិមជាក់ស្តែង មន្ត្រីនគរបាលយុត្តិធម៌ត្រូវតែគោរពតាម

បទប្បញ្ញត្តិនៃមាតិកានេះ ។

**មាត្រា ៨៦.** – និយមន័យបទឧក្រិដ្ឋ ឬបទមជ្ឈិមជាក់ស្តែង

បទឧក្រិដ្ឋ ឬបទមជ្ឈិមជាក់ស្តែងគឺ :

-បទល្មើសដែលកំពុងប្រព្រឹត្ត

-បទល្មើសដែលទើបប្រព្រឹត្តរួចភ្លាម ។

ត្រូវចាត់ទុកថា ជាបទឧក្រិដ្ឋ ឬបទមជ្ឈិមជាក់ស្តែងដែរ កាលណានៅក្រោយពេលមានបទល្មើសរួចបន្តិចមក :

-ជនដែលគេសង្ស័យ ត្រូវបានសាធារណជនស្រែកដេញប្រដាប់ចាប់ប្រភឹង

-បុគ្គលដែលត្រូវគេរកឃើញមានវត្ថុ ឬមានស្លាកស្នាម ឬតម្រុយច្បាស់លាស់ ហើយស៊ីសង្វាក់ផ្សេងទៀត ដែលនាំឱ្យគេសន្និដ្ឋានបានថា បុគ្គលនោះបានប្រព្រឹត្ត ឬបានចូលរួមប្រព្រឹត្តបទល្មើស ។

**មាត្រា ៨៧.** – ការចាប់ខ្លួនក្នុងករណីបទឧក្រិដ្ឋ ឬបទមជ្ឈិមជាក់ស្តែង

ក្នុងករណីបទឧក្រិដ្ឋ ឬបទមជ្ឈិមជាក់ស្តែង គ្រប់បុគ្គលទាំងអស់អាចចាប់ខ្លួនជនល្មើស ហើយនាំខ្លួនជននោះទៅប្រគល់ជូនមន្ត្រីនគរបាលយុត្តិធម៌ដែលនៅជិតបំផុត ។

**មាត្រា ៨៨.** – ការចាត់ទុកដូចជាបទឧក្រិដ្ឋ ឬបទមជ្ឈិមជាក់ស្តែង

ត្រូវបានចាត់ទុកដូចជាបទឧក្រិដ្ឋ ឬបទមជ្ឈិមជាក់ស្តែងផងដែរ បើទោះបីជាស្ថិតនៅក្រៅពីករណីដែលមានចែងក្នុងមាត្រា ៨៦ (និយមន័យបទឧក្រិដ្ឋ ឬបទមជ្ឈិមជាក់ស្តែង) ខាងលើនេះក៏ដោយ គ្រប់បទឧក្រិដ្ឋ ឬបទមជ្ឈិមទាំងឡាយណាដែលត្រូវបានប្រព្រឹត្តនៅក្នុងទីកន្លែងដែលអ្នកកាន់កាប់នៅទីនោះ សុំឱ្យព្រះរាជអាជ្ញា ឬមន្ត្រីនគរបាលយុត្តិធម៌ចូលមកពិនិត្យ ឬភ្នាក់ងារនគរបាលយុត្តិធម៌ ក្នុងករណីដែលគ្មានមន្ត្រីនគរបាលយុត្តិធម៌នៅទីកន្លែងនោះ ។ ក្នុងករណីចុងក្រោយនេះ ភ្នាក់ងារនគរបាលយុត្តិធម៌ត្រូវរាយការណ៍ជាបន្ទាន់ជូនដល់មន្ត្រីនគរបាលយុត្តិធម៌ ។

## ជំពូកទី ២
## វិធានការស្រាវជ្រាវ

**មាត្រា ៨៩.** –វិធានការដំបូងក្នុងករណីបទឧក្រិដ្ឋ ឬបទមជ្ឈិមជាក់ស្តែង

ក្នុងករណីបទឧក្រិដ្ឋ ឬបទមជ្ឈិមជាក់ស្តែង មន្ត្រីនគរបាលយុត្តិធម៌ត្រូវរាយការណ៍ភ្លាមជូនព្រះរាជអាជ្ញា ។

មន្ត្រីនគរបាលយុត្តិធម៌ចុះទៅកាន់ទីកន្លែងកើតហេតុ ដើម្បីធ្វើការពិនិត្យបទល្មើស ។ មន្ត្រីនគរបាលយុត្តិធម៌ធានារ៉ាប់រងរក្សាទុកនូវតម្រុយនៃភស្តុតាងទាំងឡាយណាដែលអាចបាត់បង់ ។ មន្ត្រីនគរបាលយុត្តិធម៌ អាចហាមឃាត់បុគ្គលគ្រប់រូបកុំឱ្យទៅទីណាឆ្ងាយពីកន្លែងបទល្មើស រហូតដល់ពេលបញ្ចប់កិច្ចប្រតិបត្តិការរបស់ខ្លួន ។

ប្រសិនបើយល់ឃើញថាមានប្រយោជន៍ ព្រះរាជអាជ្ញាចុះទៅកាន់កន្លែងកើតហេតុ និងដឹកនាំការស៊ើបអង្កេត ។

ប្រសិនបើមានការបន្ទាន់ ព្រះរាជអាជ្ញាអាចអនុញ្ញាតឱ្យមន្ត្រីនគរបាលយុត្តិធម៌ណាម្នាក់ធ្វើប្រតិបត្តិការលើវិសាលភាពទាំងមូលនៃដែនដីជាតិ ដោយគោរពតាមលក្ខខណ្ឌទាំងឡាយដែលមានចែងក្នុងមាត្រា ៦៨ (ការពន្លាតសមត្ថកិច្ចដែនដី) នៃក្រមនេះ ។

**មាត្រា ៩០.** – កំណត់ហេតុលើការស្រាវជ្រាវ និងការពិនិត្យ

មន្ត្រីនគរបាលយុត្តិធម៌ត្រូវធ្វើកំណត់ហេតុស្ដីពីការស្រាវជ្រាវ និងការពិនិត្យរបស់ខ្លួន ។

**មាត្រា ៩១.** – ការឆែកឆេរ

មន្ត្រីនគរបាលយុត្តិធម៌អាចធ្វើការឆែកឆេរបាន ។ ក្នុងករណីនេះ មន្ត្រីនគរបាលយុត្តិធម៌ត្រូវទទួលជាបឋមនូវការអនុញ្ញាតពីព្រះរាជអាជ្ញា ទោះបីជាការអនុញ្ញាតដោយផ្ទាល់មាត់ក៏ដោយ ។

មន្ត្រីនគរបាលយុត្តិធម៌ ត្រូវធ្វើការឆែកឆេរនៅចំពោះមុខអ្នកកាន់កាប់ទីកន្លែង ឬបើគ្មានអ្នកកាន់កាប់ទេ ត្រូវធ្វើនៅចំពោះមុខសាក្សីពីរនាក់ ។ សាក្សីត្រូវចាត់តាំងដោយមន្ត្រីនគរបាលយុត្តិធម៌ ។ សាក្សីមិនអាចជានគរបាល ឬក៏ជាកងរាជអាវុធហត្ថ ដែលជាកងកម្លាំងរួមប្រតិបត្តិការក្នុងការឆែកឆេរនោះបានឡើយ ។

មន្ត្រីនគរបាលយុត្តិធម៌ មិនអាចផ្ដើមធ្វើការឆែកឆេរមុនម៉ោង ៦ (ប្រាំមួយ) ព្រឹក និងក្រោយម៉ោង ១៨ (ដប់ប្រាំបី) ឡើយ លើកលែងតែ :

-ក្នុងករណីដែលមានចែងដោយមាត្រា ៨៦ (និយមន័យបទឧក្រិដ្ឋ ឬបទមជ្ឈិមជាក់ស្ដែង) នៃក្រមនេះ

-ក្នុងករណីដែលចែងដោយមាត្រា ៨៨ (ការចាត់ទុកដូចជាបទឧក្រិដ្ឋ ឬបទមជ្ឈិមជាក់ស្ដែង) នៃក្រមនេះ

-ក្នុងករណីមានសំរែកស្រែកឱ្យគេជួយពីក្នុងទីកន្លែង

-ក្នុងករណីឆែកឆេរនៅទីកន្លែងក្នុងពេលម៉ោងដែលបើកចំហដល់សារធារណជន

-ក្នុងករណីឆែកឆេរនៅគ្រប់ទីកន្លែងដែលផលិត រក្សាទុក ជួញដូរ ចែកចាយ

ប្រើប្រាស់ គ្រឿងញៀន ។

មន្ត្រីនគរបាលយុត្តិធម៌ធ្វើកំណត់ហេតុស្តីពីការឆែកឆេរដែលនៅក្នុងនោះមានចុះ :

-ការអនុញ្ញាតរបស់ព្រះរាជអាជ្ញាដោយប្រាប់ថ្ងៃ និងម៉ោងនៃការអនុញ្ញាតនេះ

-អត្តសញ្ញាណរបស់អ្នកកាន់កាប់ទីកន្លែង ឬរបស់សាក្សីនីមួយៗ ។

មន្ត្រីនគរបាលយុត្តិធម៌ មិនអាចធ្វើការឆែកឆេរនៅក្នុងការិយាល័យមេធាវីបានទេ ។ មានតែព្រះរាជអាជ្ញា ឬចៅក្រមស៊ើបសួរតែប៉ុណ្ណោះ ដែលអាចធ្វើការឆែកឆេរនេះបាន នៅចំពោះមុខប្រធានគណៈមេធាវី ឬប្រតិភូរបស់ប្រធានគណៈមេធាវី ឬមេធាវីសាមី ។

មន្ត្រីនគរបាលយុត្តិធម៌ អាចធ្វើការឆែកឆេរនៅក្នុងអគារសារព័ត៌មាន សហគ្រាសនៃសារព័ត៌មានសរសេរ ឬសហគ្រាសសារព័ត៌មានសោតទស្សន៍ បានតែចំពោះមុខព្រះរាជអាជ្ញា ឬចៅក្រមស៊ើបសួរម្នាក់ ដែលធានារ៉ាប់រងកុំឱ្យការឆែកឆេរនេះ ប៉ះពាល់ដល់ការប្រកបដោយសេរីនូវមុខរបរអ្នកសារព័ត៌មាន និងធ្វើឱ្យយឺតយ៉ាវដល់ការផ្សព្វផ្សាយព័ត៌មាននេះដោយមិនត្រឹមត្រូវ ។

**មាត្រា ៩២.** – ការបិទស្លាកបោះត្រាលើវត្ថុតាង

មន្ត្រីនគរបាលយុត្តិធម៌ អាចចាប់យកវត្ថុតាង ។ មន្ត្រីនគរបាលយុត្តិធម៌ត្រូវបិទស្លាកបោះត្រានៅលើវត្ថុតាងនោះ ។

ក្រោយពីបានបង្ហាញវត្ថុដែលចាប់បានដល់អ្នកកាន់កាប់ទីកន្លែង ឬដល់សាក្សីពីរនាក់មើលរួច មន្ត្រីនគរបាលយុត្តិធម៌ ធ្វើកំណត់ហេតុស្តីពីការចាប់យក ដែលរួមមានបញ្ជីសារពើភ័ណ្ឌនៃវត្ថុដែលចាប់ ។ កំណត់ហេតុស្តីពីការចាប់យក ត្រូវចុះហត្ថលេខា ឬផ្តិតម្រាមដៃដោយអ្នកកាន់កាប់ទីកន្លែង ឬដោយសាក្សីពីរនាក់ ។

**មាត្រា ៩៣.** – កំណត់ហេតុលើការស្តាប់ចម្លើយ

មន្ត្រីនគរបាលយុត្តិធម៌អាចហៅ និងនាំមកកាន់អង្គភាពរបស់ខ្លួននូវបុគ្គលគ្រប់រូបដែលសង្ស័យថា បានចូលរួមក្នុងបទល្មើស ។ មន្ត្រីនគរបាលយុត្តិធម៌ធ្វើការស្តាប់ចម្លើយជនទាំងនោះ ។

ការស្តាប់ចម្លើយនីមួយៗ ត្រូវមានធ្វើកំណត់ហេតុ ។

កំណត់ហេតុត្រូវដកស្រង់តាមដោយត្រឹមត្រូវ នូវសេចក្តីរាយការណ៍របស់បុគ្គលដែលផ្តល់ចម្លើយ ។ ក្នុងករណីចាំបាច់មន្ត្រីនគរបាលយុត្តិធម៌ អាចរកអ្នកបកប្រែដែលស្បថថា និយាយការពិត ស្របតាមជំនឿ ឬសាសនារបស់ខ្លួន ។ អ្នកបកប្រែមិនអាចជ្រើសរើសយកពីក្នុងចំណោមនគរបាល កងរាជអាវុធហត្ថ ឬបុគ្គលដែលទាក់ទិនក្នុងរឿងជាមួយគ្នាបានទេ ។

ទំព័រនីមួយៗនៃកំណត់ហេតុ ត្រូវចុះហត្ថលេខា ឬផ្តិតម្រាមដៃដោយបុគ្គលដែលបានឆ្លើយ ។

មុននឹងចុះហត្ថលេខា ឬផ្តិតម្រាមដៃ បុគ្គលនោះត្រូវអានកំណត់ហេតុឡើងវិញ ។ ក្នុងករណីចាំបាច់ មន្ត្រីនគរបាលយុត្តិធម៌ត្រូវអានដោយសំលេងខ្លាំងៗ នូវខ្លឹមសារកំណត់ហេតុ ។ មន្ត្រីនគរបាលយុត្តិធម៌ អាចហៅរកអ្នកបកប្រែបាន ។ កាលណាបុគ្គលនោះមិនព្រមចុះហត្ថលេខា ឬមិនព្រមផ្តិតម្រាមដៃទេ មន្ត្រីនគរបាលយុត្តិធម៌ត្រូវចុះនិទ្ទេសនៅក្នុងកំណត់ហេតុ ។

**មាត្រា ៩៤.** – បទបញ្ជាឱ្យចូលខ្លួនក្នុងករណីការស៊ើបអង្កេតបទល្មើសជាក់ស្តែង

មន្ត្រីនគរបាលយុត្តិធម៌អាចកោះហៅ និងស្តាប់ចម្លើយបុគ្គលគ្រប់រូប ដែលអាចផ្តល់ព័ត៌មានស្តីអំពីរឿងហេតុបាន ។

បុគ្គលដែលកោះហៅនោះ ត្រូវចូលបង្ហាញខ្លួន ។ ក្នុងករណីរឹងទទឹង មន្ត្រីនគរបាលយុត្តិធម៌ ត្រូវជូនដំណឹងដល់ព្រះរាជអាជ្ញា ដែលអាចចេញបញ្ជាឱ្យចូលខ្លួនបាន ។ បញ្ជាឱ្យចូលខ្លួននេះ ត្រូវមានអត្តសញ្ញាណរបស់បុគ្គលដែលពាក់ព័ន្ធ មានចុះកាលបរិច្ឆេទ និងចុះហត្ថលេខាដោយព្រះរាជអាជ្ញា និងមានបោះត្រាផង ។ បញ្ជាឱ្យចូលខ្លួន អនុញ្ញាតឱ្យមន្ត្រីនគរបាលយុត្តិធម៌ប្រើប្រាស់កម្លាំងសាធារណៈដើម្បីបង្ខំបុគ្គលនោះ ឱ្យចូលបង្ហាញខ្លួន ។ កថាខណ្ឌទី ២ ដល់ទី ៥ នៃមាត្រា ៩៣ (កំណត់ហេតុលើការស្តាប់ចម្លើយ) នៃក្រមនេះ ត្រូវយកមកអនុវត្ត ។

**មាត្រា ៩៥.** – ការត្រួតពិនិត្យខាងផ្នែកបច្ចេកទេស ឬវិទ្យាសាស្ត្រ

ប្រសិនបើត្រូវធ្វើការពិនិត្យបច្ចេកទេស ឬវិទ្យាសាស្ត្រដែលមិនអាចបង្អង់បាន មន្ត្រីនគរបាលយុត្តិធម៌អាចពឹងដល់បុគ្គលគ្រប់រូបដែលមានមុខជំនាញ ។ ប្រសិនបើបុគ្គលនោះមិនទាន់បានចុះឈ្មោះនៅក្នុងបញ្ជីអ្នកជំនាញដូចចែងនៅមាត្រា ១៦៣ (បញ្ជីថ្នាក់ជាតិនៃអ្នកជំនាញ) នៃក្រមនេះទេ បុគ្គលនេះត្រូវស្បថតាមសាសនា ឬជំនឿរបស់ខ្លួនថា នឹងជួយដោយភក្ដីភាពដល់តុលាការ ។

## ជំពូកទី ៣
## ការឃាត់ខ្លួន

**មាត្រា ៩៦.** – ការឃាត់ខ្លួន

ដើម្បីឆ្លើយតបនឹងតម្រូវការចាំបាច់នៃការស៊ើបអង្កេត មន្ត្រីនគរបាលយុត្តិធម៌ អាចឃាត់ខ្លួនបុគ្គលដែលសង្ស័យថា បានចូលរួមក្នុងបទល្មើស ។ មន្ត្រីនគរបាលយុត្តិធម៌ក៏អាចឃាត់ខ្លួនបុគ្គលដែលអាចផ្តល់ព័ត៌មានស្តីអំពីរឿងហេតុបានដែរ ប្រសិនបើលក្ខខណ្ឌខាងក្រោមនេះត្រូវបានបំពេញ :

-បុគ្គលដែលអាចផ្តល់ព័ត៌មានប្រកែកមិនព្រមផ្តល់ព័ត៌មាន

-មានការយល់ព្រមជាលាយលក្ខណ៍អក្សរឱ្យធ្វើការឃាត់ខ្លួនពីព្រះរាជអាជ្ញា ។

មន្ត្រីនគរបាលយុត្តិធម៌ត្រូវរាយការណ៍ភ្លាមជូនព្រះរាជអាជ្ញា ព្រមទាំងត្រូវបញ្ជូនគ្រប់ភស្តុតាងទាំងអស់ដែលតម្រូវឱ្យមានការឃាត់ខ្លួននេះ ។ ការឃាត់ខ្លួនមានថិរវេលា ៤៨ (សែសិបប្រាំបី) ម៉ោង ។ ថិរវេលាត្រូវចាប់គិតពីម៉ោងដែលសាមីខ្លួនមកដល់អង្គភាពនគរបាល ឬកងរាជអាវុធហត្ថ ។

ចំពោះបទឧក្រិដ្ឋ កាលណាមានតម្រុយដែលបង្ហាញឱ្យឃើញថា មានពិរុទ្ធភាពលើបុគ្គលដែលឃាត់ខ្លួន មន្ត្រីនគរបាលយុត្តិធម៌អាចពន្យារពេលឃាត់ខ្លួនបាន ប្រសិនបើវិធានការនេះជាការចាំបាច់ដើម្បីឱ្យការស៊ើបអង្កេតប្រព្រឹត្តទៅបានល្អ ។ ការពន្យារពេលនេះត្រូវសុំទៅព្រះរាជអាជ្ញាដែលត្រូវផ្ទៀងផ្ទាត់មើលមូលកភាព ។ ការអនុញ្ញាតឱ្យពន្យារពេលឃាត់ខ្លួនដែលធ្វើជាលាយលក្ខណ៍អក្សរ និងមានសំអាងហេតុ ត្រូវដាក់បញ្ចូលទៅក្នុងសំណុំរឿង ។ ការពន្យារគឺជាវិធានការពិសេស ។ ការពន្យារនេះមិនអាចឱ្យលើសពី ២៤ (ម្ភៃបួន) ម៉ោង ឡើយ ដោយមិនគិតពីថិរវេលាចាំបាច់ក្នុងការដឹកជញ្ជូន ។

ការពន្យារមិនអាចត្រូវយល់ព្រមបានទេ ប្រសិនបើបុគ្គលដែលឃាត់ខ្លួននោះ ជាអនីតិជន ។

ចំពោះបទឧក្រិដ្ឋ អនីតិជនដែលមានអាយុពី ១៤ ឆ្នាំ ដល់ ក្រោម ១៦ ឆ្នាំ មិនអាចត្រូវគេឃាត់ខ្លួនហួសរយៈពេល ៣៦ ម៉ោងឡើយ ។

ចំពោះបទមជ្ឈិម អនីតិជនដែលមានអាយុពី ១៤ ឆ្នាំ ដល់ ក្រោម ១៦ ឆ្នាំ មិនអាចត្រូវគេឃាត់ខ្លួនហួសរយៈពេល ២៤ ម៉ោងឡើយ ។

ចំពោះបទឧក្រិដ្ឋ អនីតិជនដែលមានអាយុពី ១៦ ឆ្នាំ ដល់ក្រោម ១៨ ឆ្នាំ មិនអាចត្រូវគេឃាត់ខ្លួនហួសរយៈពេល ៤៨ ម៉ោងឡើយ ។

ចំពោះបទមជ្ឈិម អនីតិជនដែលមានអាយុពី ១៦ ឆ្នាំ ដល់ក្រោម ១៨ ឆ្នាំ មិនអាចត្រូវគេឃាត់ខ្លួនហួសរយៈពេល ៣៦ ម៉ោងឡើយ ។

អនីតិជនដែលមានអាយុក្រោម ១៤ ឆ្នាំ ពុំអាចត្រូវគេឃាត់ខ្លួនបានឡើយ ។

**មាត្រា ៩៧.** – កំណត់ហេតុស្តីពីការឃាត់ខ្លួន

កាលណាមានការឃាត់ខ្លួនបុគ្គលណាមួយ មន្ត្រីនគរបាលយុត្តិធម៌ត្រូវឱ្យដំណឹងជាបន្ទាន់អំពីសេចក្តីសម្រេចរបស់ខ្លួនដល់បុគ្គលនោះ ដោយប្រាប់ឱ្យបានដឹងអំពីមូលហេតុនៃសេចក្តីសម្រេចឃាត់ខ្លួននេះ ។ មន្ត្រីនគរបាលយុត្តិធម៌ប្រាប់ដល់សាមីខ្លួនឱ្យបានដឹងផងដែរ អំពីសិទ្ធិដែលបានចែងនៅមាត្រា ៩៨ (ជំនួយរបស់មេធាវីនៅក្នុងពេលឃាត់ខ្លួន) នៃក្រមនេះ ។ ក្នុងករណីចាំបាច់មន្ត្រីនគរបាលយុត្តិធម៌អាចហៅរកអ្នកបកប្រែ ។ មន្ត្រីនគរបាលយុត្តិធម៌ធ្វើកំណត់ហេតុស្តីពីការឃាត់ខ្លួនជាបន្ទាន់ ដោយមានចុះសេចក្តីដូចតទៅ :

-ឈ្មោះ និងឋានៈរបស់មន្ត្រីនគរបាលយុត្តិធម៌ដែលបានបង្គាប់ឱ្យឃាត់ខ្លួន

-អត្តសញ្ញាណនៃបុគ្គលដែលត្រូវឃាត់ខ្លួន

-មូលហេតុនៃការឃាត់ខ្លួន

-ថ្ងៃ ខែ ឆ្នាំ និងម៉ោងដែលផ្តើមឃាត់ខ្លួន

-ការឱ្យដំណឹងអំពីសិទ្ធិដែលបានបញ្ញត្តនៃមាត្រា ៩៨ (ជំនួយរបស់មេធាវីនៅក្នុងពេលឃាត់ខ្លួន) នៃក្រមនេះ

-ជាយថាហេតុ ឈ្មោះអ្នកបកប្រែ ។

កំណត់ហេតុនេះត្រូវមានចុះហត្ថលេខា ឬផ្តិតម្រាមដៃរបស់ជនឃាត់ខ្លួន ក្រោយពីបានអានកំណត់ហេតុរួច ឬបើសាមីខ្លួនមិនចេះអក្សរ មន្ត្រីនគរបាលយុត្តិធម៌ត្រូវអានកំណត់ហេតុឱ្យស្តាប់ ។ ប្រសិនបើជននេះប្រកែកមិនព្រមចុះហត្ថលេខា ឬផ្តិតម្រាមដៃទេ មន្ត្រីនគរបាលយុត្តិធម៌ត្រូវចុះនិទ្ទេស ។ កំណត់ហេតុត្រូវភ្ជាប់ជាមួយសំណុំរឿង ។

**មាត្រា ៩៨.** – ជំនួយរបស់មេធាវីនៅក្នុងពេលឃាត់ខ្លួន

ក្នុងរយៈពេល ២៤ ម៉ោងបានកន្លងផុតទៅ គាំងពីពេលផ្តើមនៃការឃាត់ខ្លួនមកនោះ បុគ្គលដែលឃាត់ខ្លួន អាចសុំសន្ទនាជាមួយមេធាវី ឬជាមួយជនណាម្នាក់ដែលខ្លួនជ្រើសរើស កុំឱ្យតែជននេះមានការទាក់ទិននៅក្នុងរឿងជាមួយ ។ ជននេះត្រូវបានទទួលដំណឹងពីការស្នើសុំជ្រើសរើសនេះ តាមគ្រប់មធ្យោបាយ និងជាបន្ទាន់ ។ ជននេះអាចចូលទៅកាន់កន្លែងឃាត់ខ្លួន និងទាក់ទងជាមួយបុគ្គលសាមីខ្លួនបាន ៣០ (សាមសិប) នាទី ក្នុងលក្ខខណ្ឌធានាការសម្ងាត់នៃការសន្ទនានេះ ។ ក្រោយការសន្ទនាជននេះ អាចធ្វើកំណត់សម្គាល់ជាលាយលក្ខណ៍អក្សរដែលត្រូវភ្ជាប់ជាមួយសំណុំរឿង។

**មាត្រា ៩៩.** – ជំនួយរបស់គ្រូពេទ្យនៅក្នុងពេលឃាត់ខ្លួន

ព្រះរាជអាជ្ញា ឬមន្ត្រីនគរបាលយុត្តិធម៌ សុំឱ្យគ្រូពេទ្យមកពិនិត្យបុគ្គលដែលឃាត់ខ្លួនបានគ្រប់ពេលវេលា ។ គ្រូពេទ្យផ្ទៀងផ្ទាត់មើលថា តើស្ថានភាពសុខភាពនៃបុគ្គលឃាត់ខ្លួននេះ សមស្របនឹងការឃាត់ខ្លួនដែរឬទេ ។

ប្រសិនបើគ្រូពេទ្យយល់ឃើញថា ស្ថានភាពសុខភាពរបស់បុគ្គលនោះ ពុំសមស្របជាមួយនឹងការឃាត់ខ្លួនទេនោះ មន្ត្រីនគរបាលយុត្តិធម៌រាយការណ៍ជាបន្ទាន់ដល់ព្រះរាជអាជ្ញា ។ គ្រូពេទ្យចេញវិញ្ញាបនប័ត្របញ្ជាក់សុខភាពដែលត្រូវភ្ជាប់ជាមួយសំណុំរឿង ។ មន្ត្រីនគរបាលយុត្តិធម៌ ចុះនិទ្ទេសនៅលើកំណត់ហេតុអំពីឈ្មោះរបស់គ្រូពេទ្យ ព្រមទាំងថ្ងៃ ខែ ឆ្នាំ និងម៉ោងនៃការពិនិត្យ

សុខភាព ។

ព្រះរាជអាជ្ញាអាចចុះទៅកាន់ទីកន្លែងផ្ទាល់ ដើម្បីផ្ទៀងផ្ទាត់លក្ខខណ្ឌនៃការឃាត់ខ្លួន ។

**មាត្រា ១០០.** – អនីតិជនដែលត្រូវបានឃាត់ខ្លួន

កាលណាបុគ្គលដែលត្រូវបានឃាត់ខ្លួនជាអនីតិជន មន្ត្រីនគរបាលយុត្តិធម៌ត្រូវជូនព័ត៌មានតាមគ្រប់មធ្យោបាយដល់ឪពុក ម្ដាយ ដល់អ្នកតំណាងស្របច្បាប់ ឬដល់អ្នកទទួលភារកិច្ចលើអនីតិជននេះ ។

**មាត្រា ១០១.** – បញ្ជីនៃការឃាត់ខ្លួន

នៅក្នុងកន្លែងនីមួយៗ របស់នគរបាល ឬកងរាជអាវុធហត្ថ ដែលសម្រាប់ទទួលជនដែលត្រូវឃាត់ខ្លួន ត្រូវមានបញ្ជីស្ដីពីការឃាត់ខ្លួនមួយ ។

គ្រប់ការឃាត់ខ្លួនត្រូវមានចុះនៅក្នុងបញ្ជីដោយមានសេចក្ដីដូចតទៅនេះ :

-ឈ្មោះ និងឋានៈមន្ត្រីនគរបាលយុត្តិធម៌ដែលបានបង្គាប់ឱ្យធ្វើការឃាត់ខ្លួន

-អត្តសញ្ញាណរបស់បុគ្គលដែលឃាត់ខ្លួន

-ថ្ងៃ ខែ ឆ្នាំ និងម៉ោងដែលចាប់ផ្ដើមឃាត់ខ្លួន និងបញ្ចប់ការឃាត់ខ្លួន

-ឈ្មោះ និងឋានៈរបស់ចៅក្រមដែលបានអនុញ្ញាតឱ្យបន្តការឃាត់ខ្លួន ជាយថាហេតុ

-ឈ្មោះរបស់គ្រូពេទ្យដែលបានពិនិត្យបុគ្គលឃាត់ខ្លួន ជាយថាហេតុ

-ប្រភេទនៃសេចក្ដីសម្រេចរបស់អាជ្ញាធរតុលាការនៅពេលផុតកំណត់ការឃាត់ខ្លួន ។

បញ្ជីនេះត្រូវកាន់កាប់ជាប្រចាំសម្រាប់ជូនអាជ្ញាធរតុលាការតាមត្រូវការ ។

**មាត្រា ១០២.** – កំណត់ហេតុសរុបនៃការឃាត់ខ្លួន

គ្រប់ការឃាត់ខ្លួនត្រូវតែមានធ្វើកំណត់ហេតុសរុបនៃការឃាត់ខ្លួន ។

កំណត់ហេតុសរុបនេះត្រូវមានចុះនិទ្ទេសដូចតទៅ :

-ឈ្មោះ និងឋានៈមន្ត្រីនគរបាលយុត្តិធម៌ដែលបង្គាប់ឱ្យឃាត់ខ្លួន

-អត្តសញ្ញាណរបស់បុគ្គលដែលត្រូវឃាត់ខ្លួន

-មូលហេតុនៃការឃាត់ខ្លួន

-ថ្ងៃ ខែ ឆ្នាំ និងម៉ោងដែលផ្ដើមការឃាត់ខ្លួន

-បែបបទនៃការជូនដំណឹងដល់ព្រះរាជអាជ្ញា

-បែបបទនៃការជូនដំណឹងដោយអនុវត្តតាមមាត្រា ១០០ (អនីតិជនដែលត្រូវបានឃាត់ខ្លួន) នៃក្រមនេះ

## ផ្នែកទី ៥
## ការឃុំខ្លួនបណ្ដោះអាសន្ន

**មាត្រា ២០៣.** – គោលការណ៍នៃការឃុំខ្លួនបណ្ដោះអាសន្ន

ជាគោលការណ៍ ជនត្រូវចោទត្រូវតែមានសេរីភាព ។ ក្នុងករណីពិសេស ជនត្រូវចោទអាចត្រូវឃុំខ្លួនបណ្ដោះអាសន្ន នៅក្នុងលក្ខខណ្ឌដែលបានចែងនៅក្នុងផ្នែកនេះ ។

**មាត្រា ២០៤.** – ករណីនៃការឃុំខ្លួនបណ្ដោះអាសន្ន

ការឃុំខ្លួនបណ្ដោះអាសន្ន អាចអនុវត្តបានតែក្នុងករណីចោទប្រកាន់ពីបទឧក្រិដ្ឋ ឬបទមជ្ឈិម ដែលច្បាប់កំណត់ផ្ដន្ទាទោសដាក់ពន្ធនាគារស្មើ ឬលើសពី ១ (មួយ) ឆ្នាំ ។

**មាត្រា ២០៥.** – មូលហេតុនៃការឃុំខ្លួនបណ្ដោះអាសន្ន

ការឃុំខ្លួនបណ្ដោះអាសន្នអាចត្រូវបានបង្គាប់ កាលណាការឃុំខ្លួនបណ្ដោះអាសន្ននេះជាការចាំបាច់ :

១-ដើម្បីបញ្ឈប់បទល្មើស ឬបង្ការបទល្មើសកុំឱ្យកើតជាថ្មី ។

២-ដើម្បីរារាំងកុំឱ្យមានការគាបសង្កត់លើសាក្សី ឬជនរងគ្រោះ ឬដើម្បីរារាំងកុំឱ្យមានការត្រូវរ៉ូវគ្នា រវាងជនត្រូវចោទ និងអ្នកសមគំនិត ។

៣-ដើម្បីរក្សាភស្តុតាង ឬតម្រុយជាសម្ភារៈ ។

៤-ដើម្បីធានារក្សាជនត្រូវចោទ ទុកជូនតុលាការចាត់ការតាមនីតិវិធី ។

៥-ដើម្បីការពារសន្តិសុខឱ្យជនត្រូវចោទ ។

៦-ដើម្បីធានារក្សាសណ្ដាប់ធ្នាប់សាធារណៈកុំឱ្យមានការច្របូកច្របល់ ដែលបណ្ដាលមកពីបទល្មើស ។

**មាត្រា ២០៦.** – កំណត់សម្គាល់របស់ជនត្រូវចោទ និងការប្រាប់ហេតុផលនៃដីកា

ចៅក្រមស៊ើបសួរដែលសម្រេចថានឹងត្រូវឃុំខ្លួនបណ្ដោះអាសន្ន ដោយគំនិតផ្ដើមរបស់ខ្លួនផ្ទាល់ ឬ តាមសេចក្ដីសន្និដ្ឋានរបស់ព្រះរាជអាជ្ញា ត្រូវឱ្យដំណឹងដល់ជនត្រូវចោទ និងទទួលការកត់សម្គាល់របស់ជនត្រូវចោទនេះ ។ កាលណាជនត្រូវចោទមានមេធាវីអមផងនោះ មេធាវីត្រូវបង្ហាញមធ្យោបាយការពារខ្លួន ។

ចៅក្រមស៊ើបសួរសម្រេចឃុំខ្លួនជនត្រូវចោទបណ្ដោះអាសន្នតាមដីកាដោយមានសំអាងហេតុ ។ នៅក្នុងដីកានេះ ចៅក្រមស៊ើបសួរត្រូវយោងតាមបញ្ញត្តិនៃមាត្រា ២០៥ (មូលហេតុនៃការឃុំខ្លួន

បណ្ដោះអាសន្ន) នៃក្រមនេះ ។ ដីកាបង្គាប់ឱ្យឃុំខ្លួនបណ្ដោះអាសន្នត្រូវបានជូនដំណឹងភ្លាមដល់ព្រះរាជអាជ្ញា និងដល់ជនត្រូវចោទ ។

ចៅក្រមស៊ើបសួរចេញដីកាបង្គាប់ឱ្យឃុំខ្លួន ដូចបានចែងនៅក្នុងមាត្រា ២២០ (និយមន័យដីកាបង្គាប់ឱ្យឃុំខ្លួន) មាត្រា ២២១ (និទ្ទេសដែលត្រូវចុះលើដីកាបង្គាប់ឱ្យឃុំខ្លួន) និងមាត្រា ២២២ (ការអនុវត្តដីកាបង្គាប់ឱ្យឃុំខ្លួន) នៃក្រមនេះ ។

**មាត្រា ២០៧.** – ដីកាសម្រេចមិនឃុំខ្លួនបណ្ដោះអាសន្ន

កាលណាចៅក្រមស៊ើបសួរដែលទទួលបណ្ដឹងតាមសេចក្ដីសន្និដ្ឋានរបស់ព្រះរាជអាជ្ញា ដែលសុំឱ្យឃុំខ្លួនជនត្រូវចោទបណ្ដោះអាសន្ននោះ មិនព្រមធ្វើតាមការសុំឱ្យឃុំខ្លួននោះទេ ចៅក្រមស៊ើបសួរត្រូវចេញក្នុងរយៈពេល ៥ (ប្រាំ) ថ្ងៃ នូវដីកាសម្រេចមិនឃុំខ្លួនបណ្ដោះអាសន្ន ដោយមិនចាំបាច់មានសំអាងហេតុទេ ។ ដីកានេះត្រូវជូនដំណឹងជាបន្ទាន់ដល់អ្នកប្ដឹងសុំ ។

ប្រសិនបើចៅក្រមស៊ើបសួរមិនបានសម្រេចនៅក្នុងរយៈពេល ៥ (ប្រាំ) ថ្ងៃ ព្រះរាជអាជ្ញាអាចធ្វើពាក្យប្ដឹងទៅសភាស៊ើបសួរ ដែលនឹងសម្រេចជំនួសចៅក្រមស៊ើបសួរ ។

**មាត្រា ២០៨.** – ថិរវេលានៃការឃុំខ្លួនបណ្ដោះអាសន្នក្នុងបទឧក្រិដ្ឋ

ចំពោះនីតិជនដែលត្រូវចោទប្រកាន់ពីបទឧក្រិដ្ឋ ការឃុំខ្លួនបណ្ដោះអាសន្នមិនអាចលើសពី ៦ (ប្រាំមួយ) ខែ បានទេ ។ ប៉ុន្តែ នៅពេលផុតថិរវេលានេះ ចៅក្រមស៊ើបសួរអាចពន្យារការឃុំខ្លួនបណ្ដោះអាសន្នម្ដងបាន ៦ (ប្រាំមួយ) ខែ ដោយដីកាមានសំអាងហេតុត្រឹមត្រូវ និងច្បាស់លាស់ ។

ចៅក្រមស៊ើបសួរអាចសម្រេចពន្យារការឃុំខ្លួនបណ្ដោះអាសន្នបានតែ ២ (ពីរ) ដងគត់ ។

**មាត្រា ២០៩.** – ថិរវេលានៃការឃុំខ្លួនបណ្ដោះអាសន្នក្នុងបទមជ្ឈិម

ចំពោះនីតិជនដែលត្រូវចោទប្រកាន់ពីបទមជ្ឈិម ការឃុំខ្លួនបណ្ដោះអាសន្នមិនអាចលើសពី ៤ (បួន) ខែ បានទេ ។ ប៉ុន្តែ នៅពេលផុតថិរវេលានេះ ចៅក្រមស៊ើបសួរអាចពន្យារការឃុំខ្លួនបណ្ដោះអាសន្នបានតែម្ដងគត់ មិនឱ្យលើសពី ២ (ពីរ) ខែ ដោយដីកាមានសំអាងហេតុត្រឹមត្រូវ និងច្បាស់លាស់ ។

ថិរវេលានៃការឃុំខ្លួនបណ្ដោះអាសន្នខាងលើនេះ មិនត្រូវលើសពីពាក់កណ្ដាលនៃអប្បបរមានៃទោសដែលច្បាប់បានកំណត់ឡើយ ។

**មាត្រា ២១០.** – ថិរវេលានៃការឃុំខ្លួនបណ្ដោះអាសន្ននៅក្នុងករណីបទឧក្រិដ្ឋប្រឆាំងមនុស្សជាតិ ជាអាទិ៍

# ក្រមរដ្ឋប្បវេណី

# ព្រះរាជក្រម

នស/រកម/១២០៧/០៣០

## យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរជ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរជ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៤ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងយុត្តិធម៌
- បានទ្រង់យល់ សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋមន្ត្រីក្រសួងយុត្តិធម៌

## ប្រកាសឱ្យប្រើ

ក្រមរដ្ឋប្បវេណី ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី០៥ ខែតុលា ឆ្នាំ២០០៧ នាសម័យប្រជុំរដ្ឋសភាលើកទី៧ នីតិកាលទី៣ និងដែលព្រឹទ្ធសភាបានយល់ស្រប តាមទម្រង់ និងគតិនៃក្រមនេះទាំងស្រុង ដោយគ្មានការកែប្រែអ្វីឡើយ កាលពីថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០០៧ នាសម័យប្រជុំពេញអង្គព្រឹទ្ធសភាលើកទី ៤ នីតិកាលទី២ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅនេះ ៖

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL •

**មាត្រា ២៧.–** ការលុបចោលការប្រកាសចាប់ផ្ដើមអាណាព្យាបាលទូទៅ

បើមូលហេតុដែលបានកំណត់នៅក្នុងមាត្រា ២៤ (ការប្រកាសការចាប់ផ្ដើមអាណាព្យាបាលទូទៅ) នៃក្រមនេះ បានរលាយ តុលាការត្រូវលុបចោលនូវការប្រកាសចាប់ផ្ដើមអាណាព្យាបាលទូទៅ តាមពាក្យសុំរបស់សាមីខ្លួន សហព័ទ្ធ ញាតិដែលស្ថិតនៅក្នុង ៤ (បួន) ថ្នាក់ អ្នកអាណាព្យាបាល អ្នកត្រួតពិនិត្យអ្នកអាណាព្យាបាល មេឃុំ ឬ ចៅសង្កាត់នៃលំនៅឋានរបស់ជននោះ ឬ តំណាងអយ្យការ ។

## កថាភាគទី ៣
## ជននៅក្រោមហិតូបត្ថម្ភ

**មាត្រា ២៨.–** ការប្រកាសការចាប់ផ្ដើមហិតូបត្ថម្ភ

១-ចំពោះជនដែលមានសមត្ថភាពតិចតួចពេកក្នុងការយល់ដឹង និង វិនិច្ឆ័យអំពីលទ្ធផលតាមផ្លូវច្បាប់នៃសកម្មភាពរបស់ខ្លួន ដោយសារមានវិបត្តិផ្នែកបញ្ញាស្មារតី តុលាការអាចប្រកាសការចាប់ផ្ដើមហិតូបត្ថម្ភលើជននោះបាន តាមពាក្យសុំរបស់សាមីខ្លួន សហព័ទ្ធ ញាតិដែលស្ថិតនៅក្នុង ៤ (បួន) ថ្នាក់ អ្នកអាណាព្យាបាល អ្នកត្រួតពិនិត្យអ្នកអាណាព្យាបាល មេឃុំ ឬ ចៅសង្កាត់នៃលំនៅឋានរបស់ជននោះ ឬ តំណាងអយ្យការ ។

២-ក្នុងករណីដែលធ្វើការប្រកាសដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ បើសាមីខ្លួនជាជននៅក្រោមអាណាព្យាបាលទូទៅ តុលាការត្រូវលុបចោលការប្រកាសការចាប់ផ្ដើមអាណាព្យាបាលទូទៅចំពោះជននោះ ។

**មាត្រា ២៩.–** អត្ថន័យនៃជននៅក្រោមហិតូបត្ថម្ភ និង ការជ្រើសតាំងហិតូបត្ថម្ភកៈ

ជនដែលបានទទួលការប្រកាសចាប់ផ្ដើមហិតូបត្ថម្ភ ត្រូវហៅថា ជននៅក្រោមហិតូបត្ថម្ភ ហើយត្រូវស្ថិតនៅក្រោមការថែរក្សាដោយហិតូបត្ថម្ភកៈ ។

**មាត្រា ៣០.–** សិទ្ធិលុបចោលសកម្មភាព

លើកលែងតែសកម្មភាពដែលទាក់ទងនឹងជីវភាពរស់នៅប្រចាំថ្ងៃ សកម្មភាពដែល

បានធ្វើឡើងដោយជននៅក្រោមហិត្ថបត្ថម្ភ ដោយគ្មានការយល់ព្រមពីហិត្ថបត្ថម្ភកៈដូចខាងក្រោមនេះ អាចលុបចោលបាន ៖

ក-ការទទួល ឬ ការប្រើប្រាស់ទុន ។

ខ-ការខ្ចីទ្រព្យ ឬ ការធានា ។

គ-ការធ្វើសកម្មភាពដែលមានគោលបំណងទទួលបាន ឬ ធ្វើឱ្យបាត់បង់សិទ្ធិដែលទាក់ទងនឹងអចលនវត្ថុ ឬ ទ្រព្យសម្បត្តិដែលមានសារៈសំខាន់ផ្សេងទៀត ។

ឃ-ការធ្វើសកម្មភាពបណ្ដឹង ។

ង-ការធ្វើប្រទានកម្ម ឬ ធ្វើកិច្ចសន្យាស្រុះស្រួល ឬ កិច្ចសន្យាមជ្ឈត្តកម្ម ។

ច-ការទទួលស្គាល់នូវសន្តតិកម្ម ឬ ការបោះបង់ចោលនូវសិទ្ធិសន្តតិកម្ម ឬ ការបែងចែកនូវមត៌ក ។

ឆ-ការប្រកែកមិនទទួលប្រទានកម្មឬអច្ច័យទាន ឬ ការយល់ព្រមទទួលនូវប្រទានកម្មឬអច្ច័យទានដែលភ្ជាប់នឹងបន្ទុក ។

ជ-ការសាងសង់សំណង់ថ្មី ការសង់ឡើងវិញ ការសង់បន្ថែម ឬ ការជួសជុលធំ ។

ឈ-ការធ្វើភតិសន្យា ដែលមានអំឡុងពេលលើសពី ៣ (បី) ឆ្នាំ ចំពោះដីធ្លីលើសពី ២ (ពីរ) ឆ្នាំ ចំពោះអាគារ លើសពី ៦ (ប្រាំមួយ) ខែ ចំពោះចលនវត្ថុ ។

ញ-សកម្មភាពដែលតុលាការបានប្រកាសជាពិសេសថា ចាំបាច់ត្រូវមានការយល់ព្រមពីហិត្ថបត្ថម្ភកៈ តាមពាក្យសុំរបស់ជនដែលបានរៀបរាប់នៅក្នុងមាត្រា ២៨ (ការប្រកាសការចាប់ផ្ដើមហិត្ថបត្ថម្ភ) នៃក្រមនេះ ឬ ហិត្ថបត្ថម្ភកៈ ឬ អ្នកត្រួតពិនិត្យហិត្ថបត្ថម្ភកៈ ។

**មាត្រា ៣១.–** ការលុបចោលការប្រកាសចាប់ផ្ដើមហិត្ថបត្ថម្ភ

បើមូលហេតុដែលបានកំណត់នៅក្នុងមាត្រា ២៨ (ការប្រកាសការចាប់ផ្ដើមហិត្ថបត្ថម្ភ) នៃក្រមនេះ បានរលាយ តុលាការត្រូវលុបចោលនូវការប្រកាសចាប់ផ្ដើមហិត្ថបត្ថម្ភ តាមពាក្យសុំរបស់សាមីខ្លួន សហព័ទ្ធ ញាតិដែលស្ថិតនៅក្នុង ៤ (បួន) ថ្នាក់ អ្នកអាណាព្យាបាលសម្រាប់អនីតិជន អ្នកត្រួតពិនិត្យអ្នកអាណាព្យាបាលសម្រាប់អនីតិជន

ហិតូបត្ថម្ភកៈ អ្នកត្រួតពិនិត្យហិតូបត្ថម្ភកៈ មេឃុំ ឬ ចៅសង្កាត់នៃលំនៅឋានរបស់ជននោះ ឬ តំណាងអយ្យការ ។

## កថាភាគទី ៤

## ការការពារភាគីម្ខាងទៀតនៃជនដែលត្រូវបានកម្រិតសមត្ថភាព

**មាត្រា ៣២.–** សិទ្ធិដាស់តឿន

១-ភាគីម្ខាងទៀតនៃជនដែលត្រូវបានកម្រិតសមត្ថភាព អាចដាស់តឿនឱ្យជននោះឆ្លើយថាផ្តល់ ឬ មិនផ្តល់សច្ចានុមតិ លើសកម្មភាពដែលជននោះអាចលុបចោលបានក្នុងអំឡុងពេលលើសពី ១ (មួយ) ខែ ក្រោយពេលជននោះបានក្លាយជាសមត្ថជនវិញ ។ ប្រសិនបើជនដែលត្រូវបានកម្រិតសមត្ថភាពដែលបានក្លាយជាសមត្ថជនវិញនោះ មិនឆ្លើយតបក្នុងអំឡុងពេលដែលបានកំណត់ទេ ត្រូវចាត់ទុកថា ជននោះផ្តល់សច្ចានុមតិលើសកម្មភាពនោះ ។

២-បញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ ត្រូវយកមកអនុវត្តផងដែរ ចំពោះករណីដែលភាគីម្ខាងទៀតបានដាស់តឿន ដូចដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើទៅអ្នកមានសិទ្ធិអំណាចមេបា អ្នកអាណាព្យាបាល ឬ ហិតូបត្ថម្ភកៈ អំពីសកម្មភាពដែលស្ថិតនៅក្នុងទំហំនៃសិទ្ធិរបស់ខ្លួន នៅពេលដែលជនដែលត្រូវបានកម្រិតសមត្ថភាព មិនទាន់ក្លាយជាសមត្ថជន តែអ្នកមានសិទ្ធិអំណាចមេបា អ្នកអាណាព្យាបាល ឬ ហិតូបត្ថម្ភកៈ មិនឆ្លើយតប ក្នុងអំឡុងពេលដែលបានកំណត់ទេ ។

៣-ភាគីម្ខាងទៀតអាចដាស់តឿនឱ្យជននៅក្រោមហិតូបត្ថម្ភទទួលយកសច្ចានុមតិពីហិតូបត្ថម្ភកៈ ក្នុងអំឡុងពេលដែលបានកំណត់ក្នុងកថាខណ្ឌទី ១ ខាងលើនេះ ។ ប្រសិនបើជននៅក្រោមហិតូបត្ថម្ភ មិនបានជូនដំណឹងថា ខ្លួនបានទទួលសច្ចានុមតិក្នុងអំឡុងពេលនោះទេ ត្រូវចាត់ទុកថា ជននោះបានលុបចោលសកម្មភាពនោះ ។

**មាត្រា ៣៣.–** ការឆបោករបស់ជនដែលត្រូវបានកម្រិតសមត្ថភាព

ប្រសិនបើជនដែលត្រូវបានកម្រិតសមត្ថភាព បានប្រើប្រាស់មធ្យោបាយឆបោក

ដើម្បីឱ្យគេជឿជាក់ថា ខ្លួនជាសមត្ថជន ជននោះមិនអាចលុបចោលសកម្មភាពបានទេ ។

## ផ្នែកទី ៥
## លំនៅឋាន

**មាត្រា ៣៤.–** អត្ថន័យនៃលំនៅឋាន

កន្លែងដែលជាទីតាំងនៃជីវភាពរស់នៅរបស់បុគ្គលម្នាក់ៗ ត្រូវយកធ្វើជាលំនៅឋាន ។

**មាត្រា ៣៥.–** ទីសំណាក់

ក្នុងករណីដែលកន្លែងដែលជាទីតាំងនៃជីវភាពរស់នៅមិនច្បាស់លាស់ទេ ទីសំណាក់ត្រូវបានចាត់ទុកថាជាលំនៅឋាន ។

**មាត្រា ៣៦.–** ករណីដែលគ្មានលំនៅឋាននៅក្នុងព្រះរាជាណាចក្រកម្ពុជា

ចំពោះបុគ្គលដែលគ្មានលំនៅឋាននៅក្នុងព្រះរាជាណាចក្រកម្ពុជាទេ ទោះបីជាបុគ្គលនោះជាជនជាតិខ្មែរក៏ដោយ ជាជនជាតិបរទេសក៏ដោយ ទីសំណាក់របស់បុគ្គលនោះនៅក្នុងព្រះរាជាណាចក្រកម្ពុជា ត្រូវបានចាត់ទុកថាជាលំនៅឋាន ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវអនុវត្តឡើយ ចំពោះករណីដែលច្បាប់នៃលំនៅឋានត្រូវបានយកមកអនុវត្ត ។

## ផ្នែកទី ៦
## ការគ្រប់គ្រងទ្រព្យសម្បត្តិរបស់បុគ្គលដែលអវត្តមាន និង ការប្រកាសអំពីការបាត់ខ្លួន

### កថាភាគទី ១
### ការគ្រប់គ្រងទ្រព្យសម្បត្តិរបស់បុគ្គលដែលអវត្តមាន

**មាត្រា ៣៧.–** ការជ្រើសតាំងអ្នកគ្រប់គ្រងទ្រព្យសម្បត្តិដោយតុលាការ

ក្នុងករណីដែលបុគ្គលណាម្នាក់ដែលបានចេញពីលំនៅឋាន ឬ ទីសំណាក់ ហើយដែលគ្មានលទ្ធភាពនឹងត្រឡប់មកវិញដោយងាយស្រួលនោះ មិនបានចាត់តាំងអ្នកគ្រប់គ្រង

ទ្រព្យសម្បត្តិរបស់ខ្លួនទេ តុលាការអាចជ្រើសតាំងអ្នកគ្រប់គ្រងទ្រព្យសម្បត្តិ ឬ បង្គាប់ចាត់ចែងជាចាំបាច់ដើម្បីគ្រប់គ្រងទ្រព្យសម្បត្តិនោះបាន តាមពាក្យសុំរបស់បុគ្គលដែលមានទំនាក់ទំនងនឹងផលប្រយោជន៍ មេឃុំ ឬ ចៅសង្កាត់ដែលលំនៅឋានជននោះស្ថិតនៅ ឬ តំណាងអយ្យការ ។ បញ្ញត្តិនេះត្រូវយកមកអនុវត្តផងដែរ ចំពោះករណីដែលសិទ្ធិរបស់អ្នកគ្រប់គ្រងត្រូវបានរលត់ នៅក្នុងរយៈពេលដែលសាមីខ្លួនអវត្តមាន ។

**មាត្រា ៣៨.–** ការលុបចោលការបង្គាប់ឱ្យគ្រប់គ្រងទ្រព្យសម្បត្តិ

ក្នុងករណីដែលបានកំណត់នៅក្នុងមាត្រា ៣៧ (ការជ្រើសតាំងអ្នកគ្រប់គ្រងទ្រព្យសម្បត្តិដោយតុលាការ) នៃក្រមនេះ ប្រសិនបើក្រោយមក បុគ្គលដែលអវត្តមានបានចាត់តាំងអ្នកគ្រប់គ្រង តុលាការអាចលុបចោលនូវការបង្គាប់ តាមពាក្យសុំរបស់អ្នកគ្រប់គ្រង អ្នកដែលមានផលប្រយោជន៍ មេឃុំ ឬ ចៅសង្កាត់ដែលលំនៅឋានជននោះស្ថិតនៅ ឬ តំណាងអយ្យការ ។

**មាត្រា ៣៩.–** ការផ្លាស់ប្តូរអ្នកគ្រប់គ្រង

ក្នុងករណីដែលបុគ្គលអវត្តមានបានចាត់តាំងអ្នកគ្រប់គ្រង ប្រសិនបើពុំមានដំណឹងច្បាស់លាស់ថា អ្នកអវត្តមាននោះនៅរស់ ឬ ទទួលមរណភាពទេ តុលាការអាចផ្លាស់ប្តូរអ្នកគ្រប់គ្រងបាន តាមពាក្យសុំរបស់អ្នកដែលមានផលប្រយោជន៍ មេឃុំ ឬ ចៅសង្កាត់ដែលលំនៅឋានជននោះស្ថិតនៅ ឬ តំណាងអយ្យការ ។

**មាត្រា ៤០.–** សិទ្ធិរបស់អ្នកគ្រប់គ្រងទ្រព្យសម្បត្តិ ជាអាទិ៍

១-អ្នកគ្រប់គ្រងដែលបានជ្រើសតាំងមានសិទ្ធិធ្វើសកម្មភាពដែលបានកំណត់នៅក្នុងកថាខណ្ឌទី ២ មាត្រា ៣៦៦ (ទំហំនៃសិទ្ធិតំណាង) នៃក្រមនេះ ។ ប្រសិនបើចាំបាច់ត្រូវធ្វើសកម្មភាពផ្សេងទៀត អ្នកគ្រប់គ្រងនោះអាចធ្វើបាន ដោយទទួលការអនុញ្ញាតពីតុលាការ ។

២-ក្នុងករណីដែលពុំមានដំណឹងច្បាស់លាស់ថា បុគ្គលអវត្តមាននៅរស់ ឬ ទទួលមរណភាពទេ ហើយអ្នកគ្រប់គ្រងរបស់បុគ្គលអវត្តមាននោះចាំបាច់ត្រូវធ្វើសកម្មភាពដែល

ហួសសិទ្ធិដែលបុគ្គលអវត្តមានបានកំណត់ អ្នកគ្រប់គ្រងនោះអាចធ្វើបាន ដោយទទួលការអនុញ្ញាតពីតុលាការ ។

៣-បើយល់ឃើញថា សមរម្យក្នុងការផ្តល់កម្រៃដល់អ្នកគ្រប់គ្រង ដោយគិតពិចារណា នូវទំនាក់ទំនងរវាងអ្នកអវត្តមាន និង អ្នកគ្រប់គ្រង និង ស្ថានភាពផ្សេងទៀត តុលាការអាចផ្តល់កម្រៃចំនួនសមរម្យដល់អ្នកគ្រប់គ្រង ដោយយកពីទ្រព្យសម្បត្តិរបស់អ្នកអវត្តមានបាន ។

## កថាភាគទី ២

## ការប្រកាសអំពីការបាត់ខ្លួន

**មាត្រា ៤១.–** ល័ក្ខខ័ណ្ឌដើម្បីធ្វើការប្រកាសអំពីការបាត់ខ្លួន

១-ប្រសិនបើពុំមានដំណឹងច្បាស់លាស់ថា អ្នកអវត្តមាននៅរស់ ឬ ទទួលមរណភាពក្នុងអំឡុងពេល ៥ (ប្រាំ) ឆ្នាំ តុលាការអាចប្រកាសបានថា បុគ្គលនោះបានបាត់ខ្លួន តាមពាក្យសុំរបស់សហព័ទ្ធ អ្នកដែលត្រូវបានសន្មតថាជាសន្តតិជន អច្ច័យលាភី អ្នកទទួលប្រាក់ធានារ៉ាប់រង អ្នកមានសិទ្ធិអំណាចមេបា អ្នកអាណាព្យាបាល ឪពុកម្តាយ ឬ អ្នកផ្សេងទៀតដែលមានផលប្រយោជន៍សំខាន់តាមផ្លូវច្បាប់ក្នុងការប្រកាសអំពីការបាត់ខ្លួន ។

២-បញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះត្រូវយកមកអនុវត្តផងដែរ ចំពោះករណីបុគ្គលដែលចូលទៅតំបន់ដែលមានសង្គ្រាម បុគ្គលដែលមានវត្តមាននៅក្នុងនាវាដែលបានលិច ឬ បុគ្គលដែលបានជួបប្រទះនឹងគ្រោះថ្នាក់ផ្សេងទៀតដែលអាចនាំឱ្យទទួលមរណភាព ហើយពុំមានដំណឹងច្បាស់លាស់ថា អ្នកអវត្តមាននៅរស់ ឬ ទទួលមរណភាពក្នុងអំឡុងពេល ១ (មួយ) ឆ្នាំ ក្រោយពីចប់សង្គ្រាម ក្រោយពីនាវាបានលិច ឬ ក្រោយពីគ្រោះថ្នាក់ផ្សេងទៀតនោះ បានកន្លងផុតទៅ ។

**មាត្រា ៤២.–** ការផ្សាយជាសាធារណៈ

ការប្រកាសអំពីការបាត់ខ្លួន ត្រូវធ្វើឡើង ដោយឆ្លងកាត់ទៅតាមនីតិវិធីនៃការផ្សាយជាសាធារណៈ ។